| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | **ក- ការសុំផ្តល់ការអនុញ្ញាតបើកការដ្ឋានដើម្បីស្ថាបនា និងជួសជុលនាវា:**<br>**ក.១- សម្រាប់ការដឹកជញ្ជូនផ្លូវទឹក**<br>1. ពាក្យសុំ......................................................................មួយច្បាប់<br>2. ប្លង់ដីកម្មសិទ្ធមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ............................................................................មួយច្បាប់<br>3. ប្លង់ការដ្ឋាន..............................................................មួយច្បាប់<br>4. បង្កាន់ដៃពន្ធ............................................................មួយច្បាប់<br><u>បញ្ជាក់:</u> បែបបទនៃការសុំផ្តល់ការអនុញ្ញាត ត្រូវធ្វើតាមរយៈមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត នៃមូលដ្ឋានស្នាក់នៅរបស់អតិថិជនអ្នកសុំផ្តល់សេវាមកនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក។<br>**ខ- ការសុំអាជ្ញាបណ្ណស្ថាបនា និងជួសជុលនាវា:**<br>**ខ.១- សម្រាប់ការដឹកជញ្ជូនផ្លូវទឹក**<br>**ខ.១.១- ការស្ថាបនានាវា**<br>1. ពាក្យសុំ.................................................................មួយច្បាប់<br>2. គម្រោងសម្ភារជួសជុល............................................មួយច្បាប់<br>3. ប្លង់បច្ចេកទេសស្ថាបនាជលយាន...............................មួយច្បាប់<br>4. សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស.....................មួយច្បាប់<br>5. សៀវភៅប្រវត្តិជលយាន...........................................មួយច្បាប់<br>6. លិខិតបញ្ជាក់ទីលំនៅឬអត្តសញ្ញាណបណ្ណ ឬបណ្ណគ្រួសារ ...........................................................................មួយច្បាប់<br>7. លិខិតបញ្ជាក់ទីកន្លែងជួសជុលជលយាន.....................មួយច្បាប់<br><u>បញ្ជាក់ :</u> បែបបទនៃការសុំផ្តល់ការអនុញ្ញាត ត្រូវធ្វើតាមរយៈមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត នៃមូលដ្ឋានស្នាក់នៅរបស់អតិថិជនអ្នកសុំផ្តល់សេវាមកនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក។ |
| **យោបល់** | ការបើកការដ្ឋានស្ថាបនា ជួសជុល ឬការស្ថាបនាជួសជុលនាវាគ្រប់ប្រភេទ ទាំងសម្រាប់ការដឹកជញ្ជូនផ្លូវទឹកក្តី នាវាសមុទ្រក្តី ចាំបាច់ត្រូវមានគោលការណ៍គ្រប់គ្រង និងត្រួតពិនិត្យច្បាស់លាស់អំពីសុវត្ថិភាពបច្ចេកទេស បរិស្ថាន និងសន្តិសុខសាធារណៈ។ ដូច្នេះការគ្រប់គ្រងត្រួតពិនិត្យលើអាជីវកម្មប្រភេទនេះ អំពីនីតិវិធី និងគោលការណ៍ច្បាប់ ជាប្រការដែលខានពុំបានសំរាប់ការលើកកំពស់ការចូលរួមរបស់វិស័យឯកជនលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបទៅដោយចីរភាព។ |

# ការផ្តល់លិខិតអនុញ្ញាតយានយន្តឆ្លងដែន

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់លិខិតអនុញ្ញាតយានយន្តឆ្លងដែន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **គណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ គ.ជ.ស.ដ.ឆ** ( National Transit Transport Coodinating Committee NTTCC )។<br>**អង្គភាពសម្របសម្រួលការងារ ៖**<br>លេខាធិការដ្ឋានបច្ចេកទេសនៃគណៈកម្មាធិការជាតិសំរបសំរួល ការដឹកជញ្ជូនឆ្លងកាត់ (គ.ជ.ស.ដ.ឆ )។<br>• អាសយដ្ឋាន ៖ ស្ថិតនៅតាមផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ២ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ<br>• ទូរសព្ទ័លេខ ៖ 012 273 327 , 012 900 735 012 900 729 និង 012 844 098<br>• អ៊ីម៉ែល ៖ chan_dara@online.com.kh / soryana22@yahoo.com hongsinara@yahoo.com / vanhong01@yahoo.com |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់នូវការអនុញ្ញាតឱ្យយានយន្តដែលបំរើពាណិជ្ជកម្ម និងយានយន្តមិនបំរើពាណិជ្ជកម្មធ្វើចរាចរឆ្លងដែនទ្វេភាគី ឬពហុភាគីរវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹងប្រទេសជាសមាជិកអាស៊ាន ឬប្រទេសនានាដែលមានកិច្ចព្រមព្រៀងជាមួយគ្នា។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ចរាចរផ្លូវគោកដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១១៥/០០១ ចុះថ្ងៃ ទី០៩ ខែមករា ឆ្នាំ២០១៥<br>• អនុក្រឹត្យលេខ ១១៥ អនក្រ-បក ចុះ ថ្ងៃ ទី២១ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការបង្កើតកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូន ឆ្លងកាត់<br>• ប្រកាសលេខ ៣៧៤ ប្រក-សក ចុះ ថ្ងៃទី០៥ តុលា ឆ្នាំ២០០៦ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការគ្រប់គ្រងយានយន្តធ្វើចរាចរណ៍ឆ្លងដែន<br>• ប្រកាសរួមលេខ ៩៩០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• ប្រកាសរួមលេខ ១៤៣០ ប្រក.សក.សហវ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៤ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែប្រែកម្រងសេវាសាធាណៈនៃតារាង២បសម្ព័នភ្ជាប់ និងប្រកាសរួមលេខ៩៨៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួង<br>• ប្រកាសរួមលេខ ១៤៣១ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែប្រការ ៤ នៃប្រកាសរួម លេខ ៩៩០ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | នីតិបុគ្គល ឬរូបវន្តបុគ្គល ឬប្រតិបត្តិករដឹកជញ្ជូនទាំងអស់ដែលមានធ្វើការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរឆ្លងដែនជាទ្វេភាគី ឬពហុភាគីរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងប្រទេសទាំងឡាយដែលជាសមាជិកនៃមហាអនុតំបន់ទន្លេ |

| | |
|---|---|
| | មេគង្គ ឬជាមួយនឹងប្រទេសជាសមាជិកអាស៊ាន។ |
| ស្តង់ដាសេវា | • ដឹកជញ្ជូនទំនិញឆ្លងដែន........................................៤០០ ០០០ រៀល<br>• ដឹកជញ្ជូនអ្នកដំណើរឆ្លងដែន..................................៤០០ ០០០ រៀល<br>• យានយន្តមិនបំរើពាណិជ្ជកម្ម.....................................៥០ ០០០ រៀល<br>• ផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម ......................១ ០០០ ០០០ រៀល<br>• បន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្ម ............៨០០ ០០០ រៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | **១- អតិថិជនដែលមកសុំការអនុញ្ញាតប្រកបអាជីវកម្មឆ្លងដែនត្រូវបំពេញនូវបែបបទដូចខាងក្រោម ៖**<br>១.១-ពាក្យសុំការអនុញ្ញាត្តប្រកបអជាវីកម្មឆ្លងដែ..........................មួយច្បាប់<br>១.២-លក្ខន្តិកៈក្រុមហ៊ុន..........................................................មួយច្បាប់<br>១.៣-លិខិតថ្កោលទោស (អាជីវកម្មដំបូង)................................មួយច្បាប់<br>១.៤-តារាងតុល្យការប្រចាំឆ្នាំ..................................................មួយច្បាប់<br>១.៥-លិខិតចុះបញ្ជីពាណិជ្ជកម្ម................................................មួយច្បាប់<br>១.៦-បណ្ណធានារ៉ាប់រង..........................................................មួយច្បាប់<br>១.៧-បង្កាន់ដៃបង់ប្រាក់.........................................................មួយច្បាប់<br>**២- អតិថិជនដែលមកសុំការអនុញ្ញាតយានយន្តឆ្លងដែនត្រូវបំពេញនូវបែបបទដូចខាងក្រោម ៖**<br>២.១- ពាក្យសុំការអនុញ្ញាតយានយន្តឆ្លងដែន............................មួយច្បាប់<br>២.២- ប័ណ្ណសំគាល់យានយន្ត ................................................មួយច្បាប់<br>២.៣- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត.........មួយច្បាប់<br>២.៤- ប័ណ្ណបើកបរ ..............................................................មួយច្បាប់<br>២.៥- លិខិតអនុញ្ញាតប្រកបអាជីវកម្មឆ្លងដែន ............................មួយច្បាប់<br>២.៦- ប័ណ្ណធានារ៉ាប់រង .........................................................មួយច្បាប់<br>២.៧-ប័ណ្ណប៉ាតង់ប្រចាំឆ្នាំ......................................................មួយច្បាប់<br>២.៨-បង្កាន់ដៃបង់ប្រាក់.........................................................មួយច្បាប់ |
| យោបល់ | ជានីតិវិធី និងបែបបទកំណត់ជាផ្លូវការនៅក្នុងកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងប្រទេសទាំងឡាយជាសមាជិកនៃមហាអនុតំបន់ទន្លេមេគង្គជាមួយនឹងប្រទេសជាសមាជិកអាស៊ាន។ ការខកខានពុំបានសុំការអនុញ្ញាតឱ្យយានយន្តឆ្លងដែននោះ ការដឹកជញ្ជូនឆ្លងដែនក៏ពុំអាចអនុញ្ញាតឱ្យធ្វើទៅបានឡើយ។ |

# ការផ្តល់លិខិតអនុញ្ញាតជលយានឆ្លងដែន

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់លិខិតអនុញ្ញាតជលយានឆ្លងដែន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសាធារណការ និងដឹកជញ្ជូន**<br>**នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក**<br>អាស័យដ្ឋាន:<br>• ស្ថិតនៅតាមបណ្តោយផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ - ទូរសារ : ០២៣ ៨៦៤ ០៨៥<br>• អ៊ីម៉ែល : vuthy.bong@yahoo.com |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់នូវការអនុញ្ញាតអោយជលយានដែលបំពេញពាណិជ្ជកម្ម និងជលយានមិនបំពេញពាណិជ្ជកម្មធ្វើចរាចរឆ្លងដែនទ្វេភាគី រឺពហុភាគីរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនិងប្រទេសជាសមាជិកអាស៊ាន រឺប្រទេសនានាដែលមានកិច្ចព្រមព្រៀងជាមួយគ្នា។ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/០៦១០/០០៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក។<br>• ប្រកាសលេខ ៥៣៧ ប្រក.សក.ដជ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតនាវាឆ្លងកាត់ព្រំដែន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។<br>• ប្រកាសរួមលេខ ១៤៣០ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន លើប្រកាសលេខ ៩៨៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | នីតិបុគ្គល ឬរូបវន្តបុគ្គល ឬប្រតិបត្តិករដឹកជញ្ជូនទាំងអស់ដែលបានធ្វើការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរឆ្លងដែនជាទ្វេភាគី ឬពហុភាគីរវាង ព្រះរាជាណាចក្រកម្ពុជា ជាមួយនិងប្រទេសទាំងឡាយដែលជាសមាជិកនៃមហាអនុតំបន់ទន្លេមេគង្គ ឬជាមួយនឹងប្រទេសជាសមាជិកអាស៊ាន។ |
| ស្តង់ដាសេវា | **អ្នកដាក់ពាក្យសុំសេវា មានកាតព្វកិច្ចត្រូវបង់ថ្លៃបំរើសេវា ដូចខាងក្រោម ៖**<br>• ជលយានដឹកជញ្ជូនឆ្លងដែន......................................៤០០ ០០០រៀល |
| តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា | អតិថិជនដែលមានមកសុំផ្តល់ការអនុញ្ញាតជលយានឆ្លងដែន ត្រូវបំពេញបែបបទដូចខាងក្រោម ៖<br>1. ពាក្យសុំការអនុញ្ញាតជលយានឆ្លងដែន..........................មួយច្បាប់<br>2. បណ្ណសំគាល់ជលយាន.............................................មួយច្បាប់<br>3. វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន......មួយច្បាប់<br>4. លិខិតអនុញ្ញាតប្រកបអាជីវកម្មឆ្លងដែន.........................មួយច្បាប់<br>5. បណ្ណប៉ាតង់ប្រចាំឆ្នាំ..................................................មួយច្បាប់ |
| យោបល់ | ជានីតិវិធី និងបែបបទកំណត់ជាផ្លូវការនៅក្នុងកិច្ចព្រមព្រៀងរវាង ព្រះរាជាណាចក្រកម្ពុជា ជាមួយនិងប្រទេសទាំងឡាយជាសមាជិក នៃមហាអនុតំបន់ទន្លេមេគង្គ ជាមួយនិងប្រទេសជាសមាជិកអាស៊ាន។ ការខកខានពុំបានសុំការអនុញ្ញាតអោយជលយានឆ្លងដែននោះ ការដឹកជញ្ជូនឆ្លងដែនក៏ពុំ |

| | |
|---|---|
| | អាចអនុញ្ញាតអោយធ្វើបានទៅបានឡើយ។ |

# ការអនុញ្ញាឲ្យបើកការដ្ឋានស្ថាបនា ជួសជុលនាវា និងការស្ថាបនាជួសជុលនាវាគ្រប់ប្រភេទតាមផ្លូវសមុទ្រ

| | |
|---|---|
| ឈ្មោះសេវា | ការអនុញ្ញាឲ្យបើកការដ្ឋានស្ថាបនា ជួសជុលនាវា និងការស្ថាបនាជួសជុលនាវាគ្រប់ប្រភេទតាមផ្លូវសមុទ្រ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងសាធារណការ និងដឹកជញ្ជូន**<br>**១.នាយកដ្ឋានដឹកជញ្ជូនផ្លូវសមុទ្រ៖**<br>ទទួលបំរើការផ្តល់ការអនុញ្ញាតច្បាប់ឲ្យធ្វើអាជីវកម្មដឹកទំនិញ និងអ្នកដំណើរឆ្លងកាត់ខេត្តនានាតាមផ្លូវសមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជា។<br>• អាស័យដ្ឋាន: ស្ថិតនៅតាមបណ្តោយផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ/ទូរសារលេខ : ០២៣ ៨៦៤ ១១០<br>• អ៊ីម៉ែល: mmd@online.com.kh |
| គោលបំណងនៃការផ្តល់សេវា | **គោលបំណងនៃការផ្តល់សេវានេះ គឺដើម្បីសម្រួលដល់:**<br>1. ប្រជាពលរដ្ឋក្នុងការស្ថាបនាជួសជុលកែច្នៃជលយានគ្រប់ប្រភេទសម្រាប់ដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវទឹក និងផ្លូវសមុទ្រ ដើម្បីបំរើនូវសេចក្តីត្រូវការប្រចាំថ្ងៃ និងចំពោះមុខក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន ដើម្បីរួមចំណែកកាត់បន្ថយនូវភាពក្រីក្រ។<br>2. ការរៀបចំសណ្តាប់ធ្នាប់សន្តិសុខ និងសុវត្ថិភាពក្នុងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវទឹក និងផ្លូវសមុទ្រ ដើម្បីជួយកាត់បន្ថយនូវគ្រោះថ្នាក់នាវាចរណ៍ដែលកើតមានឡើយដោយថាហេតុដែលបណ្តាលមកពីភាពអនាធិបតេយ្យ នៃការប្រើប្រាស់ជលយានកែច្នៃទាំងនោះ។ |
| មូលដ្ឋានគតិយុត្ត | • ប្រកាសអន្តរក្រសួងលេខ ៥៣៥ ប្រក.សក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីពីការ កំណត់ថ្លៃសេវាកម្មសាធារណៈ ដឹកជញ្ជូនផ្លូវគោក ដឹកជញ្ជូនផ្លូវទឹក និងនាវាជំនួញសមុទ្រ។<br>• សារាចរលេខ ០០២ សរណន.គម.តពស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៨៩ របស់ក្រសួងគមនាគមន៍ដឹកជញ្ជូន និងប្រៃសណីយ៍ ស្តីពីការគ្រប់គ្រងមធ្យោបាយដឹក ជញ្ជូនផ្លូវគោក និងផ្លូវទឹក ក្នុងរដ្ឋកម្ពុជា។<br>• សារាចរណែនាំលេខ ០០៦ សរណន.សក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៩ របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការគ្រប់គ្រងវិស័យនាវាចរណ៍សមុទ្រ។<br>• សារាចរលេខ ០០៣ សរណន.សក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ របស់ ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនតាម ផ្លូវទឹក។ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | អតិថិជន អាជីវករទាំងអស់ដែលមានមធ្យោបាយដឹកជញ្ជូនតាមផ្លូវគោកក្តី ផ្លូវទឹកក្តី ឬសមុទ្រក្តី ហើយមានបំណងចង់យកមធ្យោបាយទាំងអស់នោះ ទៅបំរើអាជីវកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរនៅក្នុងមូលដ្ឋានខេត្ត ឬឆ្លងកាត់ខេត្ត និងដឹកជញ្ជូនឆ្លងដែនទៅក្រៅប្រទេស។ |
| ស្តង់ដាសេវា | **ស្រាវជ្រាវរុករកទេសចរណ៍ និងការនេសាទតាមផ្លូវទឹក និងផ្លូវសមុទ្រនៅកម្ពុជា**<br>**១. ច្បាប់អនុញ្ញាតស្ថាបនានាវា**<br>• នាវាមានចំណុះផ្ទុក២០តោនចុះក្រោម.......................២០០ ០០០រៀល<br>• នាវាមានចំណុះផ្ទុកលើសពី២០តោន ដល់១៥០តោន...២៦០ ០០០រៀល |

| | |
|---|---|
| | • នាវាមានចំណុះផ្ទុកលើសពី១៥០តោន ដល់៣០០តោន.៤០០ ០០០រៀល<br>• នាវាមានចំណុះផ្ទុកលើសពី៣០០តោន......................៥០០ ០០០រៀល<br>**២. ការបង្កើតយានដ្ឋានសាងសង់ ឬជួសជុលនាវា**<br>• លិខិតបង្កើតការដ្ឋានសាងសង់ ឬជួសជុល..................៥០០ ០០០រៀល<br>• លិខិតអនុញ្ញាតប្រតិបត្តិការ.....................................២០០ ០០០រៀល<br>• បន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការ.................២០០ ០០០រៀល<br>**៣. ការបង្កើតការសាងសង់ និងប្រតិបត្តិការកំពង់ផែ**<br>• លិខិតវាយតម្លៃផែនការកម្មកំពង់ផែ ឬលិខិតអនុញ្ញាតបង្កើតកំពង់ផែ<br>......................................................................២ ០០០ ០០០រៀល<br>• លិខិតអនុញ្ញាតសាងសង់កំពង់ផែ..........................២ ០០០ ០០០រៀល<br>• លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ.......................៤ ០០០ ០០០រៀល<br>• បន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ...៣ ០០០ ០០០រៀល<br>**៤. ការបង្កើត និងប្រតិបត្តិការសាលាបណ្តុះបណ្តាលនាវិក**<br>• លិខិតអនុញ្ញាតបង្កើត........................................២ ០០០ ០០០រៀល<br>• លិខិតអនុញ្ញាតប្រតិបត្តិការ.................................១ ៦០០ ០០០រៀល<br>• បន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការ..............១ ០០០ ០០០រៀល |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | **ក- ការសុំផ្តល់ការអនុញ្ញាតបើកការដ្ឋានដើម្បីស្ថាបនា និងជួសជុលនាវា:**<br>**ក.១- សម្រាប់ការដឹកជញ្ជូនផ្លូវសមុទ្រ**<br>1. ពាក្យសុំ.....................................................................មួយច្បាប់<br>2. ប្លង់ដីកម្មសិទ្ធមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន<br>...............................................................................មួយច្បាប់<br>3. ប្លង់ការដ្ឋាន..............................................................មួយច្បាប់<br>4. បង្កាន់ដៃពន្ធ.............................................................មួយច្បាប់<br><u>បញ្ជាក់:</u> បែបបទនៃការសុំផ្តល់ការអនុញ្ញាត ត្រូវធ្វើតាមរយៈមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត នៃមូលដ្ឋានស្នាក់នៅរបស់អតិថិជនអ្នកសុំផ្តល់សេវាមកនាយកដ្ឋានដឹកជញ្ជូនជំនួញសមុទ្រ។<br>**ខ- ការសុំអាជ្ញាបណ្ណស្ថាបនា និងជួសជុលនាវា:**<br>**ខ.១- សេវាសាធារណៈលើផ្នែកនាវាជំនួញសមុទ្រ**<br>**ខ.១.១- ការស្ថាបនានាវា**<br>8. ពាក្យសុំ................................................................មួយច្បាប់<br>9. គម្រោងសម្ភារជួសជុល...........................................មួយច្បាប់<br>10. ប្លង់បច្ចេកទេសស្ថាបនាជលយាន...............................មួយច្បាប់<br>11. សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស.....................មួយច្បាប់<br>12. សៀវភៅប្រវត្តិជលយាន..........................................មួយច្បាប់<br>13. លិខិតបញ្ជាក់ទីលំនៅ ឬអត្តសញ្ញាណបណ្ណ ឬបណ្ណគ្រួសារ<br>..........................................................................មួយច្បាប់<br>14. លិខិតបញ្ជាក់ទីកន្លែងជួសជុលជលយាន.....................មួយច្បាប់<br><u>បញ្ជាក់ :</u> បែបបទនៃការសុំផ្តល់ការអនុញ្ញាត ត្រូវធ្វើតាមរយៈមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត នៃមូលដ្ឋានស្នាក់នៅរបស់អតិថិជនអ្នកសុំផ្តល់សេវាមកនាយកដ្ឋានជំនួញសមុទ្រ។ |
| **យោបល់** | ការបើកការដ្ឋានស្ថាបនា ជួសជុល ឬការស្ថាបនាជួសជុលនាវាគ្រប់ប្រភេទ ទាំងសម្រាប់ការដឹកជញ្ជូនផ្លូវទឹកក្តី នាវាសមុទ្រក្តី ចាំបាច់ត្រូវមានគោលការណ៍ |

| | |
|---|---|
| | គ្រប់គ្រង និងត្រួតពិនិត្យច្បាស់លាស់អំពីសុវត្ថិភាពបច្ចេកទេស បរិស្ថាន និងសន្តិសុខសាធារណៈ។ ដូច្នេះការគ្រប់គ្រងត្រួតពិនិត្យលើអាជីវកម្មប្រភេទនេះ អំពីនីតិវិធី និងគោលការណ៍ច្បាប់ ជាប្រការដែលខានពុំបានសំរាប់ការលើកកំពស់ការចូលរួមរបស់វិស័យឯកជនលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបទៅដោយចីរភាព។ |

# ក្រសួងរ៉ែ និងថាមពល

អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣)
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤
ទូរសារៈ (៨៥៥)២៣-២១៩ ៥៨៤

# អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ |
| ក្រសួង/ស្ថាប័ន ផ្ដល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥) ២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្ដល់សេវា | អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែក្នុងគោលបំណងអនុវត្ត ការងារស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែ ដោយប្រើប្រាស់ឧបករណ៍សម្ភារសាមញ្ញ ដែលមាននៅក្នុងមូលដ្ឋាន ហើយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួន ឬជាលក្ខណៈគ្រួសារដែលមានចំនួនមិនលើសពី ៧(ប្រាំពីរ)នាក់ ។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ<br>• ប្រកាសលេខ ៣៤០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ឧសភា ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្ដល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ<br>• ប្រកាសលេខ ៥២០ រថ.រស.ប្រកចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្ដល់អាជ្ញាបណ្ណសិប្បកម្ម ធនធានរ៉ែ និងអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ គោលបំណងអាជីវកម្មក្រួស ខ្សាច់ ដីឥដ្ឋ និងដីល្បាប់<br>• ប្រកាសលេខ ០០០២ រថ.អធរ.ប្រក ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៥ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណសិប្បកម្ម ធនធានរ៉ែ និងអាជ្ញាបណ្ណធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូច<br>• ប្រកាសលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់<br>• ប្រកាសលេខ ០១៤៥ រថ.នក.ប្រក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជូនមន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត ក្នុងការពិនិត្យសម្រេច និងផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ<br>• អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ មានសុពលភាពមួយ (០១) ឆ្នាំ ។<br>• ប្រកាសអន្តរក្រសួង លេខៈ ១៩១ ប្រក ប.ស្ត ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច។ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនជាតិខ្មែរ តែប៉ុណ្ណោះ |
| ស្តង់ដាសេវា | **ក. ការទទួលសេវា**<br>១- នីតិវិធី<br>• អតិថិជនអាចមកដាក់ពាក្យសុំនៅប្រកចេញ-ចូលតែមួយ របស់មន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត<br>• ក្រោយពីអង្គភាពជំនាញ ពិនិត្យលើសំនុំឯកសារឃើញថាគ្រប់គ្រាន់នោះ |

| | |
|---|---|
| | និងចុះត្រួតពិនិត្យមើលទីតាំង និងការដ្ឋានបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបរិស្ថានរួចហើយក្នុងរយៈពេល ៤៥ថ្ងៃ បន្ទាប់អតិថិជនអាចមកបង់តម្លៃសេវានៃអាជ្ញាប័ណ្ណនៅមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត ។<br>• កម្រៃអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ..........................១០០, ០០០រៀល<br>• សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណ និងសិប្បកម្មធនធានរ៉ែ ...............................................១០០, ០០០រៀល<br>• ការចុះបញ្ជីអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ......៥០, ០០០រៀល |
| **តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា** | **ត្រូវមានការយល់ព្រមពីក្រសួងរ៉ែ និងថាមពលជាមុនក្នុងការទទួល បាននូវសម្បទានដីសម្រាប់សិក្សាស្រាវជ្រាវនិងធ្វើអាជីវកម្មធនធានរ៉ែ**<br>**ឯកសារសម្រាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ រួមមានៈ**<br>1. ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ តាមគំរូពាក្យដែលកំណត់ដោយក្រសួងរ៉ែ និងថាមពល (មានបិទតែម ២,០០០រៀល) ....ចំនួន១ច្បាប់<br>2. ប្រវត្តិរូបសង្ខេប និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម..................ចំនួន១ច្បាប់<br>3. លិខិតទទួលស្គាល់ពីអាជ្ញាធរឃុំ សង្កាត់ លក្ខន្តិកៈសហគមន៍សិប្បកររ៉ែ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ក្នុងករណីចងក្រងជាសហគមន៍ ..........................................................................ចំនួន១ច្បាប់<br>4. ឯកសារបញ្ជាក់ប្លង់កម្មសិទ្ធដីស្របច្បាប់ពាក់ព័ន្ធ ក្នុងករណីប្រតិបត្តិការធនធានរ៉ែស្ថិតក្នុងដីកម្មសិទ្ធឯកជន.............................ចំនួន១ច្បាប់<br>5. គំរោងសំណើរបច្ចេកទេសអាជីវកម្មរ៉ែ និងផែនការអាជីវកម្ម ..........................................................................ចំនួន១ច្បាប់<br>6. របាយការណ៍វាយតម្លៃបឋមនៃផលប៉ះពាល់បរិស្ថាន........ចំនួន១ច្បាប់<br>7. លិខិតអង្កេតសុវិជាន និងអសុវិជាន<br>8. វិក័យបត្របញ្ជាក់ការទូទាត់កម្រៃស្នើសុំអាជ្ញាបណ្ណ...........ចំនួន១ច្បាប់<br>**ខ. ព័ត៌មាន**<br>• ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវា<br>• តាមរយៈការបិទផ្សាយនៅ ក្រសួងរ៉ែ និងថាមពល និងតាមវេប-សាយ (Website) របស់ក្រសួងរ៉ែ និងថាមពល ។<br>**គ. ភាពឆ្លើយតប**<br>• យន្តការសម្របសម្រួល និងឆ្លើយតបចំពោះការលំបាករបស់អ្នកប្រើប្រាស់សេវា<br>• តុផ្តល់ព័ត៌មាន និងផ្តល់ប្រឹក្សាយោបល់នៅច្រកចេញ ចូលតែមួយរបស់មន្ទីររ៉ែ និងថាមពល រាជធានី ខេត្ត ដោយមានតុ កៅអ៊ី សំរាប់អង្គុយរង់ចាំ ។<br>• យន្តការសម្របសម្រួលដោយមានមន្ត្រីជួយអន្តរាគមន៍ក្នុងករណីផ្ទុយពីនីតិវិធីនៃការចេញប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រី ។<br>**ឃ. ប្រសិទ្ធិភាព**<br>• អតិថិជនទទួលបាននូវសេវាល្អប្រសើរ ។<br>**ង. ការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា**<br>• មានព័ត៌មាន និងការឆ្លើយតបទៅនឹងបណ្តឹងតវ៉ា<br>• មានវិធានការដោះស្រាយ<br>• មានសេវាកម្មអតិថិជន<br>• ក្រសួង/មន្ទីររ៉ែ និងថាមពលមានប្រអប់សំបុត្រសំរាប់ទទួលព័ត៌មានត្រលប់ |

| | |
|---|---|
| | ឬការរិះគន់ពីអតិថិជន ។ |
| **យោបល់** | • សម្រាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ-ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅមន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត ដែលតំបន់សម្រាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែនោះតាំងនៅ លើកលែងតែបែបបទនៃការ ដាក់ពាក្យសុំ និងការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដែលកំណត់ ក្នុងប្រកាសរបស់ក្រសួងរ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចនៃ ការងាររ៉ែ និងថាមពល ជូនដល់បណ្តាលក្រុង-ស្រុក/ឃុំ-សង្កាត់ នៃខេត្តមួយចំនួន<br>• សម្បទានិកដែលមានអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណនេះជាថ្មី ហួតដល់ជម្រករ៉ែអស់លក្ខណៈសេដ្ឋកិច្ច មកក្រសួងរ៉ែ និងថាមពល តាមរយៈមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ដើម្បីពិនិត្យ និងសម្រេចយ៉ាងហោចណាស់សាបសិប(៣០)ថ្ងៃមុន ផុតសុពលភាពនៃអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដែលកំពុងមាន ។<br>• សម្បទានិកដែលកាន់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ មិនអាចសុំបន្តដាក់បញ្ចាំកែប្រែ ប្រគល់ជូនវិញផ្ទេរសិទ្ធិ ឬបន្តជាមរតកបានឡើយ ។ |

# អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥) ២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្តល់សេវា | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ក្នុងគោលបំណងអនុវត្តន៍ការងារស្វែងរុករក ធ្វើអាជីវកម្មធនធានរ៉ែសំណង់ និងធនធានរ៉ែ ឧស្សាហកម្មណាមួយបម្រើឲ្យការសាងសង់ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃ ហើយជីកយកពីអណ្តូងរ៉ែបើក ឬការដ្ឋានវាយថ្ម ។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ<br>• អនុក្រឹត្យលេខ ០៨ អនក្រ .បក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៥ ស្តីពីការកំនត់គោលការណ៍វិនិយោគលើធនធានរ៉ែគ្រប់ប្រភេទ<br>• អនុក្រឹត្យលេខ១១៣អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មមាត្រា១ នៃអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការកំណត់គោលការណ៍វិនិយោគលើធនធានរ៉ែគ្រប់ប្រភេទ<br>• ប្រកាសលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់<br>• ប្រកាសលេខ៣៤០ឧរថ.អធរ.ប្រក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្តល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ<br>• ប្រកាសលេខ ៥២០ រថ.រស.ប្រកចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណសិប្បកម្ម ធនធានរ៉ែ និងអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ គោលបំណងអាជីវកម្មគ្រួស ខ្សាច់ ដីឥដ្ឋ និងដីល្បាប់<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងសម្រាប់អាជីវកម្ម គ្រួស ខ្សាច់ ដីឥដ្ឋ និងដីល្បាប់ មានសុពលភាពពីរ (០២) ឆ្នាំ ។<br>• ប្រកាសអន្តរក្រសួង លេខៈ ១៩១ ប្រក ប.ស្ត ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច។ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គល |
| ស្តង់ដាសេវា | **ក. ការទទួលសេវា**<br>១- នីតិវិធី<br>• អតិថិជនអាចមកដាក់ពាក្យសុំនៅច្រកចេញ-ចូលតែមួយ របស់ក្រសួងរ៉ែ និងថាមពល<br>• ក្រោយពីអង្គភាពជំនាញពិនិត្យលើសំនុំឯកសារ និងចុះត្រួតពិនិត្យមើល |

| | |
|---|---|
| | ទីតាំង និងការដ្ឋានឃើញថាត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបរិស្ថានរួចហើយក្នុងរយៈពេល៤៥ថ្ងៃ បន្ទាប់ អតិថិជនអាចមកបង់តម្លៃសេវានៃអាជ្ញាប័ណ្ណនៅការិយាល័យគ្រប់គ្រងចំណូលធនធានរ៉ែ នៃអគ្គនាយកដ្ឋានធនធានរ៉ែ ។<br>• តម្លៃសេវាអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់៖<br>+ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ ............១០,០០០, ០០០ រៀល<br>+ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ....................................២០,០០០, ០០០ រៀល<br>• តម្លៃសេវាពន្យារបន្តសុពលភាពនៃអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់៖<br>• + ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល....................................២០,០០០, ០០០ រៀល<br>• តម្លៃសេវាការផ្ទេរសិទ្ធិ នៃអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់៖<br>+ ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ ............១០,០០០, ០០០ រៀល<br>+ ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល......................................៥០,០០០, ០០០ រៀល<br>**ការចុះបញ្ជីអាជ្ញាប័ណ្ណ**<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ គ្រួស ឡាតេរីត ដីឥដ្ឋ .........................................៨០០,០០០រៀល<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងៗទៀត ដែលមានលក្ខណៈប្រហាក់ ប្រហែល ....................................................................១,៥០០,០០០រៀល<br>• សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ..........................................៥០០,០០០រៀល<br>+ ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%)<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ គ្រួស ឡាតេរីត ដីឥដ្ឋ ....................................២,៥០០,០០០រៀល<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងៗទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល ................................................................១៥,០០០,០០០រៀល<br>+ ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០% ឡើងទៅ)<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ គ្រួស ឡាតេរីត ដីឥដ្ឋ ....................................៥,០០០,០០០រៀល<br>• អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងៗទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល ................................................................២៥,០០០,០០០រៀល |
| **តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា** | **ឯកសារសម្រាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មរួមមាន៖** |

1. ពាក្យសុំអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម តាមគំរូពាក្យដែលកំណត់ដោយក្រសួងរ៉ែ និងថាមពល (មានបិទតែម២,០០០ រៀល).............................................................ចំនួន១ច្បាប់
2. ប្រវត្តិរូបសង្ខេប និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម)ចំនួន១ច្បាប់
3. ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម (ដោយមានការបញ្ជាក់ ចម្លងត្រឹមត្រូវតាមច្បាប់ដើម) និង ច្បាប់ចម្លងលក្ខន្តិកៈក្រុមហ៊ុន ....... ................................................ចំនួន១ច្បាប់
4. របាយការណ៍សិក្សាវាយតម្លៃភូគព្ភសាស្ត្រ សក្តានុពលធនធានរ៉ែ និងការសិក្សាសមិទ្ធិលទ្ធភាពសេដ្ឋកិច្ចជម្រករ៉ែ ដោយអ្នកជំនាញខាងភូគព្ភ សាស្ត្រ-រ៉ែ .........................................ចំនួន១ច្បាប់
5. គម្រោងផែនការអាជីវកម្ម និងផលិតកម្ម ដោយរួមមានវិធានការចូលរួមលើកកំពស់ផលប្រយោជន៍សេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន .....................................................................ចំនួន១ច្បាប់
6. របាយការណ៍វាយតម្លៃបឋមនៃផលប៉ះពាល់បរិស្ថាន-សង្គម (និងជលវិទ្យាក្នុងករណីអាជីវកម្មធ្វើនៅក្នុងដងស្ទឹង ទន្លេ បឹងបួរ) និងផែនការការពារបរិស្ថាន-សង្គម និងកិច្ចព្រមព្រៀងសហគមន៍ ក្នុងករណីមានផលប៉ះពាល់ជាមួយសហគមន៍មូលដ្ឋាន ..ចំនួន១ច្បាប់
7. ផែនការ និងគម្រោងប៉ាន់ស្មានថវិកា សម្រាប់ស្តារការដ្ឋានឡើងវិញ ......................................................................ចំនួន១ច្បាប់
8. គម្រោងស្នើផែនការហិរញ្ញប្បទាន..........................ចំនួន១ច្បាប់
9. លិខិតអនុញ្ញាតផ្សេងៗ ចេញដោយស្ថាប័នមានសមត្ថកិច្ចស្រប តាមច្បាប់ជាធរមាន...........................................ចំនួន១ច្បាប់
10. វិក័យប័ត្របញ្ជាក់ការទូទាត់តម្លៃពាក្យស្នើសុំអាជ្ញាប័ណ្ណ ................ .....................................................ចំនួន១ច្បាប់

**ខ. ព័ត៌មាន**

- ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាតាមរយៈការបិតផ្សាយនៅ ក្រសួងរ៉ែ និងថាមពល និងតាមវេបសាយ(Website) របស់ក្រសួងរ៉ែ និងថាមពល ។

**គ. ភាពឆ្លើយតប**

- យន្តការសម្របសម្រួល និងឆ្លើយតបចំពោះការលំបាករបស់អ្នក ប្រើប្រាស់សេវា
- តុផ្តល់ព័ត៌មាន និងផ្តល់ប្រឹក្សាយោបល់នៅលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានធនធានរ៉ែ ដោយមានតុ កៅអ៊ី សំរាប់អង្គុយរង់ចាំ ។
- យន្តការសម្របសម្រួល ដោយមានមន្ត្រីជួយអន្តរាគមន៍ក្នុងករណីផ្ទុយពីនីតិវិធីនៃការចេញប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រី ។

**ឃ. ប្រសិទ្ធិភាព**

- អតិថិជនទទួលបាននូវសេវាល្អប្រសើរ ។

**ង. ការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា (រួមសម្រាប់មួយក្រសួង)**

- មានការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា
- មានវិធានការដោះស្រាយ
- មានសេវាកម្មអតិថិជន
- ក្រសួងមានប្រអប់សំបុត្រសំរាប់ទទួលព័ត៌មានត្រលប់ ឬការរិះគន់ពី

| | |
|---|---|
| | អតិថិជន ។ |
| **យោបល់** | សម្បទានិកដែលមានអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មអាចដាក់ពាក្យសុំពន្យារបន្តរហូតដល់ជម្រករ៉ែ អស់លក្ខណៈសេដ្ឋកិច្ចមកក្រសួងរ៉ែ និងថាមពល ដើម្បីពិនិត្យ និងសម្រេចយ៉ាងហោចណាស់ សាមសិប (៣០)ថ្ងៃមុនផុតសុពលភាពនៃអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ដែលកំពុងមានដោយភ្ជាប់មកនូវៈ<br>1. លិខិតស្នើសុំការពន្យារបន្តអាជ្ញាប័ណ្ណរ៉ែបើក និងការដ្ឋានវាយថ្ម ....................................................................ចំនួន០១ច្បាប់<br>2. របាយការណ៍ស្តីពីលទ្ធផលនៃការស្វែងរុករក និង/ឬការធ្វើអាជីវកម្ម ធនធានរ៉ែដែលបានអនុវត្តក្នុងរយៈពេលអាជ្ញាប័ណ្ណមុន ........................................................................ចំនួន១ច្បាប់<br>3. របាយការណ៍ ស្តីពីការការពារបរិស្ថាននៅក្រៅ និងក្នុងការដ្ឋានរ៉ែ និងការអនុវត្ត កម្មវិធីស្តារឡើងវិញដោយមានការបញ្ជាក់ពីមន្ទីរបរិស្ថានរាជធានី-ខេត្ត............................................ចំនួន០១ច្បាប់<br>4. តុល្យភាពគណនីសំរាប់មូលនិធិស្តារឡើងវិញ និងមូលនិធិបណ្តុះ-បណ្តាល.......................................................ចំនួន ០១ច្បាប់<br>5. របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវសួយសារឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម ........................................................................ចំនួន១ច្បាប់<br>6. ផែនការស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ ផែនការស្តារការដ្ឋានរ៉ែឡើងវិញនិងកម្មវិធីបណ្តុះបណ្តាលសំរាប់រយៈពេលពន្យារបន្ត.........................................................ចំនួន១ច្បាប់ |

# អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥) ២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥) ២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្តល់សេវា | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ក្នុងគោលបំណង់ស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងថ្មសម្អាង។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ<br>• អនុក្រឹត្យលេខ ០៨ អនក្រ .បក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការកំនត់គោលការណ៍វិនិយោគលើធនធានរ៉ែគ្រប់ប្រភេទ<br>• អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មមាត្រា ១ នៃអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីកាកំណត់គោលការណ៍វិនិយោគលើធនធានរ៉ែគ្រប់ប្រភេទ<br>• ប្រកាសលេខ ៣៤០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ឧសភា ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្តល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ<br>• ប្រកាសលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់<br>• អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ មានសុពលភាពមួយ (០១) ឆ្នាំ (ថ្មី ០២ឆ្នាំ)<br>• ប្រកាសលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាកម្មអាជីកម្មរ៉ែ។<br>• ប្រកាសអន្តរក្រសួង លេខ ១៩១ ប្រក ប.ស្ហ ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច។ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | នីតិបុគ្គលឬរូបវន្តបុគ្គលដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ |
| ស្តង់ដាសេវា | **ក. ការទទួលសេវា**<br>១- នីតិវិធី<br>• អតិថិជនអាចដាក់ពាក្យសុំនៅច្រកចេញ-ចូលតែមួយ របស់ក្រសួងរ៉ែ និងថាមពល<br>• ក្រោយពីអង្គភាពជំនាញពិនិត្យលើសំនុំឯកសារនិងចុះត្រួតពិនិត្យមើលទីតាំង និងការដ្ឋានឃើញថាត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបរិស្ថាន រួចហើយក្នុងរយះពេល៤៥ ថ្ងៃបន្ទាប់អតិថិជនអាចមកបង់តម្លៃសេវានៃអាជ្ញាប័ណ្ណនៅការិយាល័យគ្រប់គ្រងចំណូលធនធានរ៉ែ នៃអគ្គនាយដ្ឋានធនធានរ៉ែ ។ |

| | |
|---|---|
| | • តម្លៃសេវាអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្ម មានតម្លៃ ទ្រង់ទ្រាយតូច ...... ................................................................. ១,០០០,០០០ រៀល<br>• តម្លៃសេវាអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្ម មានតម្លៃ ទ្រង់ទ្រាយធំ.......... ............................................................. ១៥,០០០,០០០ រៀល<br>• តម្លៃសេវាការផ្ទេរសិទ្ធិអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្ម មានតម្លៃ ទ្រង់ទ្រាយធំ ............................................ ៥០,០០០,០០០ រៀល<br>• សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ........................................៥០០,០០០រៀល<br>**ការចុះបញ្ជីអាជ្ញាប័ណ្ណ**<br>+ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្ម មានតម្លៃ ទ្រង់ទ្រាយតូច .................. ......................................................................១០០,០០០រៀល<br>+ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្ម មានតម្លៃ ទ្រង់ទ្រាយធំ ..................... ..................................................................៣,០០០,០០០រៀល<br>• ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%)<br>• អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ..........២០,០០០,០០០រៀល<br>• ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០% ឡើងទៅ)<br>• អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ..........២៥,០០០,០០០រៀល |
| **តម្រូវការ ឯកសារដើម្បីទទួលបានសេវា** | • ត្រូវមានការយល់ព្រមពី ក្រសួងរ៉ែ និងថាមពលជាមុនក្នុងការទទួល បានសម្បទានដីសម្រាប់ធ្វើអាជីវកម្មធនធានរ៉ែ<br>• ឯកសារសម្រាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្ម មានតម្លៃ រួមមានៈ<br>1. ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ (មានបិទតែម២,០០រៀល).......... ...............................ចំនួន១ច្បាប់<br>2. ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីនៅអគ្គនាយកដ្ឋានធនធានរ៉ែ .............ចំនួន០១ច្បាប់<br>3. ប្លង់ទីតាំងស្នើសុំ (មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន)...ចំនួន១ច្បាប់<br>4. របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ ឬតុល្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ៣ឆ្នាំរបស់ភាគីទទួលសិទ្ធ ដោយមានបញ្ជាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬសវនកម្មណាដែលបានទទួលសិទ្ធិធ្វើអាជីវកម្ម នៅព្រះរាជាណាចក្រកម្ពុជា...........ចំនួន១ច្បាប់<br>5. កម្មវិធីដស្វែងរុករក /អាជីវកម្មធនធានរ៉ែ និងថវិកាសម្រាប់ចំណាយរបស់ភាគីទទួលសិទ្ធិនៅក្នុងរយៈពេលប្រតិបត្តិការធនធានរ៉ែ..............ចំនួន១ច្បាប់<br>6. ការសិក្សាពីការងារវាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងផែនការស្តារឡើងវិញនិងថវិការបម្រុងសម្រាប់ការស្តារឡើងវិញរបស់ភាគីទទួលសិទ្ធិ...............................ចំនួន១ច្បាប់<br>7. បទពិសោធន៍របស់ក្រុមហ៊ុនក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្ម៣ក់.......................................................ចំនួន១ច្បាប់<br>**ខ. ព័ត៌មាន** |

<table>
<tr>
<td></td>
<td>

- ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាតាមរយៈការបិតផ្សាយនៅក្រសួងរ៉ែ និងថាមពលនិងតាមវេបសាយ(Website)របស់ក្រសួងរ៉ែ និងថាមពល

**គ. ភាពឆ្លើយតប**

- យន្តការសម្របសម្រួល និងឆ្លើយតបចំពោះការលំបាករបស់អ្នកប្រើប្រាស់សេវា
- តុផ្តល់ព័ត៌មាន និងផ្តល់ប្រឹក្សាយោបល់នៅលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានធនធានរ៉ែ ដោយមានតុ កៅអី សំរាប់អង្គុយរង់ចាំ ។
- យន្តការសម្របសម្រួលដោយមានមន្ត្រីជួយអន្តរាគមន៍ក្នុងករណីផ្ទុយពីនីតិវិធីនៃការចេញប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រី ។

**ឃ. ប្រសិទ្ធិភាព**

- អតិថិជនទទួលបាននូវសេវាល្អប្រសើរ ។

**ង. ការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា (រួមសម្រាប់មួយក្រសួង)**

- មានការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា
- មានវិធានការដោះស្រាយ
- មានសេវាកម្មអតិថិជន
- ក្រសួងមានប្រអប់សំបុត្រសំរាប់ទទួលព័ត៌មានត្រលប់ ឬការរិះគន់ពីអតិថិជន ។

</td>
</tr>
<tr>
<td>យោបល់</td>
<td>

- សម្រាប់អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ឬ មានតម្លៃ ទ្រង់ទ្រាយតូច អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណនៅក្រសួរ៉ែ និងថាមពល តាមរយៈមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត
- តម្លៃសេវាអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ឬ មានតម្លៃ ទ្រង់ទ្រាយតូច ...... .................................................................. ១,០០០,០០០ រៀល
- ឯកសារសម្រាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ឬ មានតម្លៃ រួមមានៈ
  1. ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ តាមគំរូពាក្យដែលកំណត់ដោយ ក្រសួងរ៉ែ និងថាមពល (មានបិទតែម ២,០០០រៀល) .......ចំនួន១ច្បាប់
  2. ប្រវត្តិរូបសង្ខេប និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដោយ មានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម...ចំនួន១ច្បាប់
  3. លិខិតទទួលស្គាល់ពីអាជ្ញាធរឃុំ សង្កាត់ លក្ខន្តិកៈសហគមន៍សិប្បកររ៉ែ និងវិញ្ញាបនបត្រ ចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីចងក្រងជាសហគមន៍សិប្បកររ៉ែ) ....................................ចំនួន១ច្បាប់
  4. ឯកសារបញ្ជាក់ប្លង់កម្មសិទ្ធដីស្របច្បាប់ពាក់ព័ន្ធ (ក្នុងករណីប្រតិបត្តិការធនធានរ៉ែស្ថិតនៅក្នុងដីកម្មសិទ្ធិឯកជន).ចំនួន១ច្បាប់
  5. គំពោងសំណើរបច្ចេកទេសអាជីវកម្មរ៉ែ និងផែនការអាជីវកម្ម ............ .........................................................ចំនួន១ច្បាប់
  6. របាយការណ៍វាយតម្លៃបឋមនៃផលប៉ះពាល់បរិស្ថាន..ចំនួន១ច្បាប់
  7. លិខិតអង្កេតសិវិធាន និងអសុវិធាន .......................ចំនួន១ច្បាប់
  8. វិក័យបត្របញ្ជាក់ការទូទាត់កម្រៃពាក្យស្នើសុំអាជ្ញាប័ណ្ណ ........................................................................ចំនួន១ច្បាប់

</td>
</tr>
</table>

# អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥)២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្តល់សេវា | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែក្នុងគោលបំណងកែច្នៃត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ ឬថ្មសំអាង។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ<br>• ប្រកាសលេខ ៣៤០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ឧសភា ២០០៤ ស្តីពីការចុះបញ្ជីនិងលក្ខខណ្ឌនៃការផ្តល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ<br>• ប្រកាសលេខ ០០០២ រថ.អធរ.ប្រក ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៥ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈជាសិប្បកម្មនិងខ្នាតតូច<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ មានសុពលភាពបី (០៣) ឆ្នាំ ។<br>• ប្រកាសលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់<br>• ប្រកាសអន្តរក្រសួង លេខៈ ១៩១ ប្រក ប.ស្ត ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច។ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គល |
| ស្តង់ដាសេវា | **ក. ការទទួលសេវា**<br>១- នីតិវិធី<br>• អតិថិជនអាចដាក់ពាក្យសុំនៅច្រកចេញ-ចូលតែមួយ របស់ក្រសួង រ៉ែ និងថាមពល<br>• ក្រោយពីអង្គភាពជំនាញពិនិត្យលើសំនុំឯកសារ និងចុះត្រួតពិនិត្យមើលទីតាំង និងការដ្ឋានឃើញថា ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបរិស្ថាន រួចហើយក្នុងរយៈពេល៤៥ ថ្ងៃបន្ទាប់ អតិថិជនអាចមកបង់តម្លៃសេវានៃអាជ្ញាប័ណ្ណនៅការិយាល័យគ្រប់គ្រងចំណូលធនធានរ៉ែ នៃអគ្គនាយដ្ឋានធនធានរ៉ែ ។<br>• តម្លៃសេវាអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ សម្រាប់:<br>-កម្លាំងពលកម្មតិចជាង ៧ នាក់....................៣,៦០០, ០០០ រៀល<br>-កម្លាំងពលកម្មពី ៧-១៤ នាក់......................៧,២០០ ,០០០ រៀល<br>-កម្លាំងកម្មលើសពី ១៤នាក់........................១៥,០០០,០០០រៀល<br>• តម្លៃសេវាការផ្ទេរសិទ្ធិអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ សម្រាប់: |

| | |
|---|---|
| | -កម្លាំងពលកម្មតិចជាង ៧ នាក់...................២,៥០០, ០០០ រៀល<br>-កម្លាំងពលកម្មពី ៧-១៤ នាក់.....................៥,០០០ ,០០០ រៀល<br>-កម្លាំងកម្មលើសពី ១៤នាក់.......................៨,០០០,០០០រៀល<br>**ការចុះបញ្ជីអាជ្ញាប័ណ្ណ**<br>• ការអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ..........................៨០០,០០០រៀល<br>• សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ........................................៥០០,០០០រៀល<br>+ ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%)<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧ នាក់ ................................................................១,០០០, ០០០ រៀល<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧-១៤ នាក់ ................................................................១,០០០ ,០០០ រៀល<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងកម្មលើសពី ១៤នាក់ ..................................................................១,០០០,០០០រៀល<br>+ ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០% ឡើងទៅ)<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧ នាក់ ................................................................៥,០០០, ០០០ រៀល<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧-១៤ នាក់ ................................................................៥,០០០ ,០០០ រៀល<br>• អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងកម្មលើសពី ១៤នាក់ ..................................................................៥,០០០,០០០រៀល |
| **តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា** | • ត្រូវមានការយល់ព្រមពីក្រសួងរ៉ែនិងថាមពលជាមុន ក្នុងការទទួលបានសម្បទានដីសម្រាប់ធ្វើអាជីវកម្មធនធានរ៉ែ<br>• ត្រូវចុះកិច្ចព្រមព្រៀងធ្វើអាជីវកម្មកែច្នៃធនធានរ៉ែ ជាមួយក្រសួងរ៉ែ និងថាមពល<br>• ឯកសារសម្រាប់ដាក់ពាក្យសុំ  អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ រួមមានៈ<br>1. ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ(មានបិទតែម២,០០០រៀល) ............................................................ចំនួន១ច្បាប់<br>2. ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីនៅអគ្គនាយកដ្ឋានធនធានរ៉ែ ..................................................................ចំនួន១ច្បាប់<br>3. ប្លង់ទីតាំងស្នើសុំ (មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន)...ចំនួន១ច្បាប់<br>4. បទពិសោធន៍របស់ក្រុមហ៊ុនក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្មពាក់ព័ន្ធ.........................................................ចំនួន១ច្បាប់<br>5. ផែនការជ្រើសរើសពលករកម្ពុជានិងវិធីបណ្តុះបណ្តាល .....................................................................ចំនួន១ច្បាប់<br>**ខ. ព័ត៌មាន**<br>• ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាតាមរយៈការបិតផ្សាយនៅក្រសួងរ៉ែ និងថាមពល និងតាមវេបសាយ(Website) របស់ក្រសួងរ៉ែ និង ថាមពល ។<br>**គ. ភាពឆ្លើយតប** |

| | |
|---|---|
| | • យន្តការសម្របសម្រួល និងឆ្លើយតបចំពោះការលំបាករបស់អ្នកប្រើប្រាស់សេវា<br>• តុផ្តល់ព័ត៌មាននិងផ្តល់ប្រឹក្សាយោបល់នៅលេខាធិការដ្ឋាននៃអគ្គ-នាយកដ្ឋានធនធានរ៉ែ ដោយមានតុ  កៅអ៊ី សំរាប់អង្គុយរង់ចាំ។<br>• យន្តការសម្របសម្រួលដោយមានមន្ត្រីជួយអន្តរាគមន៍ក្នុងករណីផ្ទុយពីនីតិវិធីនៃការចេញប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រី ។<br>**ឃ. ប្រសិទ្ធិភាព**<br>• អតិថិជនទទួលបាននូវសេវាល្អប្រសើរ ។<br>**ង. ការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា (រួមសម្រាប់មួយក្រសួង)**<br>• មានការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា<br>• មានវិធានការដោះស្រាយ<br>• មានសេវាកម្មអតិថិជន<br>• ក្រសួងមានប្រអប់សំបុត្រសំរាប់ទទួលព័ត៌មានត្រលប់ ឬការរិះគន់ពីអតិថិជន ។ |
| **យោបល់** | • រូបវន្តបុគ្គល  ឬនីតិបុគ្គល ដែលមានបំណងដាក់ពាក្យសុំអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវមកដាក់ពាក្យសុំនៅច្រកចេញ-ចូលតែមួយ របស់ក្រសួង រ៉ែ និងថាមពល។<br>• ចំពោះអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ ត្រូវទៅដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅមន្ទីរ៉ែ និងថាមពល រាជធានី-ខេត្ត |

# អាជ្ញាប័ណ្ណស្វែងរុករក

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណស្វែងរុករក |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥)២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្តល់សេវា | អាជ្ញាប័ណ្ណស្វែងរុករកក្នុងគោលបំណង ដើម្បីធ្វើការស្វែងរុករក និងសិក្សាអំពីសក្តានុពលធនធានរ៉ែ។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ<br>• អនុក្រឹត្យលេខៈ  ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាកម្មធនធានរ៉ែ។<br>• ប្រកាសលេខ ៣៤០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ឧសភា ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្តល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ<br>• អាជ្ញាប័ណ្ណស្វែងរុករក មានសុពលភាពបី (០៣) ឆ្នាំ អាចពន្យាបានពីរ (០២) ដង ម្តងបានពីរ (០២) ឆ្នាំ ។<br>• ប្រកាសលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់<br>• ប្រកាសអន្តរក្រសួង លេខៈ ១៩១ ប្រក ប.ស្ក ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច។ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គល |
| ស្តង់ដាសេវា | **ក. ការទទួលសេវា**<br>១- នីតិវិធី<br>• អតិថិជនអាចដាក់ពាក្យសុំនៅច្រកចេញ-ចូលតែមួយ របស់ក្រសួងរ៉ែ និងថាមពល<br>• ក្រោយពីអង្គភាពជំនាញពិនិត្យលើសំនុំឯកសារ និងចុះត្រួតពិនិត្យមើលទីតាំង និងការដ្ឋានឃើញថាត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបរិស្ថាន រួចហើយក្នុងរយៈពេល៤៥ថ្ងៃបន្ទាប់ អតិថិជនអាចមកបង់តម្លៃសេវានៃអាជ្ញាប័ណ្ណនៅការិយាល័យគ្រប់គ្រងចំណូលធនធានរ៉ែ នៃអគ្គនាយដ្ឋានធនធានរ៉ែ ។<br>• តម្លៃសេវានៃអាជ្ញាប័ណ្ណស្វែងរុករក.................២០,០០០,០០០ រៀល<br>• តម្លៃពន្យារបន្តនៃអាជ្ញាប័ណ្ណស្វែងរុករក.......... ២០,០០០,០០០ រៀល<br>• តម្លៃផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្វែងរុករក.......... ១០០,០០០,០០០ រៀល<br>• ការចុះបញ្ជីអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណស្វែងរុករក ......៥,០០០,០០០រៀល<br>• សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត .........................................៥០០,០០០រៀល |

| | |
|---|---|
| | • ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%)<br>• អាជ្ញាប័ណ្ណស្វែងរុករក ..............................៤០,០០០,០០០រៀល<br>• ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០% ឡើងទៅ)<br>• អាជ្ញាប័ណ្ណស្វែងរុករក ..............................៥០,០០០,០០០រៀល |
| **តម្រូវការ ឯកសារដើម្បីទទួលបានសេវា** | • ត្រូវមានការយល់ព្រមពីក្រសួងរ៉ែ និងថាមពលជាមុន ក្នុងការទទួល បានសម្បទានដីសម្រាប់ធ្វើអាជីវកម្មធនធានរ៉ែ ត្រូវចុះកិច្ចព្រមព្រៀង ស្វែងរុករកជាមួយ ក្រសួងរ៉ែ និងថាមពល<br>• ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ត្រូវបំពេញតាមទម្រង់ និងបែបបទដោយមានភ្ជាប់នូវឯកសារព័ត៌មានចាំបាច់ ដូចខាងក្រោម ៖<br>1. សំណើអំពីវិធីសាស្ត្រ កម្មវិធីការងារស្វែងរុករកលម្អិត គម្រោងប៉ាន់ស្មានថវិកា ធនធានជំនាញបច្ចេកទេស និងប្រភពហិរញ្ញប្បទានដែលមាន ដើម្បីអនុវត្តកម្មវិធីដែលស្នើឡើង<br>2. លក្ខន្តិកៈក្រុមហ៊ុន និងលិខិតចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>3. សក្ខីបត្របញ្ជាក់អំពីការបង់កម្រៃទទួលពាក្យសុំអាជ្ញាបណ្ណស្វែងរុករក<br>4. របាយការណ៍សិក្សាវាយតម្លៃបឋម ឬរបាយការណ៍ព័ត៌មាន និងទិន្នន័យដូចមានចែងក្នុងមាត្រា២៤នៃអនុក្រឹត្យនេះ<br>5. របាយការណ៍វាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននិងសង្គមដំបូងនិង<br>6. ឯកសារនិងព័ត៌មានចាំបាច់ផ្សេងៗទៀតតាមការចាំបាច់ និងតាមស្ថានភាពជាក់ស្តែងនីមួយៗតាមការកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។<br>• ទម្រង់និងបែបបទលម្អិត នៃពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។<br>**ខ. ព័ត៌មាន**<br>• ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាតាមរយៈការបិតផ្សាយនៅក្រសួងរ៉ែ និងថាមពល និងតាមវេបសាយ(Website) របស់ក្រសួងរ៉ែ និង ថាមពល ។<br>**គ. ភាពឆ្លើយតប**<br>• យន្តការសម្របសម្រួល និងឆ្លើយតបចំពោះការលំបាករបស់អ្នកប្រើប្រាស់សេវា<br>• តុផ្តល់ព័ត៌មាននិងផ្តល់ប្រឹក្សាយោបល់នៅលេខាធិការដ្ឋាននៃអគ្គ-នាយកដ្ឋានធនធានរ៉ែ ដោយមានតុ កៅអី សំរាប់អង្គុយរង់ចាំ។<br>• យន្តការសម្របសម្រួលដោយមានមន្ត្រីជួយអន្តរាគមន៍ក្នុងករណីផ្ទុយពីនីតិវិធីនៃការចេញប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រី ។<br>**ឃ. ប្រសិទ្ធិភាព**<br>• អតិថិជនទទួលបាននូវសេវាល្អប្រសើរ ។<br>**ង. ការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា (រួមសម្រាប់មួយក្រសួង)**<br>• មានការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា |

| | |
|---|---|
| | • មានវិធានការដោះស្រាយ<br>• មានសេវាកម្មអតិថិជន<br>• ក្រសួងមានប្រអប់សំបុត្រសំរាប់ទទួលព័ត៌មានត្រលប់ ឬការរិះគន់ពី អតិថិជន ។ |
| **យោបល់** | • សម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចសុំពន្យារបន្តរយៈពេលស្វែងរុករកបានពីរ(០២)ដងដោយម្តងៗ មានរយៈពេលពី(០២)ឆ្នាំ<br>• សម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកមកក្រសួងរ៉ែ និងថាមពល ដើម្បីពិនិត្យ និងសម្រេចយ៉ាងហោចណាស់ សាមសិប(៤៥)ថ្ងៃ មុនផុតសុពលភាព នៃអាជ្ញាប័ណ្ណស្វែងរុករកដែលកំពុងមានដោយ ភ្ជាប់មកនូវ ៖<br>1. លិខិតស្នើសុំការពន្យារបន្តអាជ្ញាប័ណ្ណស្វែងរុករក.......ចំនួន១ច្បាប់<br>2. របាយការណ៍ស្តីពីលទ្ធផលនៃការស្វែងរុករកធនធានរ៉ែដែលបានអនុវត្តក្នុងរយៈពេលអាជ្ញាប័ណ្ណមុន........................ចំនួន១ច្បាប់<br>3. របាយការណ៍ ស្តីពីការការពារបរិស្ថាននៅក្រៅ និងក្នុងការដ្ឋានរ៉ែ និងការអនុវត្តកម្មវិធីស្តារឡើងវិញ ដោយមានការបញ្ជាក់ពីមន្ទីរបរិស្ថានរាជធានី-ខេត្ត.......................................ចំនួន០១ច្បាប់<br>4. តុល្យភាពគណនីសំរាប់មូលនិធិស្តារឡើងវិញ និងមូលនិធិបណ្តុះបណ្តាល...............................................ចំនួន០១ច្បាប់<br>5. របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវ សួយសារ ឈ្នួលដី ប្រចាំឆ្នាំ និង ពន្ធអាករ ពាក់ព័ន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម.........................................................ចំនួន១ច្បាប់<br>6. ផែនការស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ ផែនការស្តាការដ្ឋានរ៉ែឡើងវិញ និងកម្មវធីបណ្តុះបណ្តាលសំរាប់រយៈពេលពន្យារបន្ត.......................................................................ចំនួន១ច្បាប់ |

# អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥)២៣-២១៩ ៥៨៤ |
| គោលបំណងនៃការផ្តល់សេវា | អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្នុងគោលបំណងដើម្បីធ្វើការស្វែងរុករកនិងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធិភាពសេដ្ឋកិច្ច ហើយឋិតនៅតែវង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ<br>• អនុក្រឹត្យលេខៈ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាកម្មធនធានរ៉ែ។<br>• អនុក្រឹត្យលេខ ០៨ អនក្រ .បក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការកំនត់គោលការណ៍វិនិយោគលើធនធានរ៉ែ គ្រប់ប្រភេទ<br>• អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មមាត្រា ១ នៃអនុក្រឹត្យលេខ ០៨ អន ក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការកំណត់គោលការណ៍វិនិយោគលើធនធានរ៉ែគ្រប់ប្រភេទ<br>• ប្រកាសលេខ ៣៤០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ឧសភា ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្តល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិ នៃអាជ្ញាប័ណ្ណធនធានរ៉ែ<br>• ប្រកាសលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់<br>• ប្រកាសអន្តរក្រសួង លេខៈ ១៩១ ប្រក ប.ស្ក ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ ២០១៦ ស្តីពីចំណាត់ថ្នាក់ នៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច។<br>• អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ មានសុពលភាពមិនលើស២១ (ម្ភៃមួយ)ឆ្នាំ អាចពន្យាបន្តបាន២(ពីរ)ដង មិនលើសពី១០(ដប់)ឆ្នាំ។ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គល |
| ស្តង់ដាសេវា | **ក. ការទទួលសេវា**<br>១- នីតិវិធី<br>• អតិថិជនអាចដាក់ពាក្យសុំនៅច្រកចេញ-ចូលតែមួយ របស់ក្រសួង រ៉ែ និងថាមពល<br>• ក្រោយពីអង្គភាពជំនាញពិនិត្យលើសំនុំឯកសារ និងចុះត្រួតពិនិត្យមើលទីតាំង និងការដ្ឋានឃើញថា ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបរិស្ថាន រួចហើយក្នុងរយៈពេល ៤៥ ថ្ងៃបន្ទាប់អតិថិជនអាចមកបង់តម្លៃសេវានៃអាជ្ញាប័ណ្ណនៅការិយាល័យគ្រប់គ្រងចំណូលធនធានរ៉ែ នៃអគ្គនាយដ្ឋាន |

| | |
|---|---|
| | ធនធានរ៉ែ ។<br>• តម្លៃសេវានៃអាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច ..............................................................១,០០០,០០០ រៀល<br>• តម្លៃសេវានៃអាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ ................................................................៥០,០០០,០០០ រៀល<br>• តម្លៃពន្យារបន្តនៃអាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ ..............................................៥០,០០០,០០០ រៀល<br>• តម្លៃការផ្ទេរសិទ្ធិ នៃអាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ..........................................២០០,០០០,០០០ រៀល<br>**ការចុះបញ្ជីអាជ្ញាប័ណ្ណ**<br>• អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ .............. ................................................................១៥,០០០,០០០រៀល<br>• អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច ........... .....................................................................១០០,០០០រៀល<br>• សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត .........................................៥០០,០០០រៀល<br>• ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%)<br>• អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ .......១០០,០០០,០០០រៀល<br>• ការចេញលិខិតទទួលស្គាល់ ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០% ឡើងទៅ)<br>• អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ .......១០០,០០០,០០០រៀល |
| **តម្រូវការ ឯកសារដើម្បីទទួលបានសេវា** | • ត្រូវមានការយល់ព្រមពីក្រសួងរ៉ែ និងថាមពលជាមុន ក្នុងការទទួលបានសម្បទានដីសម្រាប់ធ្វើអាជីវកម្មធនធានរ៉ែ ក្នុងករណីរដ្ឋមន្ត្រីយល់ថាចាំបាច់។<br>• ក្នុងករណីរដ្ឋមន្ត្រីយល់ថាចាំបាច់ត្រូវចុះកិច្ចព្រមព្រៀងធ្វើអាជ្ញាប័ណ្ណឧស្សាហកម្មធនធានរ៉ែ ជាមួយក្រសួងរ៉ែ និងថាមពល<br>• ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ត្រូវបំពេញតាមទម្រង់ និងបែបបទដោយមានភ្ជាប់ឯកសារព័ត៌មានចាំបាច់ដូចខាងក្រោម ៖<br>1. សក្ខីបត្របញ្ជាក់អំពីការបង់កម្រៃសេវាទទួលពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ<br>2. គម្រោងផែនការអភិវឌ្ឍការដ្ឋានរ៉ែ<br>3. របាយការណ៍ នៃការសិក្សាសមិទ្ធិលទ្ធភាពលម្អិត រៀបចំដោយអ្នកជំនាញដែលមានគុណវិឌ្ឍិពិតប្រាកដស្របតាមទម្រង់ បែបបទ និងមាតិកា កំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល<br>4. បណ្ណពន្ធប៉ាតង់ឆ្នាំចរន្ត<br>5. របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន<br>6. គម្រោងផែនការអភិវឌ្ឍសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធក្នុងតំបន់អាជីវកម្មធនធានរ៉ែ<br>7. ផែនការបិទការដ្ឋានរ៉ែ និងស្តារបរិស្ថានឡើងវិញ និង |

| | |
|---|---|
| | 8. ឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀតតាមការចាំបាច់ និងតាមស្ថានភាពជាក់ស្តែងនីមួយៗតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។<br>• ទម្រង់បែបបទលម្អិត នៃពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។<br>**ខ. ព័ត៌មាន**<br>• ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាតាមរយៈការបិតផ្សាយនៅក្រសួងរ៉ែ និងថាមពល និងតាមវេបសាយ(Website) របស់ក្រសួងរ៉ែ និង ថាមពល ។<br>**គ. ភាពឆ្លើយតប**<br>• យន្តការសម្របសម្រួល និងឆ្លើយតបចំពោះការលំបាករបស់អ្នកប្រើប្រាស់សេវា<br>• តុផ្តល់ព័ត៌មាននិងផ្តល់ប្រឹក្សាយោបល់នៅលេខាធិការដ្ឋាននៃអគ្គ-នាយកដ្ឋានធនធានរ៉ែ ដោយមានតុ កៅអី សំរាប់អង្គុយរង់ចាំ។<br>• យន្តការសម្របសម្រួលដោយមានមន្ត្រីជួយអន្តរាគមន៍ក្នុងករណីផ្ទុយពីនីតិវិធីនៃការចេញប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រី ។<br>**ឃ. ប្រសិទ្ធិភាព**<br>• អតិថិជនទទួលបាននូវសេវាល្អប្រសើរ ។<br>**ង. ការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា (រួមសម្រាប់មួយក្រសួង)**<br>• មានការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា<br>• មានវិធានការដោះស្រាយ<br>• មានសេវាកម្មអតិថិជន<br>• ក្រសួងមានប្រអប់សំបុត្រសំរាប់ទទួលព័ត៌មានត្រលប់ ឬការរិះគន់ពីអតិថិជន ។ |
| យោបល់ | • អ្នកចុះកិច្ចសន្យាត្រូវដាក់ពាក្យសុំពន្យារបន្តសុពលភាពអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែយ៉ាងហោចណាស់កៅសិប (៩០) ថ្ងៃមុនផុតសុពលភាពនៃអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែ ដែលកំពុងមានហើយត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍បច្ចេកទេស និងគម្រោងផែនការដូចខាងក្រោមមកក្រសួងដើម្បីពិនិត្យ និងសម្រេច។<br>1. របាយការណ៍ស្តីពីលទ្ធផលនៃការជីករ៉ែ និងថវិការចំណាយ ..................................................................ចំនួន១ច្បាប់<br>2. របាយការណ៍ ស្តីពីការប៉ះបរិស្ថាន និងក្នុងការស្តារឡើងវិញ ..................................................................ចំនួន១ច្បាប់<br>3. របាយការណ៍ស្តីពីការជ្រើសរើសពលករកម្ពុជា និងការបណ្តុះបណ្តាល......................................................ចំនួន១ច្បាប់<br>4. របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវសួយសារឈ្នួលដីសម្បទាន សួយសារពន្ធ និងពន្ធដារ ថ្លៃឈ្នួល និងបន្ទុកចំណាយផ្សេងទៀតដោយភ្ជាប់មកជាមួយនូវសេក្តីប័ត្រពាក់ពន្ធ....ចំនួន១ច្បាប់<br>5. តារាងតុល្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ..........ចំនួន១ច្បាប់<br>6. ប្លង់ទីតាំងតំបន់ដែលត្រូវធ្វើអាជីវកម្មរ៉ែ សម្រាប់រយៈពេលពន្យារបន្ត............................................................ចំនួន១ច្បាប់<br>7. ផែនការជីកយករ៉ែ និងថវិការចំណាយសម្រាប់រយៈពេលពន្យារបន្ត.............................................................ចំនួន១ច្បាប់ |

| | |
|---|---|
| | 8. ការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថានផែនការគ្រប់គ្រងផែនការស្តារឡើយវិញ និងថវិការបម្រុងសម្រាប់ការស្តារឡើង ..................................................................ចំនួន១ច្បាប់<br>9. ផែនការជ្រើសរើសពលកររកម្ពុជា និងការបណ្តុះបណ្តាល ..................................................................ចំនួន១ច្បាប់<br>10. ផែនការប្រើប្រាស់ទំនិញ និងសេវាដែលមាននៅកម្ពុជា ..................................................................ចំនួន១ច្បាប់ |

# ការអនុញ្ញាតឱ្យវិនិយោគផលិត-បញ្ជូន/ឬចែកចាយអគ្គិសនី

| | |
|---|---|
| ឈ្មោះសេវា | ការអនុញ្ញាតឱ្យវិនិយោគផលិត-បញ្ជូន/ឬចែកចាយអគ្គិសនី |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខ: ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារ: (៨៥៥)២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្តល់សេវា | ការចេញលិខិតអនុញ្ញាតនេះ ក្នុងគោលបំណងតាមដានសកម្មភាពវិនិយោគផលិត-បញ្ជូន និង/ឬចែកចាយអគ្គិសនី ដើម្បីក្រសួង ឬមន្ទីរមានមូលដ្ឋានក្នុងការរៀបចំ និងគ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់គម្រោងរាជរដ្ឋាភិបាលលើវិស័យអគ្គិសនី និងតម្រូវឱ្យអ្នកវិនិយោគផ្តល់ទិន្នន័យស្ថិតិ និងរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។ |
| មូលដ្ឋានគតិយុត្ត | ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣ និង មាត្រា ៤ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនជាតិខ្មែរ ជនបរទេស នីតិបុគ្គល ឬរូបវន្តបុគ្គល |
| ស្តង់ដាសេវា | • **កម្រិតថ្នាក់ក្រសួង:** មុននឹងក្រសួងផ្តល់លិខិតអនុញ្ញាតឱ្យវិនិយោគ ក្រសួងចេញលិខិតអនុញ្ញាតជាគោលការណ៍រយៈពេល ៦ខែ ឬ ២៤ខែ (អាស្រ័យទំហំវិនិយោគ) ឱ្យអ្នកស្នើសុំ ឬក្រុមហ៊ុនឯកជនធ្វើការសិក្សាលំអិតលើលក្ខណៈបច្ចេកទេសហិរញ្ញវត្ថុ និងបរិស្ថាន ដើម្បីក្រសួងមានមូលដ្ឋានពិនិត្យវាយតម្លៃ និងសម្រេច។<br>• **កម្រិតថ្នាក់មន្ទីរតាមបណ្តាខេត្ត-រាជធានី:** មុននឹងមន្ទីរផ្តល់លិខិតអនុញ្ញាតឱ្យវិនិយោគអាជីវករ ឬក្រុមហ៊ុនឯកជនត្រូវបំពេញឯកសារមួយចំនួនដូចខាងក្រោម (តម្រូវការឯកសារ ដើម្បីផ្តល់លិខិតអនុញ្ញាត)។<br>• រយៈពេលពី ៣០ ថ្ងៃ ដល់ ៤៥ ថ្ងៃ នៃថ្ងៃធ្វើការ តាមទំហំនៃការវិនិយោគ ដើម្បីផ្តល់លិខិតអនុញ្ញាត ឬមិនអនុញ្ញាត បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់។<br>• កម្រៃសេវាបញ្ញត្តិកម្ម (កំពុងរៀបចំប្រកាសអន្តរក្រសួង)។ |
| តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា | **១-កម្រិតថ្នាក់ក្រសួងអានុភាពលើសពី ១២៥ KVA និងបណ្តាញចែកចាយ ចាប់ពី ២២ KV ឡើងទៅ:**<br>• លិខិតវិនិយោគ - ០១ ច្បាប់<br>• ជីវប្រវត្តិសង្ខេប - ០១ ច្បាប់ (របស់អ្នកស្នើសុំ ឬប្រធានក្រុមហ៊ុន)<br>• វិញ្ញាបនបត្រចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរបស់ក្រុមហ៊ុន ឬថតចំលងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន - ០១ ច្បាប់<br>• ឯកសារសិក្សាលំអិត - ០២ ច្បាប់ (បន្ទាប់ពីសិក្សាហើយ)<br>• ការវាយតម្លៃបឋមអំពីផលប៉ះពាល់បរិស្ថាន (បើមាន)<br>• អនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចពិសេស ឬសួនឧស្សាហកម្ម (បើមាន)<br>• បញ្ជីភាគហ៊ុន (បើមាន) - ០១ ច្បាប់<br>**២-កម្រិតថ្នាក់មន្ទីរតាមបណ្តាខេត្ត-រាជធានី អានុភាពក្រោម ១២៥ KVA និងប** |

| | |
|---|---|
| | **ណ្តាញចែកចាយ 0.៤ KV :**<br>• លិខិតសុំវិនិយោគ - ០១ ច្បាប់<br>• ជីវប្រវត្តសង្ខេប - ០១ ច្បាប់ (របស់អ្នកស្នើសុំ ឬប្រធានក្រុមហ៊ុន)<br>• វិញ្ញាបនប័ត្រក្រុមហ៊ុន ឬថតចំលងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន - ០១ ច្បាប់<br>• ប្លង់បណ្តាញ និង/ឬទីតាំងម៉ាស៊ីនអគ្គិសនី - ០១ ច្បាប់<br>• តារាងវាយតម្លៃ - ០១ ច្បាប់<br>• លិខិតអង្កេតសុវិជាន អសុវិជាន…………………………ចំនួន ០១ ច្បាប់<br>• តារាងគម្រោងវិនិយោគ…………………………………..ចំនួន ០១ ច្បាប់<br>• បញ្ជីភាគហ៊ុន (បើមាន)…………………………………ចំនួន ០១ ច្បាប់ |
| **យោបល់** | ក្រោយពីទទួលបានលិខិតអនុញ្ញាតឱ្យវិនិយោគផលិត-បញ្ជូន និង/ឬចែកចាយអគ្គិសនី អ្នកស្នើសុំ ឬក្រុមហ៊ុនឯកជនមានសិទ្ធទៅសុំអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធ្វើអាជីវកម្មផលិត-បញ្ជូន និង/ឬចែកចាយអគ្គិសនី។ |

**ការអនុញ្ញាតឱ្យសិក្សាគម្រោង(ខ្សែបញ្ជូនអគ្គិសនី ស្ថានីយ៍អគ្គិសនីដុតធ្យូងថ្ម ប្រេងឥន្ធនៈ ជីវម៉ាស់ វារីអគ្គិសនី និងថាមពលកកើតឡើងវិញ)**

| | |
|---|---|
| ឈ្មោះសេវា | ការអនុញ្ញាតឱ្យសិក្សាគម្រោង(ខ្សែបញ្ជូនអគ្គិសនី ស្ថានីយ៍អគ្គិសនីដុតធ្យូងថ្ម ប្រេងឥន្ធនៈ ជីវម៉ាស់ វារីអគ្គិសនី និងថាមពលកកើតឡើងវិញ) |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខៈ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារៈ (៨៥៥)២៣-២១៩ ៥៨៤ |
| គោលបំណងនៃការផ្តល់សេវា | ការចេញលិខិតអនុញ្ញាតនេះ ក្នុងគោលបំណង ដើម្បីរៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រថាមពលក្នុងការប្រើប្រាស់ និងការគ្រប់គ្រងវិស័យថាមពលអគ្គិសនីនិងថាមពលផ្សេងៗទៀត ដើម្បីការសិក្សាស្រាវជ្រាវរុករក រៀបចំ និងអនុវត្តផែនការអភិវឌ្ឍវិស័យថាម-ពលដោយជានា និងការពារនូវផលប្រយោជន៍របស់សង្គម។ |
| មូលដ្ឋានគតិយុត្ត | ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣ និង មាត្រា ៤ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ជនជាតិខ្មែរ ជនបរទេស នីតិបុគ្គល ឬរូបវន្តបុគ្គល |
| ស្តង់ដាសេវា | • រយៈពេល ៤៥ ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីផ្តល់លិខិតអនុញ្ញាតឱ្យសិក្សា/អនុស្សារណៈយោគយល់ (MOU) ឬមិនផ្តល់ឱ្យសិក្សា/MOU បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់។<br>• រយៈពេល ២០ ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ការពន្យាពេលលិខិតអនុញ្ញាត/MOU ក្នុងករណីក្រុមហ៊ុនស្នើសុំបន្តការសិក្សា។<br>• ក្រសួងចេញលិខិតអនុញ្ញាតឱ្យសិក្សា/ចុះMOU មានរយៈពេល ៦ ខែ រហូតដល់ ២៤ ខែ (អាស្រ័យទំហំវិនិយោគ) ឱ្យក្រុមហ៊ុនឬអ្នកស្នើសុំ ដើម្បីធ្វើការសិក្សាលម្អិតលក្ខណៈបច្ចេកទេស ហិរញ្ញវត្ថុ និងបរិស្ថាន។<br>• បន្ទាប់ពីបានរបាយការណ៍សិក្សាលម្អិតផ្ញើមកក្រសួងរួចមក ក្រសួងនឹងឆ្លើយតបទៅក្រុមហ៊ុន ដោយទទួលយក ឬមិនទទួលយកលទ្ធផលនៃការសិក្សា។<br>• កម្រៃសេវាៈ មិនគិតថ្លៃ |
| តម្រូវការ ឯកសារដើម្បីទទួលបានសេវា | • លិខិតសុំសិក្សាគម្រោងវិនិយោគ......................................០១ ច្បាប់<br>• ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤x៦ ០១ ច្បាប់ (អ្នកស្នើសុំ ឬប្រធានក្រុមហ៊ុន)<br>• ប្រវត្តិសង្ខេប និងបទពិសោធន៍ទាក់ទងថាមពលរបស់ក្រុមហ៊ុន...០១ ច្បាប់<br>• វិញ្ញាបនបត្រចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរបស់ក្រុមហ៊ុនឬថតចំលងអត្តសញ្ញាណ-ប័ណ្ណ ឬលិខិតឆ្លងដែន ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម........................................................................០១ ច្បាប់<br>• លិខិតបញ្ជាក់អាស័យដ្ឋានក្រុមហ៊ុន ដោយមានការបញ្ជាក់ពីសាលាខេត្ត-រាជធានី |

| | |
|---|---|
| | • ឯកសារសិក្សាលម្អិត……………………០២ ច្បាប់ (បន្ទាប់ពីសិក្សាហើយ)<br>• បញ្ជីភាគហ៊ុន (បើមាន)…………………………………………០១ ច្បាប់ |
| **យោបល់** | ក្រុមហ៊ុន ឬអ្នកស្នើសុំសិក្សាគម្រោងវិនិយោគត្រូវរងចាំការឆ្លើយតបតាមរយៈលិខិតផ្លូវការពីក្រសួងរ៉ែ និងថាមពល ក្នុងការពិនិត្យ និងសម្រេចក្នុងការទទួល ឬមិនទទួលជាគោល-ការណ៍សម្រាប់ការសិក្សា បើសិនឯកភាពជាគោលការណ៍ក្រសួងនឹងបន្តទៅសុំគោល-ការណ៍ឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា និងបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិភាក្សាលម្អិតអំពីបច្ចេកទេសសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបរិស្ថាន របស់គម្រោងដោយប្រើរយៈពេលពី ៦ ខែ ទៅ ២៤ ខែ អាស្រ័យតាមទំហំវិនិយោគគម្រោង ដើម្បីទទួលបាននូវកិច្ចព្រមព្រៀង អនុវត្តគម្រោងទើបមានសិទ្ធទៅសុំអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធ្វើអាជីវកម្មថាមពលអគ្គិសនី។ |

# ការអនុញ្ញាតឱ្យផ្ទេរសិទ្ធការវិនិយោគផលិត-បញ្ជូន និងចែកចាយថាមពលអគ្គិសនី

| | |
|---|---|
| ឈ្មោះសេវា | ការអនុញ្ញាតឱ្យផ្ទេរសិទ្ធការវិនិយោគផលិត-បញ្ជូន និងចែកចាយថាមពល អគ្គិសនី |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល( អគ្គនាយកដ្ឋានធនធានរ៉ែ)<br>• អគារលេខ: ៧៩-៨៩ ផ្លូវប៉ាស្ទ័រ(៥១) សង្កាត់ផ្សារថ្មី(៣) ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: (៨៥៥)២៣-២១៩ ៥៧៤<br>• ទូរសារ: (៨៥៥)២៣-២១៩ ៥៨៤ |
| គោលបំណង នៃការផ្តល់សេវា | ការចេញលិខិតអនុញ្ញាតនេះក្នុងគោលបំណង ដើម្បីត្រួតពិនិត្យ ណែនាំឱ្យប ណ្តាក្រុមហ៊ុន អង្គភាពអគ្គិសនីអនុវត្តតាមផែនការអភិវឌ្ឍវិស័យថាមពល ដោយជានា និងការពារនូវផលប្រយោជន៍របស់ សង្គមក្នុងការផ្គត់ផ្គង់ថាមពល អគ្គិសនីគ្រប់ប្រភេទ។ |
| មូលដ្ឋានគតិយុត្ត | ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣ និង មាត្រា ៤ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនជាតិខ្មែរ ជនបរទេស នីតិបុគ្គល ឬរូបវន្តបុគ្គល |
| ស្តង់ដាសេវា | • រយៈពេល ២០ ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីផ្តល់លិខិតអនុញ្ញាតឱ្យផ្ទេរសិទ្ធ ឬមិន ផ្តល់ឱ្យផ្ទេរ បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់។<br>• កម្រៃសេវាបញ្ញត្តិកម្ម (កំពុងរៀបចំប្រកាសអន្តរក្រសួង) |
| តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា | • លិខិតសុំផ្ទេរសិទ្ធគម្រោងវិនិយោគ……………………………០១ ច្បាប់<br>• ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤x៦ (អ្នកស្នើសុំ ឬប្រធានក្រុមហ៊ុន)....... ០១ ច្បាប់<br>• ប្រវត្តិសង្ខេប និងបទពិសោធន៍ទាក់ទងថាមពលរបស់ក្រុមហ៊ុន...០១ ច្បាប់<br>• វិញ្ញាបនបត្រចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរបស់ក្រុមហ៊ុន ឬថតចំលងអត្ត សញ្ញាណប័ណ្ណឬលិខិតឆ្លងដែន ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាម ច្បាប់ដើម ០១ ច្បាប់<br>• លិខិតបញ្ជាក់អាស័យដ្ឋានក្រុមហ៊ុន ដោយមានការបញ្ជាក់ពីសាលាខេត្ត-រាជធានី<br>• កិច្ចសន្យាផ្ទេរសិទ្ធ ដោយមានការឯកភាពពីភាគីទាំងពីរ.............០១ ច្បាប់ |
| យោបល់ | ក្រុមហ៊ុន ឬអ្នកស្នើសុំផ្ទេរសិទ្ធគម្រោងវិនិយោគ ត្រូវរងចាំការឆ្លើយតបតាមរយៈ លិខិតផ្លូវការពីក្រសួងរ៉ែ និងថាមពល ក្នុងការពិនិត្យ និងសម្រេចក្នុងការ អនុញ្ញាតឱ្យផ្ទេរ ឬមិនអនុញ្ញាតឱ្យផ្ទេរ ទើបមានសិទ្ធទៅសុំអាជ្ញាប័ណ្ណពីអាជ្ញាធរ អគ្គិសនីកម្ពុជា ដើម្បីធ្វើអាជីវកម្មថាមពលអគ្គិសនី។ |

# លិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយប្រេងឥន្ធនៈ

| | |
|---|---|
| ឈ្មោះសេវា | លិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយប្រេងឥន្ធនៈ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែនិងថាមពល<br>អគ្គនាយកដ្ឋានប្រេងកាត<br>នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខ ថាមពល |
| គោលបំណង នៃការផ្តល់សេវា | ធានាថាបុគ្គលដែលបង្កើតស្ថានីយប្រេងឥន្ធនៈ នៅព្រះរាជាណាចក្រកម្ពុជា ស្របតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាព ឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងបរិស្ថានល្អ ដើម្បីកាត់បន្ថយនូវឧបទ្ទវហេតុនានា ដែលកើតមានឡើងដោយ ថាហេតុ។ |
| មូលដ្ឋានគតិយុត្ត | • ប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និង ថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពបង្កើតស្ថានីយប្រេងឥន្ធនៈ<br>• ប្រកាសអន្តរក្រសួង រវាងក្រសួងរ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការកំណត់កម្រៃសេវាសាធារណៈចំពោះការផ្តល់លិខិតបញ្ជាក់អនុលោមភាពបច្ចេកទេសបង្កើតស្ថានីយប្រេងឥន្ធនៈវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេង ឥន្ធនៈ ការបន្តសុពលភាពនៃវិញ្ញាបនបត្រ អនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ និង លិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬ នីតិបុគ្គល |
| ស្តង់ដាសេវា | • រយៈពេល៖ ៤០ ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការផ្តល់សេវានេះ<br>• កម្រៃសេវា៖ ២ ០០០ ០០០រៀល<br>• សុពលភាព៖ អចិន្ត្រៃយ៍ |
| តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា | 1. ពាក្យស្នើសុំលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយប្រេងឥន្ធនៈ.............................................០១ច្បាប់<br>2. ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន.....០១ ច្បាប់<br>3. ច្បាប់ចម្លងលក្ខន្តិកៈ និង វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ករណីនីតិបុគ្គល)............................................០១ ច្បាប់<br>4. ផែនទីបង្ហាញទីតាំងស្ថានីយប្រេងឥន្ធនៈដែលត្រូវបង្កើត០១ ច្បាប់<br>5. គំនូសប្លង់ស្ថាបត្យកម្ម និង ប្លង់គ្រឿងបង្គុំសំណង់ស្ថានីយប្រេងឥន្ធនៈ.....................................................០១ ច្បាប់<br>6. រូបថត ៤x៦ របស់ម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន...០៣ សន្លឹក |
| យោបល់ | ការផ្តល់សេវានេះ ជាបទដ្ឋានគតិយុត្តសំខាន់មួយសម្រាប់ឈានទៅរកការគ្រប់គ្រងអាជីវកម្មស្ថានីយប្រេងឥន្ធនៈ ឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងបរិស្ថានល្អ ដើម្បីកាត់បន្ថយនូវឧបទ្ទវហេតុនានា ដែលកើតមានឡើងដោយ ថាហេតុ។ |

## I . ការផ្តល់ និងបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## II. ការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

| | |
|---|---|
| **ឈ្មោះសេវា** | I. ការផ្តល់ និងបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ<br>II. ការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | ក្រសួងរ៉ែ និងថាមពល<br>អគ្គនាយកដ្ឋានប្រេងកាត<br>នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខ ថាមពល |
| **គោលបំណងនៃការផ្តល់សេវា** | ជានាថាបុគ្គលដែលប្រតិបត្តិការស្ថានីយប្រេងឥន្ធនៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាព ឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងបរិស្ថានល្អ ដើម្បីកាត់បន្ថយនូវឧបទ្ទវហេតុនានា ដែលកើតមានឡើងជាយថាហេតុ។ |
| **មូលដ្ឋានគតិយុត្ត** | • ប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និង ថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពបង្កើតស្ថានីយប្រេងឥន្ធនៈ<br>• ប្រកាសអន្តរក្រសួង រវាងក្រសួងរ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់កម្រៃសេវាសាធារណៈចំពោះការផ្តល់លិខិតបញ្ជាក់អនុលោមភាពបច្ចេកទេសបង្កើតស្ថានីយប្រេងឥន្ធនៈ វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ការបន្តសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ និងលិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | រូបវន្តបុគ្គល ឬ នីតិបុគ្គល |
| **ស្តង់ដាសេវា** | • រយៈពេល៖ ៤០ ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការផ្តល់សេវានេះ<br>• កម្រៃសេវា៖ ២០០០ ០០០រៀល<br>• សុពលភាព៖ ០២ឆ្នាំ |
| **តម្រូវការ ឯកសារដើម្បីទទួលបានសេវា** | **I. វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ**<br>(១). ចំពោះស្ថានីយប្រេងឥន្ធនៈដែលបានចាប់ផ្តើមសាងសង់ ក្រោយ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ នៃសារាចរលេខ ៤៦៥ រថ.អប្រក.សរច ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ៖<br>1. ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ (ទម្រង់ ក)........................................................០១ ច្បាប់<br>2. ច្បាប់ចម្លងលិខិតវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពីក្រសួងបរិស្ថាន (ចំពោះស្ថានីយមានសមត្ថភាពផ្ទុកបរិមាណប្រេងឥន្ធនៈចាប់ពី ២០,០០០ លីត្រឡើង)..........................................០១ ច្បាប់<br>3. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ ពីមន្ទីរ ឬ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់............................០១ ច្បាប់<br>4. ច្បាប់ចម្លងលិខិតបញ្ជាក់អនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី ..........................................................................០១ ច្បាប់<br>5. ច្បាប់ចម្លងលិខិតបញ្ជាក់អំពីបច្ចេកទេសបង្ការ និងពន្លត់អគ្គិភ័យពី |

| | |
|---|---|
| | ការិយាល័យនគរបាល បង្ការ និងពន្លត់អគ្គិភ័យ រាជធានីខេត្ត<br>...........................................................................០១ ច្បាប់<br>6. រូបថត ៤x៦ របស់ម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន...០៣ សន្លឹក<br>(២). ចំពោះស្ថានីយប្រេងឥន្ធនៈដែលបានចាប់ផ្តើមសាងសង់ មុនថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ នៃសារាចរលេខ ៤៦៥ រថ.អប្រក.សរចស្តីពីសុវត្ថិភាព សម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ៖<br>1. ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ (ទម្រង់ ខ)..........................................................០១ ច្បាប់<br>2. ផែនទីបង្ហាញទីតាំងស្ថានីយប្រេងឥន្ធនៈ.....................០១ ច្បាប់<br>3. គំនូសប្លង់ស្ថាបត្យកម្ម និង ប្លង់គ្រឿងបង្គុំសំណង់ស្ថានីយប្រេងឥន្ធនៈ.................................................................០១ ច្បាប់<br>4. ច្បាប់ចម្លងលិខិតវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពីក្រសួងបរិស្ថាន (ចំពោះស្ថានីយ មានសមត្ថភាពផ្ទុកបរិមាណប្រេងឥន្ធនៈចាប់ពី ២០,០០០ លីត្រឡើង) .......................................០១ ច្បាប់<br>5. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ ពីមន្ទីរ ឬ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់............................០១ ច្បាប់<br>6. ច្បាប់ចម្លងលិខិតបញ្ជាក់អនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី<br>...........................................................................០១ ច្បាប់<br>7. ច្បាប់ចម្លងលិខិតបញ្ជាក់អំពីបច្ចេកទេសបង្ការ និងពន្លត់អគ្គិភ័យពីការិយាល័យនគរបាលបង្ការ និងពន្លត់អគ្គិភ័យរាជធានី ខេត្ត<br>...........................................................................០១ ច្បាប់<br>8. រូបថត ៤x៦ របស់ម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន...០៣ សន្លឹក<br>វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានសុពលភាព ០២ (ពីរ) ឆ្នាំ។ ម្ចាស់ស្ថានីយប្រេងឥន្ធនៈ ត្រូវមកដាក់ពាក្យស្នើសុំបន្ត សុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ មុនពេលផុតកំណត់សុពលភាព។<br>**II. ការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ**<br>1. ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ............................................................០១ ច្បាប់<br>2. រូបថតម្ចាស់ស្ថានីយប្រេងឥន្ធនៈ ឬ ប្រធានក្រុមហ៊ុន ៤x៦ ចំនួន<br>...........................................................................០៣ សន្លឹក<br>3. ច្បាប់ចម្លងវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ដែលផុតសុពលភាព................................................០១ ច្បាប់ |
| **យោបល់** | ការផ្តល់សេវានេះជាបទដ្ឋានគតិយុត្តសំខាន់មួយសម្រាប់ឈានទៅកេការគ្រប់គ្រងអាជីវកម្មស្ថានីយប្រេងឥន្ធនៈ ឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និង សុវត្ថិភាព ដើម្បីកាត់បន្ថយនូវឧបទ្ទវហេតុនានា ដែលកើតមានឡើងដោយថាហេតុ។ |

# លិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ

| | |
|---|---|
| ឈ្មោះសេវា | លិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល<br>អគ្គនាយកដ្ឋានប្រេងកាត<br>នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខ ថាមពល |
| គោលបំណង នៃការផ្តល់សេវា | ជានាថាបុគ្គលដែលកែសម្រួលស្ថានីយប្រេងឥន្ធនៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាព ឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងបរិស្ថានល្អ ដើម្បីកាត់បន្ថយនូវឧបទ្ទវហេតុនានា ដែលកើតមានឡើងដោយថាហេតុ។ |
| មូលដ្ឋានគតិយុត្ត | • ប្រកាសលេខ ០០៩២ រ៉េ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និង ថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពបង្កើតស្ថានីយប្រេងឥន្ធនៈ<br>• ប្រកាសអន្តរក្រសួង រវាងក្រសួងរ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់កម្រៃសេវាសាធារណៈចំពោះការផ្តល់លិខិតបញ្ជាក់អនុលោមភាពបច្ចេកទេសបង្កើតស្ថានីយប្រេងឥន្ធនៈ វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេង ឥន្ធនៈការបន្តសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ និងលិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬ នីតិបុគ្គល |
| ស្តង់ដាសេវា | • រយៈពេល៖ ៤០ ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការផ្តល់សេវានេះ<br>• កម្រៃសេវា៖ ២ ០០០ ០០០រៀល<br>• សុពលភាព៖ អចិន្ត្រៃយ៍ |
| តម្រូវការ ឯកសារ ដើម្បីទទួលបានសេវា | 1. ពាក្យស្នើសុំធ្វើការកែសម្រួលស្ថានីយ.........................០១ ច្បាប់<br>2. គំនូសប្លង់ស្ថាបត្យកម្ម និងប្លង់គ្រឿងបង្គុំសំណង់ស្ថានីយ (ប្រសិនមានការកែសម្រួល)..............................................០១ ច្បាប់ |
| យោបល់ | ការផ្តល់សេវានេះ ជាបទដ្ឋានគតិយុត្តសំខាន់មួយសម្រាប់ឈានទៅរកការគ្រប់គ្រងអាជីវកម្មស្ថានីយប្រេងឥន្ធនៈ ឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងសុវត្ថិភាព ដើម្បីកាត់បន្ថយនូវឧបទ្ទវហេតុនានា ដែលកើតមានឡើងដោយថាហេតុ។ |

## លិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ

| | |
|---|---|
| ឈ្មោះសេវា | លិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងរ៉ែ និងថាមពល<br>អគ្គនាយកដ្ឋានប្រេងកាត<br>នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខ ថាមពល |
| គោលបំណងនៃការផ្តល់សេវា | ដើម្បីឲ្យការគ្រប់គ្រងអាជីវកម្មស្ថានីយប្រេងឥន្ធនៈ នៅព្រះរាជាណាចក្រកម្ពុជាមានប្រសិទ្ធិភាព។ |
| មូលដ្ឋានគតិយុត្ត | • ប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និង ថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពបង្កើតស្ថានីយប្រេងឥន្ធនៈ<br>• ប្រកាសអន្តរក្រសួងរវាងក្រសួងរ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់កម្រៃសេវាសាធារណៈចំពោះការផ្តល់លិខិតបញ្ជាក់អនុលោមភាពបច្ចេកទេសបង្កើតស្ថានីយប្រេងឥន្ធនៈ វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេង ឥន្ធនៈ ការបន្តសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ និង លិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬ នីតិបុគ្គល |
| ស្តង់ដាសេវា | • រយៈពេល៖ ១០ ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការផ្តល់សេវានេះ<br>• កម្រៃសេវា៖ ១ ១០០ ០០០រៀល<br>• សុពលភាព៖ អចិន្ត្រៃយ៍ |
| តម្រូវការ ឯកសារដើម្បីទទួលបានសេវា | 1. ពាក្យស្នើសុំធ្វើការផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ ...........០១ ច្បាប់<br>2. ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ម្ចាស់ថ្មី) .........................................................................០១ ច្បាប់<br>3. ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ករណីនីតិបុគ្គល)..........................................................០១ ច្បាប់<br>4. រូបថត ៤x៦ របស់ម្ចាស់ស្ថានីយ..............................០៣ សន្លឹក |
| យោបល់ | ការផ្តល់សេវានេះ ជាបទដ្ឋានគតិយុត្តសំខាន់មួយសម្រាប់ឈានទៅរកការគ្រប់គ្រងអាជីវកម្មស្ថានីយប្រេងឥន្ធនៈ ឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព។ |

# ក្រសួងឧស្សាហកម្ម និងសិប្បកម្ម


អគារលេខ ៤៥ មហាវិថីព្រះនរោត្តម, សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣)២១០ ៣៥៧

# ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ

| | |
|---|---|
| ឈ្មោះសេវា | ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| គោលបំណង នៃការផ្តល់សេវា | បង្កឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រដែលត្រឹមត្រូវ សុក្រឹតជានិរន្ត និងធានា ប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យមាត្រាសាស្ត្រ និងយុត្តិធម៌សង្គម |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា<br>• អនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ប្រកាសលេខ ១៨១ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ<br>• ប្រកាសរួមលេខ ៧១៧ សហវ.ប្រក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការ ផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ប្រជាជនកម្ពុជា ជនបរទេស ក្រុមហ៊ុនរោងចក្រ សហគ្រាស សិប្បកម្ម |
| ស្តង់ដាសេវា | • រយៈពេលៈ ចេញភ្លាម សុពលភាព ១ឆ្នាំ (សំរាប់ដៃបាញ់ប្រេងឥន្ទនៈ និងជញ្ជីងមេកានិច តិចជាង ១000គីឡូក្រាម)<br>• រយៈពេលផ្តល់ ៩ ថ្ងៃ សុពលភាព ១ឆ្នាំ (ជញ្ជីងស្ពានទម្ងន់លើសពី៤០ តោន)<br>• កម្រៃសេវាៈ<br>- ដៃបាញ់ប្រេងឥន្ទនៈ ៤០.000រៀល<br>- ជញ្ជីងមេកានិច តិចជាង ១000គីឡូក្រាមៈ ១០.000រៀល<br>- ជញ្ជីងស្ពាន ទម្ងន់លើសពី ៤០ តោនៈ ២.០៦០.000រៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ពាក្យស្នើសុំមួយច្បាប់ និងឯកសារភ្ជាប់៖<br>• អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកស្នើសុំ |
| យោបល់ | |

# ការចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា

| | |
|---|---|
| ឈ្មោះសេវា | ការចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | វិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• អគារលេខ ៥៣៨ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ - កម្ពុជា<br>• ទូរស័ព្ទលេខ ៖ ៨៥៥-២៣-៤២៥ ៤៣១<br>• អ៊ីមែល ៖ camtbt-info@isc.gov.kh<br>• គេហទំព័រ: www.isc.gov.kh |
| គោលបំណង នៃការផ្តល់សេវា | ដើម្បីបញ្ជាក់ថា ផលិតផលមួយបានអនុលោមតាមស្តង់ដារកម្ពុជា ដែលធានាបាននូវគុណភាព សុវត្ថិភាព សុខុមាលភាពសាធារណៈ ការការពារបរិស្ថាន។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីស្តង់ដារកម្ពុជា<br>• អនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ប្រកាសលេខ ១០៤៥ ឧរថ.បឧ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការ បិទស្លាកលើផលិតផលចំណីអាហារ<br>• ប្រកាសលេខ ៩៦៣ ឧរថ.នប.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីអំពី ការការចុះបញ្ជីផលិតផលឧស្សាហកម្ម<br>• ប្រកាសលេខ ៦២១ ឧរថ.សឧក.ប្រក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ស្តីពី លក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល<br>• ប្រកាសរួមលេខ៧១៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការ ផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ពលរដ្ឋកម្ពុជា ជនបរទេស ក្រុមហ៊ុនអាជីវកម្ម-ផលិតកម្មនានា |
| ស្តង់ដាសេវា | • រយៈពេល ៥ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីផ្តល់អាជ្ញាប័ណ្ណជូន<br>• តម្លៃសេវា: 300 000រៀល(បីរយពាន់រៀល) |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ពាក្យស្នើសុំមួយច្បាប់<br>• ប្រកាសអនុញ្ញាតបើកមូលដ្ឋានផលិតកម្មរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>• វិញ្ញាបនបត្រដំណើរការរោងចក្រ សិប្បកម្ម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• អាជ្ញាប័ណ្ណចុះបញ្ជីបើកក្រុមហ៊ុន របស់ក្រសួងពាណិជ្ជកម្ម(ដែលមាន សុពលភាព)<br>• អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកស្នើសុំ(ដែលមានសុពលភាព)<br>• លិខិតយោងនិងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងប្រព័ន្ធផលិតកម្ម ឬ អាជីវកម្មរបស់ក្រុមហ៊ុន-រោងចក្រ<br>• របាយការណ៍តេស្ត ឬ វិញ្ញាបនបត្រធ្វើតេស្ត របស់មន្ទីរពិសោធន៍ក្នុង និង ក្រៅប្រទេសណាមួយដែលវិទ្យាស្ថានស្តង់ដារកម្ពុជាទទួលស្គាល់<br>• ឯកសារបច្ចេកទេសពាក់ព័ន្ធសម្រាប់យោង |

| | |
|---|---|
| **យោបល់** | ផ្អែកលើមូលដ្ឋានគតិយុត្តិខាងលើ ដើម្បីឱ្យផលិតផលមួយទទួលបាននូវគុណភាព សុវត្ថិភាព ការពារសុខុមាលភាព មនុស្ស សត្វ និងបរិស្ថាន និងផ្តល់នូវភាពជឿ ជាក់ពីអ្នកប្រើប្រាស់ ថាជាផលិតផលមានគុណភាព និងសុវត្ថិភាព មិនប៉ះពាល់ សុខភាពមនុស្ស សត្វ និងបរិស្ថាន។ |

## ប្រកាសបង្កើតសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងចុះបញ្ជីសិប្បកម្ម

| | |
|---|---|
| ឈ្មោះសេវា | ប្រកាសបង្កើតសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងចុះបញ្ជីសិប្បកម្ម |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**<br>• អគារលេខ ៤៥ មហាវិថីព្រះនរោត្តម, សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>• ទូរស័ព្ទលេខ: (៨៥៥-២៣)២១០ ៣៥៧<br>• នាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និង នាយកដ្ឋានកិច្ចការសិប្បកម្ម |
| គោលបំណងនៃការផ្តល់សេវា | ការចេញប្រកាសនិងបង្កើតសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងចុះបញ្ជីសិប្បកម្ម ដើម្បីធ្វើការគ្រប់គ្រងសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ក្នុងគោលបំណងគ្រប់គ្រងសកម្មភាពផលិតកម្ម-អាជីវកម្ម ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម សំដៅធានាការបង្កើត និងដំណើរការសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម បានប្រព្រឹត្តទៅប្រកបដោយ ការទទួលខុសត្រូវសង្គម បរិស្ថាន និងការការពារសុខមាលភាពសាធារណៈ ស្របតាមបទប្បញ្ញត្ត ច្បាប់ និងសម្រាប់ធ្វើជាមូលដ្ឋានដល់ការរៀបចំគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម<br>• ច្បាប់ ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម<br>• ប្រកាសរួមលេខ ៧១៧ សហវ.ប្រក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការ ផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| អតិថិជនដែលមានសិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គល |
| ស្តង់ដាសេវា | • មានរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដាក់ពាក្យស្នើសុំត្រូវបានចុះបញ្ជីចូលនិងទទួលមកពិនិត្យសម្រេច។<br>• សុពលភាពអចិន្ត្រៃយ៍<br>• តម្លៃសេវាក្នុងការផ្តល់ប្រកាសបង្កើតសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងចុះបញ្ជីសិប្បកម្ម៖<br>• ការចុះបញ្ជីសិប្បកម្ម (ដើមទុនតិចជាងឬស្មើ ៥០,០០០ដុល្លារ ស្មើនឹង ១៥០,០០០រៀល<br>• ប្រកាសបង្កើតសិប្បកម្ម (ដើមទុនតិចជាងឬស្មើ ៥០,០០០ដុល្លារ ស្មើនឹង ១៥០,០០០រៀល<br>• ប្រកាសបង្កើតសហគ្រាសធុនតូច (ដើមទុនលើសពី ៥០,០០០ដុល្លារ ដល់ ២៥០,០០០ដុល្លារ) ស្មើនឹង ៣០០,០០០រៀល<br>• ប្រកាសបង្កើតសហគ្រាសធុនមធ្យម (ដើមទុនលើសពី ២៥០,០០០ដុល្លារ ដល់ ៥០០,០០០ដុល្លារ) ស្មើនឹង ៥០០,០០០រៀល |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • ពាក្យសុំបង្កើត និងតារាងព័ត៌មានបច្ចេកទេស<br>• គោលការណ៍ឯកភាពចំពោះការវិនិយោគ (បើសិនជាគម្រោងវិនិយោគ)<br>• វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (បើសិនម្ចាស់រោងចក្រជានីតិបុគ្គល)<br>• លិខិតយល់ព្រមលើទីតាំងពីអាជ្ញាធរដែនដី |

| | |
|---|---|
| | • តារាងវាយតំលៃបឋមអំពីផលប៉ះពាល់បរិស្ថាន (បើសិនជាគម្រោងតម្រូវឲ្យធ្វើការវាយតំលៃផលប៉ះពាល់បរិស្ថាន)<br>• ប្លង់បង្ហាញទីតាំង ប្លង់រួម ប្លង់អគារ ប្លង់ទីតាំងគ្រឿងចក្រ និងគំនូសបំព្រួញនៃខ្សែសង្វាក់ផលិតកម្ម ក្នុងកិច្ចដំណើរការ<br>• ច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនម្ចាស់សហគ្រាស<br>• រូបថតម្ចាស់សហគ្រាស ៤x៦ ចំនួន ០២សន្លឹក<br>• ឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធក្នុងករណីចាំបាច់ |
| **យោបល់** | |

# ប្រកាសបង្កើតរោងចក្រ

| | |
|---|---|
| ឈ្មោះសេវា | ប្រកាសបង្កើតរោងចក្រ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**<br>• អគារលេខ ៤៥ មហាវិថីព្រះនរោត្តម, សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>• ទូរស័ព្ទលេខ: (៨៥៥-២៣)២១០ ៣៥៧<br>• នាយកដ្ឋានកិច្ចការឧស្សាហកម្ម |
| គោលបំណង នៃការផ្តល់សេវា | ការចេញប្រកាសនិងបង្កើតរោងចក្រ ដើម្បីធ្វើការគ្រប់គ្រងរោងចក្រ ក្នុងគោលបំណង គ្រប់គ្រងសកម្មភាពផលិតកម្ម-អាជីវកម្ម ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម សំដៅធានាការបង្កើត និងដំណើរការរោងចក្រ បានប្រព្រឹត្តទៅប្រកបដោយការទទួលខុសត្រូវសង្គមបរិស្ថាន និងការការពារសុខមាលភាពសាធារណៈ ស្របតាមបទប្បញ្ញត្ត ច្បាប់ និងសម្រាប់ធ្វើជាមូលដ្ឋានដល់ ការរៀបចំគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម។ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម<br>• ច្បាប់ ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម<br>• ប្រកាសរួមលេខ ៧១៧ សហវ.ប្រក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការ ផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គល |
| ស្តង់ដាសេវា | • មានរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដាក់ពាក្យស្នើសុំប្រកាសបង្កើតរោងចក្រ។<br>• សុពលភាពអចិន្ត្រៃយ៍<br>• តម្លៃសេវាក្នុងការផ្តល់ប្រកាសបង្កើតរោងចក្រ (ដើមទុនលើសពី ៥០០,០០០ ដុល្លារ) តម្លៃសេវា ២,០០០,០០០ រៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ១-ពាក្យសុំបង្កើតរោងចក្រថ្មី ឬពាក្យស្នើសុំវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា (បើមាន)<br>២-លិខិតឯកភាពឱ្យវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (បើមាន)<br>៣-លិខិតចុះបញ្ជីក្រសួងពាណិជ្ជកម្ម (បើមាន)<br>៤-លិខិតប្រកាសដាក់ឈ្មោះរោងចក្រ<br>៥-លិខិតបញ្ជាក់លើទីតាំងពីអាជ្ញាធរដែនដី (បើមាន)<br>៦-លក្ខន្តិកៈក្រុមហ៊ុន (បើមាន)<br>៧-សៀវភៅគម្រោងសិក្សាសមិទ្ធិលទ្ធភាពបង្កើតរោងចក្រ (បើមាន)<br>៨-កិច្ចសន្យាជួលទីតាំងរោងចក្រ (បើមាន)<br>៩-ប្លង់បង្ហាញទីតាំង និងប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន (មាត្រា១៨នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ)<br>១០-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ម្ចាស់រោងចក្រ (ថតចម្លង)<br>១១-រូបថតម្ចាស់រោងចក្រ(៤×៦)៣សន្លឹក |
| យោបល់ | |

# ក្រសួងការពារជាតិ


មហាវិថីសហព័ន្ធរុស្សី កាច់ជ្រុងផ្លូវ ១៧៥ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៨៨៣ ១៨៤ / ៤២៨ ១៧១

ទូរសារ ៖ ០២៣ ៨៨៣ ១៨៤

អ៊ីម៉ែល ៖ info@mod.gov.kh

គេហទំព័រ ៖ http://www.mod.gov.kh

# សេវាអប់រំបន្សាបសារធាតុគ្រឿងញៀន

| | |
|---|---|
| **ឈ្មោះសេវា** | សេវាអប់រំបន្សាបសារធាតុគ្រឿងញៀន |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | **ក្រសួងការពារជាតិ**<br>• កងរាជអាវុធហត្ថ ខេត្តបាត់ដំបង<br>- អាសយដ្ឋាន ៖ ផ្លូវលេខ៣ភូមិកម្មករសង្កាត់ស្វាយ ប៉ោក្រុងបាត់ដំបង ខេត្តបាត់ដំបង<br>- ទូរស័ព្ទលេខ ៖ ០១៦ ៥០០១៦៣ **/** ០៩៧ ៧៧៧ ៧៧ ៨២ **/** FREE ( ៥៤៣ ) / ០៩៧ ៩៨៥ ៥៨ ០២ / ០១៦ ៩៩៤ ៨៤៨ /០១៦ ៩៧ ៧៩ ៧៩ ០១២ /៨២៣ ៦៦៨<br>• កងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ<br>- អាសយដ្ឋាន ៖ ភូមិគោរដ្ឋានសង្កាត់អូរអំបិល ក្រុងសេរីសោភ័ណ<br>- ទូរស័ព្ទលេខ ៖ ០៩៧ ៧៧៧ ៧៧ ៨២ **/ FREE (**៥៣១ ) ០៩៧ ៩៩៨ ៣១ ២៣ / ០១២ /០១៥ ៩៩៨៩៦៦<br>• កងរាជអាវុធហត្ថ ខេត្តព្រះសីហនុ<br>- អាសយដ្ឋាន ៖ ក្រុម១៦ ភូមិ១ សង្កាត់១ ក្រុងព្រះសីហនុ<br>- ទូរស័ព្ទលេខ ៖ ០១២ ៤៦៣ ៦៣៦ / ០៩៧ ៧៥៥ ៥៦៦៦ FREE (៧៩៦៦ ) / ០១៦ ៩១៩ ០០៧ |
| **គោលបំណងនៃការផ្តល់សេវា** | អប់រំបន្សាបសារធាតុគ្រឿងញៀនដល់ជនទាំងឡាយ ដែលកំពុងរងគ្រោះដោយសារធាតុគ្រឿងញៀន |
| **មូលដ្ឋានគតិយុត្ត** | អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងទូទៅនៃកងរាជអាវុធហត្ថ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | គ្រប់ជនរងគ្រោះដោយសារគ្រឿងញៀន |
| **ស្តង់ដាសេវា** | • រយៈពេល ៖ មិនកំណត់ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើម) |
| **យោបល់** | គ្រប់ជនរងគ្រោះដោយសារគ្រឿងញៀនអាចទំនាក់ទំនងទៅកងរាជអាវុធហត្ថខេត្តបាត់ដំបង, កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ និងកងរាជអាវុធហត្ថខេត្តព្រះសីហនុ តាមរយៈលេខទូរសព្ទ័ខាងលើ ២៤ លើ ២៤ម៉ោង |

## សេវារក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

| ឈ្មោះសេវា | សេវារក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម |
|---|---|
| ក្រសួង/ស្ថាប័ន<br>ផ្តល់សេវា | **ក្រសួងការពារជាតិ**<br>១. បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស<br>• បញ្ជាការដ្ឋានយុត្តិធម៌<br>- ទូរស័ព្ទលេខ : ០១២ ៦៧២ ០១២ /០១៦ ៥០០ ១៧២ /<br>FREE ( ៧៧៧២ )<br>០៩៧ ៧៧៧ ៧៧ ៧២ / ០១២ ៧២ ៦៦ ៦៦<br>FREE ( ៥៥៩ )<br>• ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ<br>- ទូរស័ព្ទលេខ : ០១៧ ៩១១ ១៦៨ / ០៩៧ ៨៩១ ១១៦៨<br>FREE ( ៤៥២១ )<br>០៧៧ / ០៩៩ ៦៦៧ ៧៧៧<br>FREE ( ៧៨៥៧ )<br><br>២. បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ<br>- ទូរស័ព្ទលេខ : ០១២ ៨១៥ ០០៧ / ០៩៧ ៧៧៧ ៧៧ ៨៤/<br>FREE ( ៤៥៦៥ )<br>០១៦ ៨០៩ ០០៧ / ០៨៨ ៧៧៧ ៧៧ ៧៧/<br>FREE ( ៧៨០៧ )<br><br>៣. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកណ្តាល<br>- ទូរស័ព្ទលេខ : ០១២ ៩០០ ៦៦៦ / ០៩៧ ៧៧៧ ៧៧៦១/<br>FREE ( ៥៨៤ )<br>០១៦ ៥០០ ១៥៨ / ០៩៧ ៩៩២ ៣៣៣៩/<br>FREE ( ៥៥០ )<br>០១២ ៥១១ ១៤៧ / ០៩៧ ៩៩២ ៣៣៩២/<br>០១២ ២៧០ ២៧០<br><br>៤. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តសៀមរាប<br>- ទូរស័ព្ទលេខ : ០១២ ៨៥២ ២២៩ /០៩៧ ៧៧៧ ៧៧ ៧៨<br>FREE ( ៥៦៧ )<br>០១២ ៥៣៥ ៧៦៧<br><br>៥. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកំពង់ស្ពឺ<br>- ទូរស័ព្ទលេខ : ០១២ ៨៨៨ ៥១០ / ០៩៧ ៧៧៧ ៧៧ ៧៣<br>FREE ( ៥៤៥ )<br>០១៦ ៥០០ ១៥៩<br><br>៦. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកំពង់ឆ្នាំង<br>- ទូរស័ព្ទលេខ : ០១២ ៩១២ ៥៥២ / ០៩៧ ៧៧៧ ៧៧ ៦២<br>FREE ( ៥៤៦ ) |

| | |
|---|---|
| | ០១២ ៦៣៥ ៣០៧ / ០៩៧ ៩៩៦ ០៣០៩<br><br>៧. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកំពត<br>- ទូរស័ព្ទលេខ : ០១២ ៣០០ ៤៤៤ / ០៩៧ ៧៩៧ ៥៩ ៧៥<br>FREE ( ៦១៨ )<br>០១៦ ៥០០ ១៦០<br><br>៨. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តពោធិ៍សាត់<br>- ទូរស័ព្ទលេខ : ០១២ ៧១៣ ២៤២ / ០៩៧ ៧៧៧ ៧៧ ៨១<br>០១៦ ៥០០ ១៥៣ / ០១២ ៨៣៨ ៨២៥ /<br>០៩៧ ៧២៥ ៩៩ ១១<br><br>៩. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តប៉ៃលិន<br>- ទូរស័ព្ទលេខ : ០១២ ៨៣៩ ១២២ / ០៩៧ ៧៧៧ ៧៧ ៨៣ /<br>០១៦ ៥០០ ១៧៩<br><br>១០. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តព្រះវិហារ<br>- ទូរស័ព្ទលេខ : ០១២ ៩១៤ ៦៣៨ / ០៩៧ ៧៧៧ ៧៧ ២៥<br>០១១ ៩១៤ ៦៣៨ /០៩៧ ៧៥៧ ៨៨ ៥៥<br>០១៦ ៥០០ ១៨៥ / ០១២ ៩៣០ ៥៤៧<br><br>១១. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តព្រះសីហនុ<br>- ទូរស័ព្ទលេខ : ០១២ ៤៦៣ ៦៣៦ / ០៩៧ ៧៥៥ ៥៦៦៦<br>FREE ( ៧៩៦៦ )<br><br>១២. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកោះកុង<br>- ទូរស័ព្ទលេខ : ០១៦ ៥០០ ១៦៤ / ០៩៧ ៧៧៧ ៧៧ ៧៥<br>FREE ( ៥៧៦ )<br>០៩៧ ៧១៧ ៩៩ ៧៧ / FREE ( ៥៣៩ )<br><br>១៣. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តតាកែវ<br>- ទូរស័ព្ទលេខ : ០១២ ៤៦៤ ៤៤៤ / ០៩៧ ៧៧៧ ៧៧ ៧០<br>FREE ( ៥៤៤ )<br>០១៦ ៥០០ ១៦១ / ០៩៧ ៩៩៦ ៦៩ ៥៩<br><br>១៤. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកំពង់ធំ<br>- ទូរស័ព្ទលេខ : ០១២ ៧០៥ ៦៩៩ / ០៩៧ ៧៧៧ ៧៧ ៧៦<br>FREE ( ៥៤១ )<br>០១២ ៨២៩ ៩៣៦ / ០៩៧ ៧៥៨ ៩៩១១<br><br>១៥. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តក្រចេះ<br>- ទូរស័ព្ទលេខ : ០១២ ៨៤២ ៦២៦ / ០៩៧ ៨៩៨ ៩៨ ៩៨<br>០១៦ ៥០០ ១៥៧ / ០១២ ៥៥២ ០៦៦/<br>០៩៧ ៧៥៨ ៩៩ ៧៧<br><br>១៦. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តរតនៈគីរី<br>- ទូរស័ព្ទលេខ : ០១២ ៨៣០ ៤៤៦ / ០៩៧ ៧៧៧ ៧៧ ៦៣ |

| | |
|---|---|
| | ០១៦ ៥០០ ១៥៤ / ០៩៧ ៧៦១ ៦៦ ៣៣<br>០១២ ៤៣៥ ៥៦១<br><br>១៧. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តមណ្ឌលគីរី<br>- ទូរស័ព្ទលេខ : ០១២ ៨២១ ២៧៥ / ០៩៧ ៧៧៧ ៧៧ ៦៤<br>០១៦ ៥០០ ១៧៣ / ០៩៧ ៧៧១ ៧៧ ៥៥<br><br>១៨. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តស្វាយរៀង<br>- ទូរស័ព្ទលេខ : ០១២ ៥៧២ ៧៦៨ / ០៩៧ ៧៧៧ ៧៧ ៦៧<br>FREE ( ៥៤២ )<br>០៩៧ ៧៧៧ ៧៦៦៦ /០១៥ ៣៤៤ ៦០៦<br><br>១៩. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តព្រៃវែង<br>- ទូរស័ព្ទលេខ : ០១៦ ៥០០ ១៧១ / ០៩៧ ៧៧៧ ៧៧ ៦៩<br>FREE ( ៥៥៧ )<br>០១២ / ០១៦ ៩០៧ ០០៨<br><br>២០. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកំពង់ចាម<br>- ទូរស័ព្ទលេខ : ០៨១ ៨៨៨ ១៨៨ / ០៩៧ ៧៧៧ ៧៧ ៦៨<br>FREE ( ៧៩៧០ / ៥១៣ )<br>២១. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តត្បូងឃ្មុំ<br>- ទូរស័ព្ទលេខ : ០១២ ៥៦១ ៧៨៩ / ០៩៧ ៧៧៧ ៧៧ ៨៦<br>FREE ( ៤៤៧៩ )<br><br>២២. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តឧត្តរមានជ័យ<br>- ទូរស័ព្ទលេខ : ០១១ ៧១៣ ០៤៣ / ០៩៧ ៧៧៧ ៧៧៨០<br>០១៦ ៥០០ ១៨២ / ០១១ ៦៣១ ២៨៥/<br>០១៦ ២៧៩ ៣៧៤<br><br>២៣. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តស្ទឹងត្រែង<br>- ទូរស័ព្ទលេខ : ០៧៧ ៧៧៧ ៩៩៩ / ០៩៧ ៧៧៧ ៧៧៦០<br>FREE ( ៦២៩ / ៤៤៨០ )<br><br>២៤. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តកែប<br>- ទូរស័ព្ទលេខ : ០១២ ៨១៥ ០០៧ / FREE ( ៥៧០ )<br>០១៦ ៥០០ ១៨១ / ០១២ ៦៦៧ ៤០៧<br><br>២៥. បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ<br>- ទូរស័ព្ទលេខ : ០៩៧ ៧៧៧ ៧៧ ៨២ / FREE ( ៤៥៣១ ) |
| **គោលបំណង នៃការផ្តល់សេវា** | ជានាបរិយាកាស ការអភិវឌ្ឍសង្គមជាតិ រក្សាភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងផ្តល់ទំនុកចិត្តដល់វិនិយោគិន ធុរជន ក្នុងការប្រកបអាជីវកម្មនៅកម្ពុជា |
| **មូលដ្ឋានគតិយុត្ត** | អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងទូទៅ នៃកងរាជអាវុធហត្ថ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | គ្រប់ប្រជាពលរដ្ឋទូទាំងប្រទេស ឬជនបរទេស |

| | |
|---|---|
| **ស្តង់ដាសេវា** | • ផ្តល់ជូនដល់ជនរងគ្រោះ ២៤/២៤ ម៉ោង<br>• រកយុត្តិធម៌ជូនជនរងគ្រោះនិងស្វែងរកចាប់ខ្លួនជនបង្ក |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើម) |
| **យោបល់** | ប្រជាពលរដ្ឋគ្រប់រូបដែលបានជួបប្រទះនូវរាល់អំពើអយុត្តិធម៌ ដែលបង្កភាពអសន្តិសុខណាមួយ អាចទំនាក់ទំនងទៅកងរាជអាវុធហត្ថ ២៥ រាជធានី ខេត្ត តាមរយៈលេខទូរស័ព្ទខាងលើ ២៤ ម៉ោង លើ ២៤ ម៉ោង ។ |

# ក្រសួង អភិវឌ្ឍន៍ជនបទ

មហាវិថីសហព័ន្ធរុស្សី កាច់ជ្រុងផ្លូវ ១៦៩ រាជធានីភ្នំពេញ
សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
ទូរសព្ទ ៖ ០២៣ ៨៨៤ ៥៣៩
ទូរសារ ៖ ០២៣ ៩៩១ ១១៧
ប្រអប់សំបុត្រ ៖ ២០១៦
គេហទំព័រ ៖ http://www.mrd.gov.kh

**គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទនៅតាមបណ្តារាជធានី ខេត្ត**
**(ការផ្តល់សេវាឥណទានជនបទ)**

| | |
|---|---|
| ឈ្មោះសេវា | គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទនៅតាមបណ្តារាជធានី ខេត្ត (ការផ្តល់សេវាឥណទានជនបទ) |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | • **អង្គភាពគ្រប់គ្រងគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ**<br>- អាសយដ្ឋានៈ កាច់ជ្រុងវិថីលេខ ១៦៩ និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : ០២៣ ៩៦៥ ៤៤៣<br>- អ៊ីម៉ែល : credit.mrd@gmail.com<br>- គេហទំព័រ : www.mrd.gov.kh<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម**<br>- អាសយដ្ឋានៈ ផ្លូវព្រះកេតុមាលា ភូមិទី១៤ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ**<br>- អាសយដ្ឋានៈ ភូមិពោធិ៍ស្រុក ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង**<br>- អាសយដ្ឋានៈ ផ្លូវលេខ៣ ភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងកំពង់ចាម ខេត្តបាត់ដំបង<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ**<br>- អាសយដ្ឋានៈ ផ្លូវ២៨ មិថុនា សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តតាកែវ**<br>- អាសយដ្ឋានៈ ភូមិចក សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ**<br>- អាសយដ្ឋានៈ ភូមិទួលគោក សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ**<br>- អាសយដ្ឋានៈ ផ្លូវស្ទឹងសែន ភូមិទី៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ<br>• **អង្គភាពអនុវត្តគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង**<br>- អាសយដ្ឋានៈ ភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ប្រាក់កម្ចីដល់ប្រជាពលរដ្ឋជនបទសម្រាប់ជាដើមទុន ដើម្បីប្រកបមុខរបរបង្កើនប្រាក់ចំណូល |
| មូលដ្ឋានគតិយុត្ត | វិញ្ញាបនបត្រលេខ០៣០/០៣ វ.ប.ច.ប ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់ជាប្រតិបត្តិករឥណទានជនបទរបស់ធនាគារជាតិនៃកម្ពុជា |

| | |
|---|---|
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | ប្រជាពលរដ្ឋនៅទីជនបទ មានអាយុពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ ដែលមានសមត្ថភាពសងប្រាក់ត្រឡប់មកវិញ |
| **ស្តង់ដាសេវា** | • **ឥណទានជាក្រុមៈ**<br>- សមាជិកចាប់ពី ០៣ ទៅ ០៦នាក់ សម្រាប់ធានាគ្នាទៅវិញទៅមក<br>- ទំហំឥណទានមិនលើសពី ១ ០០០ ០០០រៀល<br>- រយៈពេលខ្ចី ពី០៦ខែ ទៅ ១០ខែ<br>- របៀបសង គឺសងរំលស់ចាប់ពីខែទី១ទៅ (អាចយ៉ាងយូរត្រឹមខែទី៦)<br>- អត្រាការប្រាក់ ២,២% ក្នុងមួយខែ (ពីរក្បៀសពីរភាគរយក្នុង១ខែ)<br>• **ឥណទានឯកកត្តជន (ទោល)**<br>- ទំហំឥណទានលើសពី១ ០០០ ០០០រៀល ដល់១២ ០០០ ០០០ រៀល<br>- រយៈពេលខ្ចី ពី ០៦ ទៅ ១៨ ខែ<br>- របៀបសង គឺសងរំលស់ចាប់ពីខែទី១ទៅ (អាចយ៉ាងយូរត្រឹមខែទី៦)<br>- អត្រាការប្រាក់ : ២% ក្នុងមួយខែ (ពីរភាគរយក្នុង១ខែ) |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | **ចំពោះសេវាឥណទានជាក្រុម**<br>- ពាក្យសុំខ្ចីរបស់ក្រុមធានា<br>- កិច្ចសន្យាខ្ចីប្រាក់របស់ក្រុមធានា<br>**ចំពោះសេវាឥណទានឯកត្តជន (ទោល)**<br>- ពាក្យសុំខ្ចីចងការប្រាក់<br>- កិច្ចសន្យាខ្ចីប្រាក់<br>- កិច្ចសន្យាដាក់បញ្ចាំ<br>- កិច្ចសន្យាព្រមព្រៀងធានា<br>- លិខិតបញ្ជាក់អចលនទ្រព្យ |
| **យោបល់** | ការផ្តល់ឥណទានជនបទពីគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានអត្រាការប្រាក់ទាប និងអាចផ្តល់ដើមទុនសម្រាប់ក្សា-បង្កើត និងពង្រីកមុខរបរផលិតកម្មកសិកម្ម សិប្បកម្ម សហគ្រាសខ្នាតតូច និងអាជីវកម្មផ្សេងៗ សហការបង្កើនប្រាក់ចំណូល ក៏ដូចជារួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ គម្រោងនេះនឹងពង្រីកបន្ថែមទៅតាមបណ្តាខេត្តផ្សេងៗផងដែរ។ |

# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អគារលេខ៣  មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨ ៤៣ ៧៥
ទូរសារ: ០២៣ ៨៨ ២៧ ៦៩

## ការចុះបញ្ជិកាសំណុំបែបបទស្តីពីសហគ្រាស គ្រឹះស្ថាន

| | |
|---|---|
| ឈ្មោះសេវា | ការចុះបញ្ជិកាសំណុំបែបបទស្តីពីសហគ្រាស គ្រឹះស្ថាន |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>• អាសយដ្ឋានៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក<br>• ឈ្មោះស្ថាប័ន អង្គភាពៈ នាយកដ្ឋានអធិការកិច្ចការងារ<br>• លេខទូរស័ព្ទទំនាក់ទំនងៈ ០២៣ ៨៨២ ៧៣០ |
| គោលបំណងនៃការផ្តល់សេវា | • ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិនិយោគ<br>• ផ្តល់ភាពស្របច្បាប់ជូនសហគ្រាស គ្រឹះស្ថាន ទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ<br>• ការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជក |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការងារ<br>• ប្រកាសលេខ២៨៨សកបយ.ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន<br>• ប្រកាសលេខ២៦៨សកបយ.ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០១ ស្តីពីសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន<br>• ប្រកាសលេខ២៦៩សកបយ.ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការបង្កើតសៀវភៅបើកប្រាក់<br>• សេចក្តីជូនដំណឹងលេខៈ ១៤ សកបយ.ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន |
| អតិថិជនដែលមានសិទ្ធទទួលសេវា | រូបវន្តបុគ្គល |
| ស្តង់ដាសេវា | ១- <u>តម្លៃសេវា</u>:<br>• ចុះបញ្ជិកាប្រកាសបើកសហគ្រាស<br>+ ២០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១នាក់ ដល់ ៧នាក់<br>+ ៣០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៨នាក់ ដល់ ១០០នាក់<br>+ ១០០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១០១នាក់ ដល់ ៥០០នាក់<br>+ ២០០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៥០១នាក់ឡើង<br>• ចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន<br>+ ២០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១នាក់ ដល់ ៧នាក់<br>+ ៤០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៨នាក់ ដល់ ១០០នាក់<br>+ ៨០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១០១នាក់ ដល់ ៥០០នាក់<br>+ ៨០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៥០១នាក់ឡើង<br>• ចុះបញ្ជិកាសៀវភៅបើកប្រាក់<br>+ ៤០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១នាក់ ដល់ ៧នាក់<br>+ ៦០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៨នាក់ ដល់ ១០០នាក់<br>+ ១២០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១០១នាក់ ដល់ ៥០០នាក់<br>+ ១២០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៥០១នាក់ឡើង |

| | |
|---|---|
| | • ចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុង<br>+ ៧០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៨នាក់ ដល់ ១០០នាក់<br>+ ៣០០ ០០០រៀល កម្មករនិយោជិត ចាប់ពី ១០១នាក់ ដល់ ៥០០នាក់<br>+ ៦០០ ០០០រៀល កម្មករនិយោជិត ចាប់ពី ៥០១នាក់ឡើង<br>**២- <u>រយៈពេលផ្តល់សេវាៈ</u>**<br>• ចុះបញ្ជិកាប្រកាសបើកសហគ្រាសៈ ១៥ថ្ងៃនៃថ្ងៃធ្វើការ<br>• ចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានៈ ៧ថ្ងៃនៃថ្ងៃធ្វើការ<br>• ចុះបញ្ជិកាសៀវភៅបើកប្រាក់ៈ ៧ថ្ងៃនៃថ្ងៃធ្វើការ<br>• ចុះទិដ្ឋាកាបទបញ្ជាផ្ទៃក្នុងៈ ៦០ថ្ងៃនៃថ្ងៃធ្វើការ<br>**៣- <u>សុពលភាពនៃសេវាៈ</u>** អចិន្ត្រៃយ៍ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • លក្ខន្តិកៈក្រុមហ៊ុន (បើមាន)<br>• ប័ណ្ណប៉ាតង់<br>• វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងក្រសួង(ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងការបរទេស ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ។ល។ ) |
| **យោបល់** | • សហគ្រាស គ្រឹះស្ថាន រួមទាំងសាខារបស់ខ្លួន ដែលមានវិញ្ញាបនប័ត្រសុំនៅក្រសួង (ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងការបរទេស ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ។ល។) ត្រូវតែ មកចុះបញ្ជិកាបែបបទស្តីពីសហគ្រាស គ្រឹះស្ថាន នៅនាយកដ្ឋានអធិការកិច្ចការងារ តាមប្រកាសលេខៈ២២៨ ក.ប /ប្រក.ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤<br>• សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិត ៧នាក់ចុះ ត្រូវទៅបំពេញបែបបទ និងទទួលសេវាពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត។ |

# លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង

| | |
|---|---|
| ឈ្មោះសេវា | លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>• អាសយដ្ឋានៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក<br>• ឈ្មោះស្ថាប័ន អង្គភាពៈ នាយកដ្ឋានអធិការកិច្ចការងារ<br>• លេខទូរស័ព្ទទំនាក់ទំនងៈ ០២៣ ៨៨២ ៧៣០ |
| គោលបំណង នៃការផ្តល់សេវា | • ធានាបាននូវការធ្វើការបន្ថែមម៉ោងស្របតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមច្បាប់<br>• ចូលរួមកាត់បន្ថយការជួលសន្លប់ ដោយសារធ្វើការលើសចិរវេលាកំណត់ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការងារ<br>• ប្រកាសលេខ៨០ សកបយ.ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការធ្វើការបន្ថែមម៉ោង។ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | រូបវន្តបុគ្គល |
| ស្តង់ដាសេវា | ១- តម្លៃសេវាៈ ១០០ ០០០រៀល<br>២- រយៈពេលផ្តល់សេវាៈ ប្រើរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការ<br>៣- សុពលភាពនៃសេវាៈ មានរយៈពេល ២ខែ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • លិខិតស្នើសុំធ្វើការបន្ថែមម៉ោង ត្រូវបញ្ជូនទៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃមុនការចាប់ផ្តើមធ្វើបន្ថែមម៉ោងចំនួន០១ច្បាប់<br>• លិខិតបញ្ជាក់អំពីយោបល់ឯកភាពរបស់ប្រតិភូពេញសិទ្ធគ្រប់រូបរបស់សហគ្រាស គ្រឹះស្ថាន ឬការ ឯកភាពពីចំនួនពាក់កណ្តាលនៃកម្មករ និយោជិត បើសហគ្រាស គ្រឹះស្ថានមិនទាន់មាន ប្រតិភូបុគ្គលិក ចំនួន ០១ច្បាប់។ |
| យោបល់ | សហគ្រាស គ្រឹះស្ថាន រួមទាំងសាខារបស់ខ្លួន ក្នុងករណីចង់ធ្វើការបន្ថែមម៉ោងលុះត្រាតែមាន ការអនុញ្ញាតពីនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។ |

# ពិនិត្យកាយសម្បទាមុនចូលធ្វើការ កម្មករនិយោជិតខ្មែរ

| | |
|---|---|
| ឈ្មោះសេវា | ពិនិត្យកាយសម្បទាមុនចូលធ្វើការ កម្មករនិយោជិតខ្មែរ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>• អាសយដ្ឋានៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក<br>• អគ្គនាយកដ្ឋានការងារ<br>• នាយកដ្ឋានពេទ្យការងារ<br>• លេខទូរសព្ទទំនាក់ទំនងៈ ០២៣ ៨៨៣ ១៧០ |
| គោលបំណងនៃការផ្តល់សេវា | បញ្ជាក់ពីកាយសម្បទា ដើម្បីវាយតម្លៃឲ្យសមស្របទៅនឹងការងារដែលត្រូវធ្វើ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីការងារ<br>• ប្រកាសរួមលេខ ០៩សកអ/៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៤ ស្តីពីការពិនិត្យកាយសម្បទាសម្រាប់ជនកម្ពុជា និងជនបរទេសដែលមកប្រកបមុខរបរនៅព្រះរាជាណាចក្រកម្ពុជា |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ជនជាតិខ្មែរទាំងពីរភេទ ដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា |
| ស្តង់ដាសេវា | ១- តម្លៃសេវាៈ ២០ ០០០រៀល<br>២- រយៈពេលផ្តល់សេវាៈ ០៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ<br>៣- សុពលភាពនៃសេវាៈ អចិន្ត្រៃយ៍ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • រូបថតទំហំ ៤ x ៦ ចំនួន ០២សន្លឹក<br>• អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រឺ លិខិតឆ្លងដែន រឺសំបុត្រកំណើតសញ្ជាតិខ្មែរ រឺ សៀវភៅគ្រួសារ រឺសៀវភៅស្នាក់នៅ |
| យោបល់ | ក្នុងករណីកម្មករនិយោជិត ផ្លាស់ប្តូរកន្លែងធ្វើការ រឺប៉ុស្តិ៍ការងារ តម្រូវឱ្យមានការពិនិត្យការសម្បទាឡើងវិញ។ |

# ពិនិត្យកាយសម្បទាមុនចូលធ្វើការ សម្រាប់ជនបរទេស

| | |
|---|---|
| ឈ្មោះសេវា | ពិនិត្យកាយសម្បទាមុនចូលធ្វើការ សម្រាប់ជនបរទេស |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ពាក្យសុំប្រកបអាជីវកម្ម ០១ច្បាប់<br>• និមិត្តសញ្ញា (Logo) ០២ច្បាប់<br>• លិខិតថ្កោលទោស ០១ច្បាប់<br>• ជីវប្រវត្តិរូបសង្ខេប ០២ច្បាប់<br>• កិច្ចសន្យា ០២ច្បាប់<br>• លិខិតបញ្ជាក់អត្តសញ្ញាណ(ថតចម្លង) ០២ច្បាប់<br>• តារាងអង្កេតទូទៅ ០២ច្បាប់<br>• លិខិតបញ្ជាក់ពីអាសយដ្ឋានសម្រាប់ទំនាក់ទំនង ០១ច្បាប់<br>• ប្លង់ទីតាំងធ្វើអាជីវកម្ម និង គំនូសតាងប្រព័ន្ធផ្សព្វផ្សាយ០២ច្បាប់<br>• របាយការណ៍សង្ខេបកម្មវិធីផ្សាយប្រចាំឆ្នាំ ០១ច្បាប់<br>• តារាងរាយនាមសម្ភារគ្រឿងម៉ាស៊ីនផ្សាយ ០២ច្បាប់ |
| យោបល់ | • គោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។<br>• គោរពតាមច្បាប់ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា។ |

| | |
|---|---|
| | • គោរពតាមក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន។<br>• គោរពតាមសេចក្តីជូនដំណឹង និងរាល់សារាចរណ៍ណែនាំរបស់ ក្រសួងព័ត៌មាន។<br>• ផ្តល់របាយការណ៍ចេញផ្សាយកាសែតប្រចាំឆ្នាំជូនក្រសួងព័ត៌មាន និងរាយការណ៍មក អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ដូចខាងក្រោម៖<br>១.បញ្ជីឈ្មោះ និងរចនាសម្ព័ន្ធអង្គភាព<br>២.លិខិតបញ្ជាក់អាសយដ្ឋានរោងពុម្ព និងចំនួនបោះពុម្ពដែលមាន ហត្ថលេខារបស់ប្រធានអង្គភាព កាសែត ទស្សនាវដ្តី និងព្រឹត្តិបត្រ<br>៣.លិខិតបញ្ជាក់អាសយដ្ឋានទីស្នាក់ការរបស់អង្គភាព ដែលមានបញ្ជាក់ពីចៅសង្កាត់ ឬមេឃុំ |

# ការផ្តល់លិខិតអនុញ្ញាតប័ណ្ណព័ត៌មានសម្រាប់អ្នកកាសែត

| | |
|---|---|
| **ឈ្មោះសេវា** | ការផ្តល់លិខិតអនុញ្ញាតប័ណ្ណព័ត៌មានសម្រាប់អ្នកកាសែត |
| **ក្រសួង/ស្ថាប័ន ផ្តល់សេវា** | **ក្រសួងព័ត៌មាន**<br>• អាគារលេខ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍<br>• ទូរស័ព្ទ : ០២៣ ៧២៤ ៥១៤/ ០២៣ ៤៣០ ២២៧<br>• ទូរសារ : ០២៣ ៤២៧ ៤៧៥<br>• គេហទំព័រ : www.info.gov.kh<br>• អ៊ីម៉ែល : info@inb.gov.kh |
| **គោលបំណង នៃការផ្តល់សេវា** | ដើម្បីលើកស្ទួយសិទ្ធិសេរីភាពសារព័ត៌មាន និងពង្រឹងពង្រីកលើវិស័យ ព័ត៌មានបោះពុម្ពផ្សាយ |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | ជារូបវន្តបុគ្គល ឬនីតិបុគ្គលជាជនជាតិខ្មែរ ឬជនជាតិបរទេសដែល កំណត់ដោយច្បាប់ និងកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| **មូលដ្ឋានគតិយុត្ត** | • ព្រះរាជក្រមលេខ នស/រកម ០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើត ក្រសួងព័ត៌មាន<br>• ច្បាប់ស្តីពីរបបសារព័ត៌មាន<br>• អនុក្រឹតលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងព័ត៌មាន<br>• អនុក្រឹត្តលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍<br>• ប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន ស្តីពីការផ្តល់ សេវាសាធារណៈរបស់ក្រសួងព័ត៌មាន |
| **ស្តង់ដាសេវា** | **តម្លៃ :**<br>• ប័ណ្ណព័ត៌មានសម្រាប់អ្នកកាសែតជនជាតិខ្មែរ ៥,០០០ រៀល<br>• ប័ណ្ណព័ត៌មានសម្រាប់អ្នកកាសែតជនជាតិបរទេស ២០,០០០ រៀល<br>**រយៈពេលផ្តល់សេវា :** ០៧ថ្ងៃ (ថ្ងៃធ្វើការ)<br>**សុពលភាព :** ១ឆ្នាំ (មួយឆ្នាំ) |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | • ពាក្យស្នើសុំរបស់អង្គភាព ០១ច្បាប់<br>• ប្រវត្តិរូបសង្ខេប ០១ច្បាប់<br>• លិខិតបញ្ជាក់អត្តសញ្ញាណ(ថតចម្លង) ០១ច្បាប់<br>***សម្រាប់ជនបរទេស ត្រូវមានប័ណ្ណអ្នកសារព័ត៌មានពីប្រទេសដើម** |
| **យោបល់** | • ប័ណ្ណព័ត៌មាននេះចេញដោយអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សំរាប់អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។<br>• អ្នកសារព័ត៌មាន ពេលចុះយកព័ត៌មានត្រូវតែបង្ហាញជូនសមត្ថកិច្ច នូវប័ណ្ណព័ត៌មានរបស់ខ្លួន។<br>• អ្នកសារព័ត៌មាន ដែលធ្វើសកម្មភាពប្រាសចាកវិជ្ជាជីវៈ និងក្រម សីលធម៌នៃអ្នកសារព័ត៌មាន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ |

# ការផ្តល់លិខិតអនុញ្ញាតសារបង្ការដៃ

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់លិខិតអនុញ្ញាតសារបង្កាន់ដៃ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងព័ត៌មាន**<br>• អាគារលេខ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍<br>• ទូរស័ព្ទ : ០២៣ ៧២៤ ៥១៤/ ០២៣ ៤៣០ ២២៧<br>• ទូរសារ : ០២៣ ៤២៧ ៤៧៥<br>• គេហទំព័រ : www.info.gov.kh<br>• អ៊ីម៉ែល : info@inb.gov.kh |
| គោលបំណង នៃការផ្តល់សេវា | ដើម្បីលើកស្ទួយសិទ្ធិសេរីភាពសារព័ត៌មាន និងពង្រឹងពង្រីកលើវិស័យ ព័ត៌មាន និងសោតទស្សន៍ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជារូបវន្តបុគ្គល ឬនីតិបុគ្គលជាជនជាតិខ្មែរ ឬជនជាតិបរទេសដែលកំណត់ដោយច្បាប់ និងកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម ០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើត ក្រសួងព័ត៌មាន<br>• ច្បាប់ស្តីពីរបបសារព័ត៌មាន<br>• អនុក្រឹតលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងព័ត៌មាន<br>• អនុក្រឹត្តលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍<br>• ប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន ស្តីពីការផ្តល់ សេវាសាធារណៈរបស់ក្រសួងព័ត៌មាន |
| ស្តង់ដាសេវា | **តម្លៃ** : ៤០,០០០រៀល<br>**រយៈពេលផ្តល់សេវា** : ០៥ថ្ងៃ (ថ្ងៃធ្វើការ)<br>**សុពលភាព** : ៦ខែ (ប្រាំមួយខែ) |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ពាក្យសុំ ០១ច្បាប់<br>• ខ្លឹមសារ និងឯកសារពាក់ព័ន្ធ ០១ច្បាប់ |
| យោបល់ | • គោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា<br>• គោរពតាមច្បាប់ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា<br>• គោរពតាមក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន<br>• គោរពតាមសេចក្តីជូនដំណឹង និងរាល់សារាចរណ៍ណែនាំរបសក្រសួង ព័ត៌មាន |

# ក្រសួង កិច្ចការនារី


ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹង មានជ័យ

ខណ្ឌមានជ័យ  រាជធានីភ្នំពេញ

ទូរសព្ទ ៖ ០២៣ ៨៨០ ៧៣៧/៨៨២ ០៤៨

៨៨២ ០៣៩/៨៨២ ០៤៩

ទូរសារ ៖ ០២៣ ៨៨០ ៧៣៧

# កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

| | |
|---|---|
| ឈ្មោះសេវា | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងកិច្ចការនារី**<br>• អគ្គនាយកដ្ឋានអភិវឌ្ឍសង្គម<br>• នាយកដ្ឋានការពារផ្លូវច្បាប់<br>- អាស័យដ្ឋាន : ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>- ទូរស័ព្ទអគ្គនាយករង : ០១២ ៩២៦ ៤៥៩<br>- ទូរស័ព្ទអនុប្រធាននាយកដ្ឋាន : ០៩៧ ៩៤ ៩៣ ១៨០/០១១ ២១៧ ១២៣<br>- អ៊ីមែល : chanchin137@gmail.com / sineth.sar@yahoo.com<br>**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី**<br>• អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍<br>• មន្ទីរកិច្ចការនារីរាជធានី ខេត្ត<br>- អាស័យដ្ឋាន : ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងគ្រប់មន្ទីរកិច្ចការនារី រាជធានី ខេត្ត<br>- ទូរស័ព្ទប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ : ០១២ ៨២៣ ៣៣៤ |
| គោលបំណង នៃការផ្តល់សេវា | • ផ្តល់ និងពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាលើស្ត្រី និងការជួញដូរមនុស្ស រៀងរាល់ម៉ោងធ្វើការ<br>• ជួយធ្វើពាក្យបណ្តឹងដល់ជនរងគ្រោះទៅនគរបាលយុត្តិធម៌និងតុលាការ និងតាមដានសំណុំរឿងរបស់ជនរងគ្រោះទៅគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>• ធានាឲ្យស្ត្រី និងក្មេងស្រីទទួលបាននូវកិច្ចការពារផ្លូវច្បាប់ដោយស្មើភាពតាមរយៈការបញ្ចូលសិទ្ធិស្ត្រីក្នុងដំណើរការតាក់តែង រៀបចំ និងអនុវត្តច្បាប់ និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សានិងការជួញដូរមនុស្សដោយមានប្រសិទ្ធភាព<br>• លើកកម្ពស់កិច្ចការពារផ្លូវច្បាប់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និងកុមាររួមទាំងអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើអាសអាភាស អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ កំលាំងពលកម្ម និងទេសន្តប្រវេសន៍<br>• បង្កើនប្រសិទ្ធភាពក្នុងការទទួលបាននូវសេវាការពារផ្លូវច្បាប់ដល់ស្ត្រី ដែលរងគ្រោះដោយអំពើហិង្សា អំពើជួញដូរមនុស្ស<br>• បង្កើនការទទួលបាន និងផ្តល់សេវាសង្គម និងសុខាភិបាល ដល់ជនរងគ្រោះដោយអំពើហិង្សា រួមទាំងអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ កំលាំងពលកម្ម<br>• ជួយជំរុញការអនុវត្តសិទ្ធិស្ត្រីឲ្យមានប្រសិទ្ធភាពស្របតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW) |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខនស/រកម/១០០៥/០៣១ចុះថ្ងៃទី១៥ខែតុលាឆ្នាំ២០០៥ ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ |

| | |
|---|---|
| | • ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី៣០ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ<br>• ប្រកាសអន្តរក្រសួងលេខ ៦៤ ប្រកកយ កកន/០៧ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពី ការតែងតាំងនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី<br>• សេចក្តីជូនដំណឹងលេខ ៥៦៤ សជណ.អហ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០១៤ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | • ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើហិង្សា (ជនគ្រប់រូបដោយសារ អាយុ ពិការភាព ភេទ សាវតា វប្បធម៌ ឬឋានៈ សង្គម ស្ថានភាពផ្សេងៗ ទោះជាបណ្តោះអាសន្នក្តី ឬអចិន្ត្រៃយ៍ក្តី)<br>• ស្ត្រី កុមារក្រីក្ររងគ្រោះដោយអំពើហិង្សាគ្រប់រូបភាពនៅទូទាំងរាជធានីខេត្ត |
| **ស្តង់ដាសេវា** | មិនគិតកម្រៃ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • ឯកសារពាក់ព័ន្ធនឹងសំណុំរឿងក្តីរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ<br>• បំពេញបែបបទធ្វើពាក្យបណ្តឹងមកក្រសួងកិច្ចការនារី<br>• អាចអន្តរាគមន៍ក្នុងករណីចាំបាច់<br>• លិខិតបញ្ជាក់ពីស្ថានភាពក្រីក្ររបស់អាជ្ញាធម៌ឃុំ សង្កាត់<br>• កំណត់ហេតុ និងរបាយការណ៍ |
| **យោបល់** | សម្របសម្រួលក្នុងការស្វែងរកសេវាផ្លូវច្បាប់ និងសេវាផ្សេងទៀត សម្រាប់ស្ត្រី កុមារ ក្រីក្ររងគ្រោះដោយអំពើហិង្សាគ្រប់រូបភាពនៅទូទាំងរាជធានី ខេត្ត ទាំងមាន និងគ្មានពាក្យបណ្តឹង |

# បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

| | |
|---|---|
| **ឈ្មោះសេវា** | ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |
| **ក្រសួង/ស្ថាប័ន ផ្តល់សេវា** | **ក្រសួងកិច្ចការនារី**<br>• អគ្គនាយកដ្ឋានសមភាពយេនឌ័រនិងអភិវឌ្ឍន៍សេដ្ឋកិច្ច<br>• នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច<br>- អាស័យដ្ឋាន : ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>- ទូរស័ព្ទអគ្គនាយក : ០១២ ៨៩២ ៥៩៧<br>- ទូរស័ព្ទប្រធាននាយកដ្ឋាន : ០៧៧ ៨៧១ ៤១៨<br>- ទូរស័ព្ទអនុប្រធាននាយកដ្ឋាន : ០១៦ ៦០៦ ៦២៧<br>- អ៊ីមែល: siphat.k@gmail.com<br>sithonsoth@yahoo.com<br>kimsoeunsav@yahoo.com |
| **គោលបំណង នៃការផ្តល់សេវា** | • លើកកម្ពស់ស្ថានភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់ ការអភិវឌ្ឍន៍សហគ្រាស និងការងារ ដើម្បីឈានទៅរកការបង្កើនប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅ និងកិច្ចការពារសង្គម<br>• បង្កើនឱកាសការងារសម្រាប់ស្ត្រីរួមទាំងស្ត្រីពិការ និងក្រុមស្ត្រីងាយរងគ្រោះ តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ស្ត្រី ស្របតាមតម្រូវការទីផ្សារការងារ |
| **មូលដ្ឋានគតិយុត្ត** | ប្រកាសលេខ ០៩៥ កកន/ប្រក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្ត ក្រុង |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | ក្មេងស្រី ស្ត្រីក្រីក្រ ដែលពុំមានលទ្ធភាពបន្តការសិក្សា និងមិនមានលទ្ធភាពទៅរៀននៅសាលាបណ្តុះបណ្តាលដែលបង់ប្រាក់ |
| **ស្តង់ដាសេវា** | មិនយកកម្រៃ |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | • ដើម្បីគាំទ្រដល់ផែនការសមាហរណកម្មថ្នាក់ស្រុក ដែលត្រូវការជំនាញសម្រាប់ស្ត្រី មន្ទីរកិច្ចការនារីធ្វើលិខិតជូនដំណឹងទៅសាលាស្រុក<br>• លិខិតប្រកាសជូនដំណឹងរបស់មន្ទីរកិច្ចការនារីទៅតាមស្រុក ឃុំ អង្គការ<br>• ពាក្យស្នើសុំរៀនជំនាញ ដោយមានហត្ថលេខាអាណាព្យាបាលសិស្ស និងមេភូមិ ដោយមានភ្ជាប់រូបថត |
| **យោបល់** | |

# ការអភិវឌ្ឍន៍សមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ

| | |
|---|---|
| ឈ្មោះសេវា | ការអភិវឌ្ឍន៍សមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងកិច្ចការនារី**<br>• អគ្គនាយកដ្ឋានសមភាពយេនឌ័រនិងអភិវឌ្ឍន៍សេដ្ឋកិច្ច<br>• នាយកដ្ឋានសមភាពយេនឌ័រ<br>- អាស័យដ្ឋាន : ផ្លូវទ្រុងមាន់ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>- ទូរស័ព្ទអគ្គនាយក : ០១២ ៨៩២ ៤៩៦<br>- ទូរស័ព្ទប្រធាននាយកដ្ឋាន : ០១២ ៧៥៨ ៩៨៦<br>- ទូរស័ព្ទការិអគ្គនាយក. : ០២៣ ៨៨២ ០៤៧ ឬ ០២៣ ៨៨២ ០៤៨<br>- អ៊ីមែល : siphat.k@gmail.com<br>- វេបសាយ : www.mowa.gov.kh |
| គោលបំណងនៃការផ្តល់សេវា | លើកកម្ពស់ស្ថានភាព ឋានៈ តួនាទី របស់ស្ត្រីតាមរយៈការអភិវឌ្ឍសមត្ថភាពដល់ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ ទាំងថ្នាក់ជាតិនិងក្រោមជាតិ និងទទួលបានឱកាសការងារសមរម្យ ឋានៈ តួនាទីដើម្បីបង្កើនសមាមាត្រស្ត្រីជាថ្នាក់ដឹកនាំលើគ្រប់វិស័យ និងឈានទៅសម្រេចបានផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងរួមចំណែកអនុវត្តន៍យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ |
| មូលដ្ឋានគតិយុត្ត | យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី៣ ( ២០១៤ - ២០១៨ ) ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ( ២០១៤ - ២០១៨ ) |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ស្ត្រីជាថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ស្តង់ដាសេវា | មិនយកកម្រៃ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | លិខិតបញ្ជាក់ពីក្រសួង ស្ថាប័ន |
| យោបល់ | សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីសម្រេចឲ្យបាននូវសមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រីនិងកុមារ ព្រមទាំងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ និងវិស័យសាធារណៈនៅគ្រប់កម្រិត។ |

# ការផ្សព្វផ្សាយព័ត៌មានស្តីពីសមភាពយេនឌ័រនិងសិទ្ធិស្ត្រី

| | |
|---|---|
| ឈ្មោះសេវា | ការផ្សព្វផ្សាយព័ត៌មានស្តីពីសមភាពយេនឌ័រនិងសិទ្ធិស្ត្រី |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងកិច្ចការនារី**<br>• អគ្គនាយកដ្ឋានសមភាពយេនឌ័រនិងអភិវឌ្ឍន៍សេដ្ឋកិច្ច<br>• នាយកដ្ឋានព័ត៌មាន<br>- អាសយដ្ឋាន : ផ្លូវទ្រុងមាន់ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>- ទូរស័ព្ទអគ្គនាយក : ០១២ ៨៩២ ៤៩៦<br>- ទូរស័ព្ទប្រធាននាយកដ្ឋាន : ០១១ ៨៥៣ ៧៥០<br>- ទូរស័ព្ទការិ.អគ្គនាយក : ០២៣ ៨៨២ ០៤៧ ឬ ០២៣ ៨៨២ ០៤៨<br>- អ៊ីមែល : siphat.k@gmail.com<br>- វេបសាយ : www.mowa.gov.kh |
| គោលបំណង នៃការផ្តល់សេវា | លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីតាមរយៈការសិក្សាស្រាវជ្រាវ ការរៀបចំវេទិកាយុវវ័យជជែកពិភាក្សាការផ្សព្វផ្សាយផ្ទាល់ដល់សហគមន៍ និងតាមវិទ្យុ ទូរទស្សន៍ ព្រឹត្តិបត្រដើម្បីបង្កើនការយល់ដឹងដល់សាធារណៈជន ជាពិសេសយុវជនក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងឈានទៅកែលម្អផ្នត់គំនិតអវិជ្ជមានដែលរើសអើងចំពោះស្ត្រី កាត់បន្ថយអំពើហិង្សា និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងឈានទៅសម្រេចបានផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងរួមចំណែកអនុវត្តន៍យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ |
| មូលដ្ឋានគតិយុត្ត | យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី៣ ( ២០១៤ - ២០១៨ ) ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ( ២០១៤ - ២០១៨ ) |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ប្រជាពលរដ្ឋទូទាំងប្រទេស |
| ស្តង់ដាសេវា | មិនយកកម្រៃ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | |
| យោបល់ | សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងសង្គមស៊ីវិលក្នុងការអភិវឌ្ឍសមត្ថភាព ការលើកកម្ពស់សមភាព និងបង្កើនភាពអង់អាចដល់ស្ត្រី។ |

# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ
ទូរសព្ទ័ និងទូរសារ ៖ (៨៥៥) ២៣ ៧២៦ ០៨៦
គេហទំព័រ ៖ www.mosvy.gov.kh

# ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានយុវនីតិសម្បទា<br>• ទូរស័ព្ទ ៖ ០៧៧ ៩៦៩ ២២១<br>• មជ្ឈមណ្ឌលបន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>• (អាសយដ្ឋានៈ ភូមិធ្លក ស.ក គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ) |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការស្នាក់បណ្តោះអាសន្នជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន នៅក្នុងមជ្ឈមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ដើម្បីបន្សាប ថែទាំសុខភាព អប់រំ កីឡា ព្យាបាល បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ស្តារនីតិសម្បទា សមាហរណកម្មនៅសហគមន៍ និងតាមដានបន្ត |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២<br>• អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពី ការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោល នយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• អនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>• អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាកនៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• ប្រកាសលេខ ២៥៣ ស.អ.យ. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ស្តីពីការអនុវត្តរបប ឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលស្នាក់ នៅក្នុងមជ្ឈមណ្ឌលអប់រំ បន្សាយ ព្យាបាល និងស្តារនីតិសម្បទា |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | • ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមណ្ឌលរបស់រដ្ឋ និង សហគមន៍<br>• ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ហើយត្រូវទទួលបានសេវាបន្សាប ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បានជាសះស្បើយ រួចធ្វើសមាហរណកម្មទៅសហគមន៍វិញ |
| ស្តង់ដាសេវា | ជនរងគ្រោះដោយការប្រើប្រាស់បំពានគ្រឿងញៀនដែលទទួលបានសេវាស្តារនីតិសម្បទា ទទួលបាន៖<br>• ទទួលបានរបបម្ហូបអាហារ ១៥០.០០០៛ /ខែ/ម្នាក់<br>• ទទួលបានសម្លៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារដំណេក ផ្ទះបាយ អ |

| | |
|---|---|
| | នាម័យ និង ព្យាបាល ១២០.០០០៛/ឆ្នាំ/ម្នាក់<br>• ទទួលបានការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ១វគ្គរយៈពេលខ្លី៣ខែ ៣៩០.០០៛/ម្នាក់<br>• ទទួលបានការធ្វើសមាហរណកម្ម ១ដងគត់ ២២៥.០០០៛/ម្នាក់ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | មជ្ឈមណ្ឌលក្រោមការគ្រប់គ្រងរបស់ក្រសួង (មណ្ឌលយុវនីតិសម្បទា)<br>**ក.ការបញ្ចូលជនរងគ្រោះក្នុងមជ្ឈមណ្ឌល ត្រូវមាន៖**<br>1. ពាក្យស្នើសុំបញ្ចូលជនរងគ្រោះក្នុងមជ្ឈមណ្ឌល ០១ច្បាប់<br>2. បញ្ជីឈ្មោះជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលត្រូវស្នើសុំបញ្ចូលក្នុងមជ្ឈមណ្ឌល ០១ច្បាប់<br>3. កំណត់ហេតុ ឬលិខិតប្រគល់ ទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ០១ច្បាប់<br>4. កិច្ចសន្យារបស់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ០១ច្បាប់<br>5. កិច្ចសន្យាអាណាព្យាបាល ០១ច្បាប់<br>6. ប្រវត្តិរូបសង្ខេបរបស់ជនរងគ្រោះ ០១ច្បាប់<br>**ខ.ការបញ្ចេញជនរងគ្រោះពីមជ្ឈមណ្ឌល ត្រូវមាន៖**<br>1. ពាក្យស្នើសុំបញ្ចេញជនរងគ្រោះពីមជ្ឈមណ្ឌល ០១ច្បាប់<br>2. បញ្ជីឈ្មោះជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលត្រូវស្នើសុំបញ្ចេញពីមជ្ឈមណ្ឌល ០១ច្បាប់<br>3. សេចក្តីចម្លងប្រកាសបញ្ចូលមុខសញ្ញាក្នុងមជ្ឈមណ្ឌល ០១ច្បាប់<br>4. សំបុត្រមរណភាព (ប្រសិនបើមាន) ០១ច្បាប់<br>5. លិខិតយល់ព្រមទទួលរបស់គ្រួសារ សាច់ញាតិ ឬអាជ្ញាធរមូលដ្ឋាន ០១ច្បាប់ |
| **យោបល់** | |

# សេវាផ្តល់ការស្នាក់នៅជូនកុមារកំព្រា និងកុមាររងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

| | |
|---|---|
| ឈ្មោះសេវា | សេវាផ្តល់ការស្នាក់នៅជូនកុមារកំព្រា និងកុមាររងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពកុមារ<br>• ការិយាល័យកិច្ចការមណ្ឌល<br>- អាសយដ្ឋាន: អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : ០២៣ ២១៤ ០៣៩ |
| គោលបំណង នៃការផ្តល់សេវា | • ការផ្តល់សេវាស្នាក់នៅ ហូបចុក ស្លៀកពាក់ដល់ទារក/កុមារដែលរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋ មានដូចជាទារកកំព្រា កុមារកំព្រា ទារក/កុមារ ស្ថិតនៅគ្រួសារទីទ័លក្រ ទារក/កុមារត្រូវគេបោះបង់ចោល កុមារពិការ កុមាររងផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ កុមារអនាថាកុមាររងផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារកុមារត្រូវបានរំលោភបំពាន កុមារត្រូវបានកេងប្រវ័ញ្ចគ្រប់រូបភាព<br>• ធ្វើឱ្យប្រសើរឡើងនូវផ្នែកជីវភាពរបស់មុខសញ្ញាខាងលើដើម្បីទទួលបានការចិញ្ចឹមបីបាច់ថែទាំ ស្តារលទ្ធភាពពលកម្ម ផ្គត់ផ្គង់ជីវភាព អប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | • អនុសញ្ញាស្តីពីសិទ្ធិកុមារ<br>• ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ<br>• ច្បាប់ស្តីពីសុំកូនអន្តរប្រទេស<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌលរដ្ឋ<br>• អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• អនុក្រឹត្យលេខ ១១៩អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រង មណ្ឌលថែទាំកុមារ<br>• ប្រកាសលេខ ៣៥៩ ស.អ.យ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត រាជធានី<br>• គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ<br>• ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ<br>• បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ<br>• សារាចរណែនាំលេខ ០០៤ ស.អ.យ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការអនុវត្ត អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦<br>• ប្រកាសលេខ ៣០៨ ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៦ ស្តីពី |

| | |
|---|---|
| | លក្ខខណ្ឌ និង ទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | ទារក/កុមារ ដែលរស់នៅក្នុងមជម្ឍណ្ឌលកុមារកំព្រារបស់រដ្ឋ មានដូចជា ទារកកំព្រា កុមារកំព្រា ទារក/កុមារស្ថិតនៅគ្រួសារទីទាល់ក្រ ទារក/កុមារត្រូវគេបោះបង់ចោល កុមារពិការ កុមាររងផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ កុមារអនាថា កុមាររងផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារត្រូវបានរំលោភបំពាន កុមារត្រូវបានកេងប្រវ័ញ្ចគ្រប់រូបភាព និងកុមាររងគ្រោះមួយចំនួនទៀតដែលកំពុងស្ថិតនៅក្រោមការថែទាំ ជំនួសក្នុងគ្រួសារ និងសហគមន៍រួមទាំងការងារស្មុំកូនក្នុងប្រទេសផងដែរ។ |
| **ស្តង់ដាសេវា** | • ទារកក្រោម ២ឆ្នាំ ចុះទទួលបានរបបទឹកដោះគោ ១៥០.០០០៛/ខែ/ម្នាក់<br>• កុមារអាយុលើស ២ឆ្នាំទទួលបានរបបម្ហូបអាហារ ១៥០.០០០៛/ខែ/ម្នាក់<br>• ទារក/កុមារពិការធ្ងន់ធ្ងរមានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ឬមានជំងឺអេដស៍ ទទួលបាន ២០.០០០៛ /ខែ/ម្នាក់ សម្រាប់ប្រាក់បំប៉នសុខភាពបន្ថែមលើប្រាក់ម្ហូប<br>• ទទួលបានប្រាក់សម្រាប់សម្លៀកបំពាក់សម្ភារសិក្សា កីឡា សម្ភារដំណេកផ្ទះបាយ អនាម័យ និងព្យាបាល ១២០.០០០៛ ក្នុង១ឆ្នាំ ក្នុង១នាក់<br>• ទារក/កុមារអាយុ៥ឆ្នាំចុះទទួលមរណភាពទទួលបានប្រាក់សម្រាប់រៀបចំពិធីបុណ្យសព ២៧០.០០០៛<br>• កុមារអាយុលើសពី៥ឆ្នាំ ទទួលមរណភាពទទួលបានប្រាក់សម្រាប់រៀបចំពិធីបុណ្យសព ៥៤០.០០០៛<br>• កុមារ យុវកុមារអាយុពី៧ ដល់ក្រោម ១៨ឆ្នាំ ទទួលបានការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ ១វគ្គរយៈពេលខ្លី ៣ខែ ៣៩០.០០០៛/ម្នាក់<br>• អាយុ១៨ឆ្នាំ ឡើងទទួលបានការធ្វើសមាហរណកម្ម១ដងគត់ ១.០៨០.០០០៛ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • ប្រកាសបញ្ចូលឈ្មោះកុមារទៅក្នុងមជ្ឈមណ្ឌលរដ្ឋ<br>• ប្រកាសបញ្ចេញឈ្មោះកុមារពីមជ្ឈមណ្ឌលរដ្ឋ<br>• ប្រកាសលុបឈ្មោះកុមារដែលត្រូវស្លាប់ពីមជ្ឈមណ្ឌលរដ្ឋ |
| **យោបល់** | |

# របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលមានស្ថានភាពចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ និង មរណភាព និងអ្នកនៅក្នុងបន្ទុក នៃជនទាំងនេះ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- អាសយដ្ឋាន : នៅក្នុងទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : (៨៥៥)២៣ ៩៨៧ ៥១២<br>- ទូរសារ : (៨៥៥)២៣ ៩៨៧ ៥២៣<br>- អ៊ីមែល : info@nssfc.gov.kh<br>- គេហទំព័រ : www.nssfc.gov.kh |
| គោលបំណងនៃការផ្តល់សេវា | ការផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និង អ្នកនៅក្នុងបន្ទុកតាមគោលការណ៍ អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>• ព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១២០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលឋានន្តរស័ក្តិ ថ្នាក់សន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងាររបស់ក្របខណ្ឌភ្នាក់ងាររដ្ឋបាល ក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេសរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>• ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>• ព្រះរាជក្រឹត្យលេខ នស/រកត/០៩១២/៨៤៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលជាស្ត្រី<br>• ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ<br>• ព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០១៧ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់ បន្ទាប់បន្សំនៃបៀវត្សមន្ត្រីរាជការស៊ីវិល<br>• អនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>• អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា<br>• អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការ |

កំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធនជូនចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ

- អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃ២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភម្តងគត់ ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញាដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- អនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃ១៦ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការកំណត់កាលបរិច្ឆេទនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍
- អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការកែសម្រួលតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ ២៦៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីការបង្កើនបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខណ្ឌយ ក្របខណ្ឌគ ឋានន្តរស័ក្តិទី៣ និងឋានន្តរស័ក្តិទី២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបន្ថែមប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិលកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និងអតីតយុទ្ធជន
- អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ប្តី និងកូនរបស់មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ
- អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិ សន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ ១១៤អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈជូនមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី
- អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរ

| | |
|---|---|
| | ដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយជានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>• សេចក្តីសម្រេចលេខ ២៤៥ សសរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពី របបគោលនយោបាយជានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់ សមត្ថភាពពលកម្ម<br>• សារាចរណែនាំ លេខ ០១១ ស.អ.យ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារជនពិការ និងគ្រួសារជនពលី គ្រួសារ ជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ<br>• សារាចរលេខ ០០៦ ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• សារាចរណែលេខ ០០៨ ស.អ.យ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>• សារាចរណែនាំលេខ ០០៦ ស.អ.យ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តិពីការបន្ថែមប្រាក់ សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រី រាជការស៊ីវិល<br>• សារាចរលេខ ០៤ សរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជន និងគ្រួសារ<br>• សេចក្តីណែនាំលេខ ០០៣ ស.អ.យ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការពង្រឹងការអនុវត្តរបបសោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• សារាចរណែនាំលេខ ០០៤ សរណេន.សអយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ប្តី និងកូនកំព្រារបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ សពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិល<br>• សារាចរណែនាំលេខ ០០២ សរណេន.សអយ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយជានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>• សារាចរណែនាំអនុវត្តលេខ ៣៣ យ.ស.សរណេន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៨៩ របស់ក្រសួងយុទ្ធជនពិការ សង្គមកិច្ច លើសេចក្តីសម្រេច២៤៥ សសរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយជានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាលបុគ្គលិកកម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម |

| | |
|---|---|
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | មន្ត្រីរាជការស៊ីវិល (រួមមានចៅក្រម និងព្រះរាជអាជ្ញា) និវត្តជន និងជនបាត់បង់សម្បទា វិជ្ជាជីវៈ (រួមមានអ្នកចូលនិវត្តន៍ដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយ) និងអ្នកនៅក្នុងបន្ទុកនៃជនទាំងនេះ |
| **ស្តង់ដាសេវា** | **មន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក**<br>• មន្ត្រីរាជការទទួលមរណភាពដោយជំងឺ ប្រាក់ឧបត្ថម្ភជូនគ្រួសារសព ចំនួន ០៦ខែ និង ប្រាក់បូជាសពចំនួន ១.២០០.០០០រៀល ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនកូនម្នាក់ ៥.០០០រៀល រហូតដល់អាយុ២១ឆ្នាំ (ក្រសួង ស.អ.យ គ្រប់គ្រង និងបើកផ្តល់បន្ត)<br>• មន្ត្រីរាជការស៊ីវិលទទួលមរណភាពដោយគ្រោះថ្នាក់ការងារ ឬបេសកកម្ម ប្រាក់ឧបត្ថម្ភ ជូនគ្រួសារសពចំនួន ៨ខែ និងប្រាក់បូជាសពចំនួន ១.៥០០.០០០រៀល ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនកូនម្នាក់ ៥.០០០ រៀល រហូតដល់ អាយុ ២១ឆ្នាំ (ក្រសួង ស.អ.យ គ្រប់គ្រង និងបើកផ្តល់បន្ត)<br>• លំហែមាតុភាពទទួលប្រាក់ឧបត្ថម្ភ ចំនួន ៦០០.០០០រៀល (ក្រសួង ស្ថាប័ន សាម៉ីទទួលបន្ទុកដោះស្រាយ)<br>• ការផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូងម្តងគត់ ជូនមន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ គឺជាបន្ទុកដោះស្រាយដោយក្រសួង ស្ថាប័ន សាម៉ី<br><br>**ចំពោះមន្ត្រីរាជការដែលចូលនិវត្តន៍**<br>- ប្រាក់ឧបត្ថម្ភមួយលើកដំបូង = បៀវត្សមូលដ្ឋាន X ៨ខែ<br>- ប្រាក់សោធនប្រចាំខែ = បៀវត្សមូលដ្ឋាន X អតីតភាពការងារ (៨០% អតីតភាពការងារអតិបរមា ៣០ឆ្នាំ និង ៦០% អតីតភាពការងារ អប្បបរមា ២០ឆ្នាំ )<br><br>**ចំពោះមន្ត្រីរាជការដែលចូលបាត់បង់សម្បទាវិជ្ជាជីវៈ**<br>- ប្រាក់ឧបត្ថម្ភមួយលើកដំបូង = បៀវត្សមូលដ្ឋាន X ៧ខែ<br>- ប្រាក់សោធនប្រចាំខែ = បៀវត្សមូលដ្ឋាន X អតីតភាពការងារ (៦៥% អតីតភាពការងារអតិបរមា ២៩ឆ្នាំ និង ៥០% អតីតភាពការងារ អប្បបរមា ២០ឆ្នាំ )<br><br>**និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក**<br>- និវត្តជនប្រាក់សោធនអតិបរមា ៧៤៨.០០០រៀល អប្បបរមា ៣៦៦.០០០រៀល ជនបាត់បង់សម្បទាវិជ្ជាជីវៈប្រាក់សោធនអតិបរមា ៦៣៦.៤៤៨ រៀល អប្បរមា ៣៦០.០០០ រៀល<br>- និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈទទួលមរណភាពប្រាក់សោធនសរុបចំនួន ១២ ខែ<br>- ប្រាក់ឧបត្ថម្ភសហព័ទ្ធ ៦.០០០រៀល និងរហូតដល់ទទួលមរណភាព ឬមានសហព័ន្ធថ្មី និងកូនម្នាក់ ៥.០០០រៀល រហូតដល់អាយុ ២១ឆ្នាំ មិនត្រូវភ្ជាប់លិខិតបញ្ជាក់ការសិក្សាទេ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | **ការទទួលបានប្រាក់ឧបត្ថម្ភដល់គ្រួសារសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាពដោយជំងឺ**<br>• លិខិតស្នើសុំឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសព និងស្នើសុំបន្តឧបត្ថម្ភប្រាក់គោលនយោបាយប្រចាំខែជូនកូនកំព្រាសពមន្ត្រីរាជការស៊ីវិល (បើមានកូននៅក្នុងបន្ទុក) ០២ច្បាប់ |

- លិខិតបញ្ជាក់សំបុត្រកំណើតកូន ០១ ច្បាប់
- ប្រកាសលុបឈ្មោះសពមន្ត្រីរាជការស៊ីវិល ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពពីអាជ្ញាធរមូលដ្ឋាន ០១ ច្បាប់
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ០១ ច្បាប់
- វិញ្ញាបនបត្រផ្តាច់ប្រាក់បៀវត្សរ៍របស់សព ០២ ច្បាប់
- តារាងទូទាត់ប្រាក់ធានារ៉ាប់រងសង្គម ០២ ច្បាប់

**ការទទួលបានប្រាក់ឧបត្ថម្ភដល់គ្រួសារសពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពដោយ គ្រោះថ្នាក់ការងារ និងបេសកកម្ម**

- លិខិតស្នើសុំឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសព និងស្នើសុំបន្តឧបត្ថម្ភប្រាក់គោលនយោបាយប្រចាំខែ ជូនកូនកំព្រាសពមន្ត្រីរាជការស៊ីវិល (បើមានកូននៅក្នុងបន្ទុក) ០២ច្បាប់
- លិខិតបញ្ជាក់សំបុត្រកំណើតកូន ០១ ច្បាប់
- ប្រកាសលុបឈ្មោះសពមន្ត្រីរាជការស៊ីវិល ០១ ច្បាប់
- លិខិតមរណភាព ០១ ច្បាប់
- លិខិតបញ្ជាបេសកកម្ម ឬ លិខិតឧទ្ទេសនាម ០១ ច្បាប់
- កំណត់ហេតុគ្រោះថ្នាក់ការងារ ឬពេលបំពេញបេសកកម្ម
- របស់អង្គភាពមានសមត្ថកិច្ច ០១ ច្បាប់
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ០១ ច្បាប់
- វិញ្ញាបនបត្រផ្តាច់ប្រាក់បៀវត្សរ៍របស់សព ០២ ច្បាប់
- តារាងទូទាត់ប្រាក់ធានារ៉ាប់រងសង្គម ០២ ច្បាប់

ចំពោះការឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសពមន្ត្រីរាជការស៊ីវិល និងលំហែមាតុភាព ទទួលបន្ទុកដោះស្រាយដោយក្រសួង ស្ថាប័នសាមីដោយមានការឯកភាពជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការទទួលបានប្រាក់ឧបត្ថម្ភរបស់មន្ត្រីរាជការស៊ីវិលពេលលំហែមាតុភាព(បច្ចុប្បន្ន ក្រសួង ស្ថាប័នសាមីជាអ្នកអនុវត្ត)

- លិខិតស្នើសុំប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម ០១ ច្បាប់
- លិខិតបញ្ជាក់ថាបានសំរាលកូនចេញពីមន្ទីរពេទ្យ ឬពី
- អង្គភាព ដែលគ្រប់គ្រងសាមីជន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតកូនពីអាជ្ញាធរមូលដ្ឋាន ០១ ច្បាប់ ការចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈរបស់មន្ត្រីរាជការស៊ីវិល
- ពាក្យស្នើសុំឧបត្ថម្ភរបបសន្តិសុខសង្គមប្រចាំខែជូននិវត្តជន
- និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់
- ប្រកាសឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ (ច្បាប់ដើម១) ០២ ច្បាប់
- សលាកបត្រមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ ០១ ច្បាប់
- ពាក្យសុំចូលនិវត្តន៍របស់អ្នករាជការដែលមានអតីតភាពការងារ ៣០ឆ្នាំ
- ឡើងទៅមិនទាន់គ្រប់អាយុ ហើយស្ម័គ្រចិត្តចូលនិវត្តន៍ ០១ច្បាប់
- វិញ្ញាបនបត្របញ្ជាក់បាត់បង់សម្បទាវិជ្ជាជីវៈចេញដោយគណៈកម្មការវាយតម្លៃសុខភាព បើអ្នករាជការនោះបាត់បង់សម្បទាវិជ្ជាជីវៈ ០១ច្បាប់
- កំណត់ហេតុស្តីពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម បើអ្នករាជការ
- នោះទទួលគ្រោះថ្នាក់ដោយបំពេញការងារ ០១ ច្បាប់
- រូបថត ៦សម គុណ ៤សម ០៣សន្លឹក

| | |
|---|---|
| | **ការទទួលបានប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជា ជីវៈ និងបន្តការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនអ្នកនៅក្នុងបន្ទុក**<br>• សំណើសុំលុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• សំណើសុំឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសព<br>• តារាងរៀបរាប់ស្ថានភាពគ្រួសារសព<br>• សេចក្តីចម្លងសំបុត្រមរណភាព<br>• សៀវភៅនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>• វិញ្ញាបនបត្រផ្តាច់ប្រាក់សោធននិវត្តន៍ ឬសោធនបាត់បង់សម្បទាវិជ្ជាជីវៈ |
| **យោបល់** | ក្រោយពីអ្នកស្នើសុំបានបំពេញលក្ខខណ្ឌដែលបានកំណត់តាមគោលការណ៍ ដូចមានចែងក្នុងចំណុច "តម្រូវការឯកសារដើម្បីទទួលបានសេវា" រួចហើយ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនឹងផ្តល់សេវា ជូនតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធ ភាព និងមានការទទួលខុសត្រូវខ្ពស់។ នាពេលអនាគត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនឹងពង្រីកសេវាបន្ថែមទៀត ដើម្បីជួយកាត់បន្ថយការលំបាករបស់មុខសញ្ញា |

## កម្មវិធីជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពសង្គម<br>- ទូរស័ព្ទ : (៨៥៥)២៣ ២១២ ៦៧៣<br>• ការិយាល័យ សង្គ្រោះសង្គម<br>- ទូរស័ព្ទ : (៨៥៥)១៥ ៣៨២ ៣៣៣<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• មន្ទីរស.អ.យ រាជធានី ខេត្ត និងការិយាល័យស.អ.យ ក្រុង ស្រុក ខណ្ឌ |
| គោលបំណងនៃការផ្តល់សេវា | កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ ជាសេវាកម្មសាធារណៈរបស់ក្រសួង ស.អ.យ ត្រូវបានបង្កើតឡើងក្នុងគោលបំណងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជួយសម្រាលទុក្ខលំបាកជីវភាពរស់នៅ និងកាត់បន្ថយជនរងគ្រោះ និងងាយរងគ្រោះរបស់ប្រជាជនក្រីក្រនៅក្នុងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | • សារាចរណែនាំ លេខ ០០២ ស.អ.យ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីកម្មវិធីជំនួយសង្គ្រោះបន្ទាន់ ដល់ជនរងគ្រោះដោយដាច់ស្បៀងទីទ័លក្រ គ្រោះធម្មជាតិ និង គ្រោះមហន្តរាយដោយយថាហេតុ ចំណាក ស្រុក អនាថា និងវិកលចរិតនៅតាម សហគមន៍ ដោយមានភ្ជាប់ឧបសម្ព័ន្ធ លេខ ០១ ដល់លេខ ០៧ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | • ប្រជាជនជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍<br>• ជនចំណាកស្រុក ជនអនាថា និងជនវិកលចរិត |
| ស្តង់ដាសេវា | ប្រជាជនជាជនងាយរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះដោយធម្មជាតិ គ្រោះមហន្តរាយដោយយថាហេតុ ត្រូវបានជួយសង្គ្រោះតាមប្រភេទ និងកម្រិតដូចខាងក្រោម ៖<br>**ប្រភេទ១ ៖ កម្រិតធ្ងន់**<br>• ប្រជាជនរងគ្រោះ ទីទ័លក្រ ដាច់ស្បៀង គ្មានមុខរបរ គ្មានដីធ្លីដាំដុះ គ្មានជម្រកស្នាក់នៅ ឬមេគ្រួសារជាស្ត្រីមេម៉ាយមានកូនច្រើនក្នុងបន្ទុកពុំមានលទ្ធភាពឱ្យកូនទៅសិក្សា ឬមេគ្រួសារជាជនពិការ ជនចាស់ជរា ជនមានជំងឺរ៉ាំរ៉ៃ ហើយមានក្មេងក្នុងបន្ទុកពុំមាន លទ្ធភាពឱ្យក្មេងទៅសិក្សា។ ត្រូវពិនិត្យលទ្ធភាពផ្តល់ជំនួយគាំទ្រដោយគិតចំនួនសមាជិក គ្រួសារតាមជំហានដូចខាងក្រោម ៖<br>- ជំហានទី១ ៖ ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាសម្ភារប្រើៈប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ៥០០.០០០ រៀល ក្នុងមួយគ្រួសារ និង ផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែង ដូចជា អង្ករ អំបិល មី មុង ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។<br>- ជំហានទី២ ៖ ត្រូវផ្តល់ជំនួយគាំទ្រសម្រាប់ការស្តារនីតិសម្បទា ដើម្បី |

| | |
|---|---|
| | ជនរងគ្រោះមានស្បៀងភាពស្បៀង សម្រាប់ជីវភាពប្រចាំថ្ងៃក្នុងរយៈ ពេល ៣០ថ្ងៃ និងផ្តល់សម្ភារៈសម្រាប់ជួសជុលផ្ទះ ឬសាងសង់ជម្រកស្នាក់នៅបណ្តោះអាសន្នដោយគិត ជាថវិកាមិនលើសពីចំនួន ១.៥០០.០០០ រៀល ក្នុងមួយគ្រួសារ។<br><br>**ប្រភេទ១ ៖ កម្រិតមធ្យម**<br>• ជនរងគ្រោះទីទ័លក្រ ដាច់ស្បៀង ខូចខាតបាត់បង់ទ្រព្យសម្បត្តិ ផ្ទះសម្បែង ប៉ះពាល់ មុខរបរ ឬសុខភាព និងខូចខាតផលដំណាំ ។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ម្តងគត់ ជាសម្ភារៈប្រើប្រាស់ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ៣០០.០០០រៀល ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែង រួមមាន ៖ អង្ករ អំបិល មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។<br><br>**ប្រភេទ១ ៖ កម្រិតស្រាល**<br>• ជនរងគ្រោះដែលទទួលនូវការខូចខាតបាត់បង់ទ្រព្យសម្បត្តិ ឬផលដំណាំតិចតួច ។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ម្តងគត់ ជាសម្ភារៈប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ២០០.០០០ រៀល ក្នុងមួយ គ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែង រួមមាន ៖ អង្ករ អំបិល មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • សំណើរបស់ប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត យោងតាមតារាងគំរូឧបសម្ព័ន្ធ<br>• សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ |
| **យោបល់** | ជំរុញការស្តារនីតិសម្បទា និងសមាហរណកម្មក្នុងសង្គមជាតិចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទទួលផ្លែផ្កានៃការអភិវឌ្ឍប្រកបដោយសមធម៌។ លើកកម្ពស់សេវាសង្គមកិច្ចឈានជាជំហានៗពីការផ្តល់ជំនួយសង្គ្រោះទៅជាការរៀបចំឱ្យមានប្រព័ន្ធសន្តិសុខសង្គម ការធានារ៉ាប់រងសង្គមដើម្បីធានាសុខុមាលភាពសង្គមជូនប្រជាជនតាមលទ្ធភាពសេដ្ឋកិច្ចជាតិដោយចាត់ទុកជាយុទ្ធសាស្ត្រសំខាន់ នៃគោលការណ៍បែងចែកភោគផលដោយសមធម៌ ។ |

## ការផ្តល់សេវាថែទាំ គាំទ្រ ដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពសង្គម<br>• ការិយាល័យសេវាការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ<br>- អាសយដ្ឋាន : អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទនាយកដ្ឋាន : (៨៥៥)២៣ ២១២ ៦៧៣<br>- ទូរស័ព្ទការិយាល័យ : (៨៥៥)១២ ៧៧៦ ៨៦០<br>- អ៊ីម៉ែល : mosvy_me@yahoo.com<br>• មន្ទីរ ស.អ.យ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| គោលបំណង នៃការផ្តល់សេវា | ដើម្បីទប់ស្កាត់ការរីករាលដាលដោយសារមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយមេរោគអេដស៍ ជំងឺអេដស៍និងជំងឺកាចសាហាវផ្សេងៗ និងជួយឱ្យជនរងគ្រោះនិងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទទួលបាននូវសេវាថែទាំ និងគាំទ្រប្រកបដោយប្រសិទ្ធភាព។ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យ លេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមណ្ឌលរបស់រដ្ឋ<br>• ប្រកាសលេខ ១២២៨ ស.អ.យ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាភាព និងតួនាទី ភារកិច្ចរបស់ការងារថ្នាក់ជាតិពហុវិស័យស្តីពី កុមារកំព្រា និងកុមារងាយរងគ្រោះ<br>• ប្រកាសលេខ ០១០ ស.អ.យ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការចាត់តាំងក្រុមការងារ ដើម្បីអនុវត្តកម្មវិធីមូលនិធិសកលជុំទី៧<br>• ប្រកាសលេខ ១១៩ ស.អ.យ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈ កម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា<br>• ប្រកាសលេខ ១៦៩១ ស.អ.យ. ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវ ផ្សេងៗនៅតាមសហគមន៍ |
| ស្តង់ដាសេវា | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវ ផ្សេងៗនៅតាមសហគមន៍ ត្រូវទទួលសេវាថែទាំ និងគាំទ្រដូចខាងក្រោម ៖<br>**១- ទារក កុមារមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលត្រូវទទួលរបបឧបត្ថម្ភដូចខាងក្រោម:**<br>- ទារកអាយុ ០២ឆ្នាំចុះ ទទួលរបបថ្លៃទឹកដោះគោ ក្នុង១ខែ ៦០.០០០ |

| | |
|---|---|
| | រៀល និងថ្លៃសំលៀកបំពាក់ សម្ភារៈដំណេក អនាម័យ និងព្យាបាល ១ ដងក្នុង ០១ឆ្នាំ ១២០.០០០ រៀល ( ទទួលពេលដើមឆ្នាំ )<br>- កុមារអាយុលើសពី ០២ឆ្នាំ ទទួលរបបឧបត្ថម្ភថ្លៃម្ហូបអាហារ ០១ខែ ៤៥.០០០រៀល ថ្លៃសំលៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១ដង ក្នុង១ឆ្នាំ ១២០.០០០ រៀល ( ទទួលពេលដើមឆ្នាំ )<br>- ទារកកុមារទទួលរបបបំប៉នសុខភាពបន្ថែមក្នុង០១ខែ ២០.០០០ រៀល<br>- ទារក កុមារអាយុ ៥ឆ្នាំចុះ ទទួលមរណភាពឧបត្ថម្ភម្តងគត់ សម្រាប់រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ ៦ខែ ( ២៧០.០០០ រៀល )<br>- កុមារអាយុលើសពី ៥ឆ្នាំឡើង ទទួលមរណភាពឧបត្ថម្ភម្តងគត់សម្រាប់រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ ១២ខែ ( ៥៤០.០០០រៀល )<br>**២- កុមាររងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺអេដស៍ កុមារកំព្រា កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ ជនពិការមានជំងឺអេដស៍ ជនពិការ អនាថាមានជំងឺអេដស៍ ។ កុមារមានអាយុក្រោម ០៥ឆ្នាំ គ្រួសារមានសមាជិករស់នៅជាមួយមេរោគអេដស៍ ឬទទួលផលប៉ះពាល់ដោយជំងឺអេដស៍ គ្រួសារដែលមានអាណាព្យាបាល ជាមនុស្សចាស់ និងមិនអាចមានសមត្ថភាពធ្វើការងារ ឬគ្រួសារដែលមានកុមារជាមេគ្រួសារ ត្រូវទទួលកញ្ចប់ស្បៀងអាហារបន្ទាន់មាន ៖**<br>- អង្ករចំនួន ៣០ គីឡូក្រាម<br>- ប្រេងឆា ចំនួន ១ លីត្រ<br>- អំបិលអ៊ីយ៉ុត ចំនួន ១/២ គីឡូក្រាម<br>- ប្រូតេអ៊ីនបន្ថែម ( ស៊ុត សៀង សាច់ងៀត ឬត្រីខកំប៉ុង ) |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | • ទម្រង់របាយការណ៍<br>• ទម្រង់ស្ថិតិជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និង ជំងឺកាចសាហាវផ្សេងៗ<br>• ទម្រង់ទិន្នន័យជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗដែលទទួលបានសេវាថែទាំ និងគាំទ្រ<br>• សំណើរបស់ប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត |
| **យោបល់** | ដើម្បីឆ្លើយតបនឹងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ ប្រកបដោយ ប្រសិទ្ធភាពខ្ពស់ ៖<br>• ត្រូវរៀបចំអនុក្រឹត្យ ស្តីពីការផ្តល់របបជំនួយឧបត្ថម្ភដល់ជនរងគ្រោះ និងរងផលប៉ះ ពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ ដែលទីទ័លក្រ គ្មានទីពឹង និងគ្មាន ជម្រក<br>• បង្កើតក្រុមការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃ<br>• សិក្សា ស្រាវជ្រាវពីបញ្ហាប្រឈម និងរកដំណោះស្រាយដែលសមស្របដល់ជនរង គ្រោះ និងរងផលប៉ពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ |

# ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

| | |
|---|---|
| ឈ្មោះសេវា | ការបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• បេឡាជាតិអតីតយុទ្ធជន "ប.ជ.អ."<br>- អាស័យដ្ឋាន : លេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ (បន្ទប់ A2-01)<br>- ទូរស័ព្ទ : ០២៣ ២១៣ ៥៨០<br>- អ៊ីមែល : nfv.info@gmail.com or nfv_gov@yahoo.com<br>- គេហទំព័រ : www.nfv.gov.kh |
| គោលបំណង នៃការផ្តល់សេវា | បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឱ្យបានឆាប់រហ័ស និងមានតម្លាភាព |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យច្បាប់លេខ ១០ ក្រ.ច ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជាដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា<br>• ព្រះរាជក្រមលេខ០៧ នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ<br>• ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០០៦ វិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ<br>• ព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ១១៥ អនក្របក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងបាត់បង់សមត្ថភាពការងារ<br>• អនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលីមរណៈ បង្គស្លាប់ បាត់ខ្លួន និងជនពិការ<br>• អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការបន្ថែមបៀវត្ស ជូនកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលបៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ<br>• អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ឬប្តី និងកូនរបស់មន្ត្រីរាជការស៊ីវិលកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ<br>• អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការបន្ថែមបៀវត្ស ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិលកងយោធពលខេមរភូមិន្ទ |

| | |
|---|---|
| | កងកម្លាំងនគរបាលជាតិ និងនិវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម យុទ្ធជនពិការដែលជាមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទកងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និងអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងជនពិការ<br>• អនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការបន្ថែមបៀវត្ស ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• អនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បង់សមត្ថភាពពលកម្ម ដែលជាអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃ ឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ<br>• អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០ ស្តីពីការកែសម្រួល ការអនុវត្តការបើកប្រាក់សោធន ចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលីគ្រួសារជនមរណៈដែលទទួលមុខតំណែងជាអ្នកនយោបាយ<br>• អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡា ជាតិអតីតយុទ្ធជន<br>• អនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការកែសម្រួល ការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បត់ាបង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ<br>• អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាន និងការបើកផ្តល់បៀវត្សដល់យោធិននៃកងយោធពលខេមរភូមិន្ទ<br>• អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាន និងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិ<br>• អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតម្លៃនៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា |

| | |
|---|---|
| | • សេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩១របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីរបបគោលនយោបាយចំពោះជនពលី ពិការ<br>• សេចក្តីសម្រេចលេខ៥២ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយជានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>• ប្រកាសអន្តរក្រសួងលេខ ១៨០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការកំណត់ និងកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែជូនកូនរបស់គ្រួសារជនពលី និងមរណៈ<br>• ប្រកាសអន្តរក្រសួងលេខ ១២៩ ប្រកអន ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការកំណត់អំពីបែបបទផ្ទេរប្រគល់ការគ្រប់គ្រងចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• ប្រកាសអន្តរក្រសួងលេខ ១២៨ ប្រកអន ចុះថ្ងៃទី០៧ ខែវិច្ឆកា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារចំពោះយោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ<br>• ប្រកាសអន្តរក្រសួងលេខ ១៨៧៧ ប្រក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកំណត់បែបបទផ្ទេរ ប្រគល់ការគ្រប់គ្រង និវត្តជន និងជនបាត់បង់សមត្ថភាពការងារ<br>• ប្រកាសលេខ ៦៧៨ ស.អ.យ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីនីតិវិធីអនុវត្ត របបឧបត្ថម្ភគោលនយោបាយចំពោះ ជនពលី មរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ<br>• ប្រកាសលេខ ១៥៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ស្តីពីនីតិវិធីកំណត់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការ<br>• ប្រកាសលេខ ៤៣០ ស.អ.យ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៦ ស្តីពីប្រាក់ឧបត្ថម្ភគោលនយោបាយជានារ៉ាប់រងសង្គមសម្រាប់ជនពិការជាអតីតយុទ្ធជន<br>• សារាចរណែនាំអន្តរក្រសួងលេខ ០០១/២០០៧ សរណ.អក ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ២០០៧ ស្តីពី ការអនុវត្តអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ<br>• សារាចរណែនាំអន្តរក្រសួងលេខ ០០១ សរណ.សអយ.សហវ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពី ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសារជនមរណៈ<br>• សារាចរណែនាំអន្តរក្រសួងលេខ០០១ ស.រ.ណ.ន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ<br>• សារាចរណែនាំអន្តរក្រសួងលេខ ០២១ ស.អ.យ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ<br>• សារាចរណែនាំលេខ ០០៣ ស.អ.យ. ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តី |

ពីការដំឡើងប្រាក់របប ១៥% ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន

- សារាចរណែនាំលេខ ០០៥ ស.អ.យ.ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧ ស្តីពីការអនុវត្តប្រកាសអន្តរក្រសួងលេខ១៨០ សហវ ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការកំណត់កែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែជូនកូនជនពលី និងមរណៈ
- សេចក្តីណែនាំលេខ០១១ស.អ.យ.ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការអនុវត្តសារាចរណែនាំអន្តរក្រសួងលេខ០០១ សរណ. សអយ.សហវ
- សារាចរណែនាំលេខ ០០៥ ស.អ.យ.ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ឬប្តី កូនជនពិការ ជនពលីជន មរណៈ និវត្តជន និងជន បាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០០៧ ស.អ.យ. ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការបន្ថែមប្រាក់ ២០% ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០០៩ សអយ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន
- ប្រកាសលេខ៨៤២ ស.អ.យ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យផ្ទៀងផ្ទាត់មុខសញ្ញាអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ
- សារាចរណែនាំលេខ ០០៦ ស.អ.យ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបន្ថែមប្រាក់ ២០% ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ
- សារាចរណែនាំលេខ ០០២ ស.អ.យ. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០០១ ស.អ.យ.ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារដែលជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០០៨ ស.អ.យ. ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការបង្កើនប្រាក់ ២០% ជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០១១ ស.អ.យ.ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ស្តីពីការបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលីគ្រួសារជនមរណៈដែលទទួលមុខតំណែងជាអ្នកនយោបាយ
- សារាចរណែនាំលេខ ០១៤ ស.អ.យ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការពង្រឹងការងារបើកផ្តល់ប្រាក់ឧបត្ថម្ភជូនអតីតយុទ្ធជន
- សារាចរណែនាំលេខ០១៥ ស.អ.យ. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តី

| | |
|---|---|
| | ពីវិធានការដោះស្រាយការទិញ បញ្ចាំ លក់ របបសន្តិសុខសង្គមរបស់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការ<br>• សារាចរណែនាំលេខ ០១៧ ស.អ.យ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការកំណត់របបឧបត្ថម្ភ១លើកដំបូងជូនគ្រួសារជនពលី គ្រួសារជនមរណៈ និងជនពិការដែលជាអតីតយុទ្ធជន<br>• សេចក្តីណែនាំលេខ ០០១ ស.អ.យ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារអតីតយុទ្ធជនរួមមាន ៖<br>- ជនពលី<br>- ជនមរណៈ<br>- ជនពិការ<br>- និវត្តជន<br>- ជនបាត់បង់សមត្ថភាពការងារ និង<br>- គ្រួសាររបស់អតីតយុទ្ធជន |
| **ស្តង់ដាសេវា** | **១. និវត្តជនទទួលបាន ៖**<br><u>យោធិន</u><br>- ប្រាក់ឧបត្ថម្ភគោលនយោបាយចំនួន ៨ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់សោធន ពី៥០% ទៅ ៨០% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន) + ប្រាក់អាទិភាព ១៥% ទៅ ២០% នៃបៀវត្សឋានន្តរសក្តិ(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្សឋានន្តរសក្តិ<br><u>នគរបាលជាតិ</u><br>- ប្រាក់ឧបត្ថម្ភគោលនយោបាយ ៨ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់សោធន ៨០% នៃបៀវត្សឋានន្តរសក្តិ + ២% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន) + ប្រាក់អាទិភាព ១៥% ទៅ ២០% នៃបៀវត្សឋានន្តរសក្តិ(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្សឋានន្តរសក្តិ<br>**២. ជនបាត់បង់សមត្ថភាពទទួលបាន ៖**<br><u>យោធិន</u><br>- ប្រាក់ឧបត្ថម្ភគោលនយោបាយ ៦ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ៖<br>  ○ កម្រិតទី១: ប្រាក់សោធន ១០០% នៃបៀវត្សឋានន្តរសក្តិ + អ្នកបម្រើ(ស្មើពលទោ) + ប្រពន្ធ + កូន + តំបន់(បើមាន)<br>  ○ កំរិតទី២: ប្រាក់សោធន ពី៥០% ទៅ ៦០% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្សឋានន្តរសក្តិ |

| | |
|---|---|
| | <u>នគរបាលជាតិ</u><br>- ប្រាក់ឧបត្ថម្ភគោលនយោបាយ ៦ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ៖<br>  ○ កម្រិតទី១: ប្រាក់សោធន ៧០% នៃបៀវត្សឋាននន្តរសក្តិ + ៥០% នៃបៀវត្សឋាននន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន)<br>  ○ និងកំរិតទី២: ប្រាក់សោធន ពី៥០% ទៅ ៦០% នៃបៀវត្សឋាននន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ជានារ៉ាប់រងសង្គម ចំនួន ១២ខែ នៃបៀវត្សឋាននន្តរសក្តិ<br>**៣. ពិការភាពទទួលបាន ៖**<br>- ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ៖<br>  ○ សម្រាប់ជនពិការជាអតីតយោធិន និងនគរបាលជាតិ ៖ ប្រាក់ឧបត្ថម្ភប្រចាំខែ = ប្រាក់បៀវត្សសរុប(បៀវត្សឋាននន្តរសក្តិ + ម្ហូប + តំបន់(បើមាន) + កូន + ប្រពន្ធ ឬប្តី) + ប្រាក់ជំនួយមុខរបួស + ប្រាក់បន្ថែមភាគរយ + ប្រាក់អ្នកបម្រើ(បើជាជនពិការថ្នាក់ទី១)<br>  ○ សម្រាប់ជនពិការជាអតីតមន្ត្រីរាជការស៊ីវិល ៖ ប្រាក់ឧបត្ថម្ភប្រចាំខែ = ប្រាក់បៀវត្សសរុប(បៀវត្សមូលដ្ឋាន + តំបន់(បើមាន) + កូន + ប្រពន្ធ ឬប្តី) + ប្រាក់ជំនួយមុខរបួស + ប្រាក់បន្ថែមភាគរយ + ប្រាក់អ្នកបម្រើ(បើជាជនពិការថ្នាក់ទី១)<br>  ○ សម្រាប់ជនពិការជាអតីតកងសេនាជន កងជីវពល ពលករ និងប្រជាពលរដ្ឋ ៖ ប្រាក់ឧបត្ថម្ភប្រចាំ = ប្រាក់ជំនួយមុខរបួស + ប្រាក់បន្ថែមភាគរយ + កូន + ប្រពន្ធ + អ្នកបម្រើ(បើជាជនពិការថ្នាក់ទី១)<br>- ក្រោយពេលទទួលមរណភាព ៖<br>  ○ ជនពិការប្រភេទ ក ជាយោធិន និងមន្ត្រីនគរបាលជាតិ ៖ ត្រូវបន្តបើកប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣ខែ ជូនគ្រួសារសព ហើយទទួលបានប្រាក់បូជាសពចំនួន ៩ខែ នៃប្រាក់ឧបត្ថម្ភប្រចាំខែចុងក្រោយរបស់សាមីជន និងប្រាក់ឧបត្ថម្ភមួយលើកចំនួន ១៥ខែ នៃបៀវត្សសរុប<br>  ○ ជនពិការប្រភេទ ក ជាសេនាជន ៖ ត្រូវបន្តបើកប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣ខែជូនគ្រួសារសព ហើយទទួលបានប្រាក់បូជាសពចំនួន ១,២០០,០០០រៀល ប្រាក់ជូនដំណឹង ជនពលីចំនួន ៣ខែ នៃប្រាក់ស្មើពលទោ និងប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ នៃប្រាក់ស្មើពលទោ<br>- ជនពិការប្រភេទ ខ ៖ ត្រូវបន្តបើកប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣ខែ ជូនគ្រួសារសព ហើយទទួលបានប្រាក់បូជាសពចំនួន ៧ខែ នៃប្រាក់ឧបត្ថម្ភប្រចាំខែចុងក្រោយរបស់សាមីជន និងប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ នៃបៀវត្សសរុប។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | **ទទួលស្គាល់អតីតយុទ្ធជនថ្មីដែលផ្ទេរពីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ពន្ធ័** |

| | |
|---|---|
| | - លិខិតផ្ទេរអតីតយុទ្ធជនគ្រប់ប្រភេទ (០២ច្បាប់)<br>- ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសចេញពីជួរ (០២ច្បាប់)<br>- បញ្ជីរាយនាម (០២ច្បាប់)<br>- លិខិតទទួលស្គាល់ (០២ច្បាប់)<br>- វិញ្ញាបនបត្របញ្ជាក់កម្រិតបាត់បង់សមត្ថភាពការងារ (០២ច្បាប់)<br>- លិខិតឧទ្ទេសនាមផ្តត់ផ្គង់ហិរញ្ញវត្ថុ (០២ច្បាប់)<br>- ជីវៈប្រវត្តិសង្ខេប (០២ច្បាប់)<br>- លិខិតចម្លងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសចេញពីជួរ (០២ច្បាប់)<br><br>**លុបអតីតយុទ្ធជនគ្រប់ប្រភេទ**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត (០២ច្បាប់)<br>- តារាងឧបសម្ព័ន្ធ (០២ច្បាប់)<br>- លិខិតទទួលស្គាល់ជនពលី ឬជនមរណៈ (០២ច្បាប់)<br>- ប្រវត្តិរូបសង្ខេប (០២ ច្បាប់)<br>- តារាងបញ្ជាក់ប្រាក់ឧបត្ថម្ភប្រចាំខែ (០២ច្បាប់)<br>- សេចក្តីចម្លងសំបុត្រមរណភាព (០២ច្បាប់)<br>- ប្រកាសទទួលស្គាល់ និងតារាងឧបសម្ព័ន្ធ របស់ក្រសួង (០២ច្បាប់)<br><br>**បញ្ចូលប្រពន្ធ ឬ ប្តី និងកូនរបស់ជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត (០២ច្បាប់)<br>- តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមអតីតយុទ្ធជន និងគ្រួសារ (០២ ច្បាប់)<br>- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្រកំណើត (០២ច្បាប់)<br>- លិខិតបញ្ជាក់ការសិក្សា (០២ច្បាប់)<br><br>**ផ្ទេរអតីតយុទ្ធជនគ្រប់ប្រភេទពីរាជធានី ខេត្តមួយ ទៅរាជធានី ខេត្តមួយទៀត**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត (០២ច្បាប់)<br>- តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមអតីតយុទ្ធជន (០២ច្បាប់)<br>- សៀវភៅបើកប្រាក់ និងសាលាកបត្រ (០២ច្បាប់)<br>- សំណុំលិខិតរបស់សាមីខ្លួន ច្បាប់ដើម<br>- ពាក្យស្នើសុំផ្ទេររបស់សាមីខ្លួន (០២ច្បាប់)<br>- ប្រកាសទទួលរបស់ក្រសួង ស.អ.យ (០២ច្បាប់)<br><br>**បើកប្រាក់របបសន្តិសុខសង្គម និងប្រាក់ឧបត្ថម្ភផ្សេងៗជូនអតីតយុទ្ធជន និងគ្រួសារអតីត យុទ្ធជន**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត (០២ច្បាប់)<br>- តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមរបស់អតីតយុទ្ធជន (០២ច្បាប់)<br>- ប្រកាសទទួលស្គាល់ និងផ្តល់របបឧបត្ថម្ភ |
| យោបល់ | |

# ការផ្តល់អាជ្ញាបណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់អាជ្ញាបណ្ណដក់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>• រដ្ឋបាលសុំកូនអន្តរប្រទេស<br>- អាសយដ្ឋាន : អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : ០២៣ ២១១ ៨៤៨<br>- អ៊ីមែល : info@icca-cambodia.com.kh<br>- គេហទំព័រ: www.icca-cambodia.com.kh |
| គោលបំណង នៃការផ្តល់សេវា | ទីភ្នាក់ងារដែលទទួលបានការអនុញ្ញាតឲ្យផ្តល់សេវាសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអាចស្វែងរកគ្រួសារចិញ្ចឹមមួយដ៏ល្អក្នុងន័យជានាឧត្តមប្រយោជន៍របស់កុមារជាចម្បង |
| មូលដ្ឋានគតិយុត្ត | • អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារដែលកម្ពុជាជាសមាជិក ប្រកាសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩២ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>• ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តឲព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស<br>• ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស<br>• ប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ប្រកាសលេខ ១៩៨០ សរបស់ ២០១៤ខែសីហា ឆ្នាំ ០៧អ.យ ចុះថ្ងៃទី. សង្គមក្រសួងកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | • ទីភ្នាក់ងារដែលមានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារ<br>• ទីភ្នាក់ងារមានការអនុញ្ញាតពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារ ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>• ទីភ្នាក់ងារនីមួយៗ ត្រូវចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល។ទីភ្នាក់ងារមិនមានបើកមណ្ឌលកុមារកំព្រា ឬ ប្រើប្រាស់មណ្ឌលកុមារកំព្រា ដើម្បីជាប្រភពផ្តល់ទារក និងកុមារកំព្រាសម្រាប់សុំកូនអន្តរប្រទេស<br>• ប្រទេសរបស់ទីភ្នាក់ងារជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។ |

<table>
<tr>
<td>ស្តង់ដាសេវា</td>
<td>
<ul>
<li>ទីភ្នាក់ងារត្រូវបានអនុញ្ញាតឲ្យផ្តល់សេវាស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកបដោយសុច្ចរិតភាព ជំនឿទុកចិត្ត អភិបាលកិច្ចល្អ សមត្ថភាពវិជ្ជាជីវៈ គណនេយ្យភាព និងក្រមសីលធម៌</li>
<li>តម្លៃសេវាសម្រាប់ការផ្តល់ ឬបន្តសុពលភាពអាជ្ញាប័ណ្ណស្មុំកូនអន្តរប្រទេស រយៈពេលផ្តល់ និងសុពលភាពអាជ្ញាប័ណ្ណត្រូវកំណត់ ដូចខាងក្រោមៈ</li>
</ul>
<table>
<tr><th>ល.រ</th><th>បរិយាយ</th><th>តម្លៃសេវា(៛)</th><th>សុពលភាព</th></tr>
<tr><td>១</td><td>កាផ្តល់អាជ្ញាបណ្ណ</td><td>១២.០០០.០០០</td><td>២ឆ្នាំ</td></tr>
<tr><td></td><td>សេវារដ្ឋបាលពិនិត្យសំណុំឯកសារ</td><td>២០០.០០០</td><td></td></tr>
<tr><td></td><td>សេវាផ្តល់អាជ្ញាបណ្ណ</td><td>១០.០០០.០០០</td><td></td></tr>
<tr><td>២</td><td>បន្តសុពលភាពអាជ្ញាបណ្ណ</td><td>២.០០០.០០០</td><td>២ឆ្នាំ</td></tr>
</table>
</td>
</tr>
<tr>
<td>តម្រូវការឯកសារ<br>ដើម្បីទទួលបានសេវា</td>
<td>
<ul>
<li>សំណុំឯកសាររបស់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសមានដូចខាងក្រោមៈ
<ol>
<li>ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារ និងមានបិទតែមប្រិ៍សារពើពន្ធតម្លៃ ៥.០០០៛</li>
<li>ច្បាប់ចម្លងលិខិតបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិរបស់ទីភ្នាក់ងារ (នៅមានសុពលភាព) ចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ</li>
<li>ច្បាប់ចម្លងឯកសារអនុញ្ញាតឲ្យបើកទីភ្នាក់ងារដែលមានទិសដៅមិនស្វែងរកផលចំណេញដោយមានការបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ</li>
<li>លិខិតរបស់អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារដែលអនុញ្ញាតឲ្យទីភ្នាក់ងារធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។</li>
<li>លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ</li>
<li>ឯកសាសង្ខេបអំពីប្រវត្តិ សកម្មភាព កម្មវិធី និងសេវារបស់ទីភ្នាក់ងារ បញ្ជីរាយនាមបុគ្គលិក និងលក្ខណសម្បត្តិរបស់បុគ្គលិកទាំងនោះ រួមទាំងភ័ស្តុតាងដែលបង្ហាញអំពីបទពិសោធន៍ក្នុងវិស័យស្មុំកូនអន្តរប្រទេសយ៉ាងតិច ៥ឆ្នាំ</li>
<li>របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយដែលមានធ្វើសវនកម្មដោយសវនករឯករាជ្យ រួមមាន ប្រភពមូលនិធិ សោហ៊ុយស្មុំកូន និងថ្លៃចំណាយនានា ទាក់ទងនឹងស្មុំកូនអន្តរប្រទេស</li>
<li>ប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ ៤សម x ៦សម របស់សមាជិកក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រងទីភ្នាក់ងារ</li>
<li>ប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ ៤សម x ៦សម របស់បុគ្គលិកមួយនាក់ ឬពីរនាក់ ដែលបានទទួលការអនុញ្ញាតឲ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារលើការងារស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា</li>
<li>ឯកសារភ័ស្តុតាងនានាដែលបញ្ជាក់ថា អ្នកតំណាងដូចមានចែងក្នុងចំណុច ៩ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេដើមរបស់ខ្លួន និងនៅប្រទេសចុងក្រោយដែលខ្លួនកំពុងរស់នៅ ប្រសិនបើប្រទេសខុសគ្នា</li>
</ol>
</li>
</ul>
</td>
</tr>
</table>

| | |
|---|---|
| | 11. ច្បាប់ចម្លងឯកសារចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដោយមានការបញ្ជាក់ត្រឹមត្រូវពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>12. ច្បាប់ចម្លងឯកសារកិច្ចព្រមព្រៀងពីអតីតកាល ឬបច្ចុប្បន្នកាលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការផ្តល់ជំនួយមនុស្សធម៌ ឬការជួយឧបត្ថម្ភដល់កុមារកំព្រានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>13. ច្បាប់ចម្លងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងប្រទេសរបស់ទីភ្នាក់ងារ ប្រសិនបើប្រទេសនេះមិនមែនជាប្រទេសភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស<br>14. ឯកសារផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាយល់ថាចាំបាច់ដើម្បីឧត្តមប្រយោជន៍កុមារ និងដើម្បីមានមូលដ្ឋានវាយតម្លៃពាក្យសុំឲ្យបានសមស្រប<br>• នីតិវិធីក្នុងការផ្ញើពាក្យសុំ និងសំណុំឯកសារទាំងអស់របស់ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវបញ្ជូនតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារទៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់ទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពិនិត្យ និងបញ្ជូនបន្តមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>• សំណុំឯកសារទាំងអស់របស់ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវមានជាភាសាអង់គ្លេស ឬភាសាបារាំង ហើយត្រូវបកប្រែជាភាសាខ្មែរ។ |
| **យោបល់** | ពាក់ព័ន្ធនឹងការផ្តល់សេវាលើការផ្តល់អាជ្ញាបណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងការទទួលបានការអនុញ្ញាតឲ្យផ្តល់សេវាសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស បានខិតខំរៀបចំ កសាងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ស្របតាមបទដ្ឋានជាតិ អន្តរជាតិដែលការងារទាំងអស់នេះពិតជាបានចូលរួម ចំណែកយ៉ាងសំខាន់ ដើម្បីរកគ្រួសារល្អឱ្យកុមារ និងធានាឧត្តមប្រយោជន៍របស់កុមារ ទប់ស្កាត់ការ រំលោភ និងជួញដូរតាមរូបភាពសុំកូនអន្តរប្រទេស។ |

# ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល

| | |
|---|---|
| ឈ្មោះសេវា | ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>• រដ្ឋបាលសុំកូនអន្តរប្រទេស<br>• អាសយដ្ឋានៈ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• ទូរស័ព្ទៈ ០២៣ ២១១ ៨៤៨<br>• អ៊ីម៉ែលៈ info@icca-cambodia.com.kh<br>• គេហទំព័រៈ www.icaa-cambodia.com.kh |
| គោលបំណង នៃការផ្តល់សេវា | ការផ្តល់សេវាដល់កុមារឱ្យទទួលបាននូវឋានៈ សិទ្ធ និងកាតព្វកិច្ច ដូចជាកូនបង្កើត អាចបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍រវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ស្របច្បាប់នៃប្រទេសទទួល |
| មូលដ្ឋានគតិយុត្ត | • អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារដែលកម្ពុជាជាសមាជិក ប្រកាសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩២ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>• ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តឲព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស<br>• ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះ ស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ<br>• ប្រកាសលេខ ០៣៨ ស.អ.យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបង្កើតគណកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ<br>• ប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពី ការថែទាំជំនួសចំពោះកុមារ<br>• ប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួស ចំពោះកុមារក្នុងមណ្ឌល<br>• ប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួស ចំពោះកុមារនៅតាមសហគមន៍<br>• ប្រកាសលេខ ១៤៩ ស.អ.យ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលសមាសភាព និងភារកិច្ចរបស់គណកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ<br>• ប្រកាសរួមលេខ ១០០៧ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ |

| | |
|---|---|
| | នីតិសម្បទាស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ប្រកាសរួម ៤៤៨ សហវ-ប្រក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកំណត់ ចំនួនប្រាក់ចំណាយសោហុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស<br>• ប្រកាសលេខ ១៩៤ ស.អ.យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា<br>• ប្រកាសលេខ ១៩៩ ស.អ.យ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>• ប្រកាសលេខ ០០២ ស.អ.យ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការប្រើប្រាស់អក្សរកាត់ រូបសញ្ញា និងគំរូ ក្បាលលិខិតរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>• ប្រកាសលេខ ០០៣ ស.អ.យ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌<br>• ប្រកាសលេខ ១៣៨ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ<br>• ប្រកាសលេខ ១៣៩ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស<br>• ប្រកាសលេខ ១២៣០ ស.អ.យ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស<br>• ប្រកាសលេខ ១៩៨០ ស.អ.យ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | ១. កូនសុំ<br>• កុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា មាន អាយុក្រោម៨ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម ១៨ឆ្នាំ។ ក្នុងករណីកុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម៨ឆ្នាំ អាចអនុញ្ញាត ឲ្យសុំកុមារនោះ រួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម១៨ឆ្នាំ<br>• កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង |

| | |
|---|---|
| | យុវនីតិសម្បទា<br>• កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬកុមារដែលស្ថិតក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត<br>• ក្នុងករណីសុំកូនដោយសាច់ញាតិសុំកូនអាចអនុញ្ញាត ឲ្យបានចំពោះកុមារមានអាយុក្រោម១៨ ឆ្នាំដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា។<br>**<u>២ .អ្នកសុំ</u>**<br>• អ្នកសុំ (ឪពុកម្តាយចិញ្ចឹម) ជាសហព័ទ្ធដែលមានបំណងសុំកូននៅកម្ពុជា (ទាក់ទងការដាក់ពាក្យសុំកូនតាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលនៃប្រទេសទទួល) ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា<br>• អ្នកសុំត្រូវមានលក្ខណសម្បត្តិ និងលក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របតាមច្បាប់ប្រទេសទទួល និងប្រទេសដើម<br>• អ្នកសុំមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំ<br>• អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបានលុះត្រាតែ អ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារ ដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន។ |
| **ស្តង់ដាសេវា** | កុមារដែលស្ថិតក្នុងករណីសុំកូនអន្តរប្រទេស ជាសុំកូនពេញលេញដែលត្រូវចម្រើនធំធាត់ នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ដើម្បីឲ្យ មានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិក លក្ខណៈរបស់កុមារ ហើយបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំនិងកូនសុំជាអចិន្ត្រៃយ៍ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ច ដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។ កុមារដែលអាចអនុញ្ញាតដាក់ឲ្យសុំកូនអន្តរប្រទេសបាន លុះត្រាតែអស់លទ្ធភាពផ្តល់ការឧបត្ថម្ភ ដើម្បីឲ្យកុមាររស់នៅកុមាររស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណាអំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជាអស់លទ្ធភាព និងស្របតាមគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារដែលចាត់ទុកសុំកូនអន្តរប្រទេស គឺជាដំណោះស្រាយចុងក្រោយនៃការទុកដាក់កុមារ។<br>I. **<u>ប្រាក់ចំណាយសោហ៊ុយ វិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស</u>**<br>អ្នកសុំត្រូវបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាចំនួន ៥.០០០ ដុល្លារអាមេរិក ក្នុងការសុំកូនម្នាក់ តាមរយៈ ទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃប្រទេសទទួល។ ការបង់ប្រាក់នេះ ត្រូវចែកជាពីរដំណាក់កាលៈ<br>• **ដំណាក់កាលទី១៖** អ្នកសុំត្រូវបង់ប្រាក់ចំនួន ១.៥០០ដុល្លារអាមេរិក នៅពេលសំណុំឯកសារសុំកូនត្រូវបានបញ្ជូនមកដល់រដ្ឋបាលសុំកូនអន្តរប្រទេសនៃអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ។<br>• **ដំណាក់កាលទី២៖** អ្នកសុំត្រូវបង់ប្រាក់ចំនួន ៣.៥០០ដុល្លារអាមេរិក នៅមុនពេលធ្វើពិធីប្រគល់កុមារជាផ្លូវការ។<br>ក្រៅពីការបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាខាងលើនេះអ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០៛ តាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ |

| | |
|---|---|
| | ពាក្យសុំការពិនិត្យភ័ស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀត ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការត្រូវបង្គាប់ឲ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះលើសពី ១.០០០.០០០៛ តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់ឲ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | I. **<u>សំណុំឯកសាររបស់កុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស</u>**<br>• ទម្រង់ឆ្លើយតបដំបូង<br>• ទម្រង់របាយការណ៍អំពីកុមារដែលត្រូវបោះបង់ចោល<br>• ទម្រង់ទុកដាក់កុមារតាមការថែទាំជំនួស<br>• ទម្រង់នៃការទទួលកុមារឲ្យស្នាក់នៅក្នុងមណ្ឌល<br>• សំបុត្រកំណើតរបស់កុមារ<br>• ប្រវត្តិរូបសង្ខេបរបស់កុមារ<br>• រូបថតកុមារ( ពេលរើសបាន/ បច្ចុប្បន្នភាព )<br>• ប្រវត្តិសុខភាពកុមារ និងគ្រួសារ<br>• ការសិក្សាអំពីកុមារ (បុគ្គលិកសង្គមកិច្ច/មណ្ឌល/មន្ទីរស.អ.យ/នាយកដ្ឋានសុខុមាលភាពកុមារ )<br>• លិខិតជូនដំណឹងទៅមន្ទីរ ស.អ.យ អំពីវត្តមានរបស់កុមារក្នុងមណ្ឌល<br>• លិខិតបញ្ជាក់សុខភាព( ការពិពណ៌នាពីសុខភាពផ្លូវកាយ និងផ្លូវចិត្ត ពិការភាព ជំងឺរ៉ាំរ៉ៃ តម្រូវការពិសេស ) និងប្រវត្តិនៃកុមារដែលបង្ហាញពីតម្រូវការពិសេស<br>• ឯកសារបញ្ជាក់ថាមានបងប្អូនអាយុក្រោម ០៨ឆ្នាំ<br>• រូបថតកុមារ ប្រសិនបើបងប្អូនបង្កើត<br>• ប្រកាសស្តីពីការបញ្ចូលកុមារក្នុងមណ្ឌល<br>• សេចក្តីប្រកាសស្វែងរកឪពុកម្តាយ ឬអាណាព្យាបាលកុមារ<br>• ឯកសារចម្លង ៖ ការសម្ភាសន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ សេចក្តីប្រកាស តាមរយៈវិទ្យុ ទូរទស្សន៍។ល។ ករណីរកឪពុកម្តាយ<br>• របាយការណ៍ អំពីការស្វែងរកឪពុកម្តាយ បង្កើត ឬអ្នកអាណាព្យាបាល ទម្រង់រកមិនឃើញ<br>• ទម្រង់បញ្ជាក់ពីការពិគ្រោះយោបល់ជាមួយកុមារស្តីពីសុំកូន និងមានមេឃុំចៅសង្កាត់ជាសាក្សី<br>• ទម្រង់បញ្ជាក់ពីការយល់ព្រមរបស់កុមារអំពីសុំកូនដោយមានមេឃុំ ចៅសង្កាត់ជាសាក្សី<br>• សេចក្តីសម្រេច ឬដីការបស់តុលាការពីភាពជាអាណាព្យាបាលសម្រាប់អនីតិជន( នាយកដ្ឋានសុខុមាលភាពកុមារ ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា )<br>• សេចក្តីប្រកាសស្វែងរកគ្រួសារអចិន្ត្រៃយ៍ ថ្នាក់ខេត្ត<br>• ឯកសារចម្លង ៖ ការសម្ភាសន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ សេចក្តីប្រកាស តាម រយៈវិទ្យុ ទូរទស្សន៍។ល។ ករណីរកគ្រួសារអចិន្ត្រៃយ៍ថ្នាក់ខេត្ត<br>• របាយការណ៍អំពីការខិតខំក្នុងការទុកដាក់កុមារជា អចិន្ត្រៃយ៍ក្នុងខេត្ត<br>• ទម្រង់បញ្ជាក់ពីការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាល |

អំពីស្មុំកូន ដោយមានមេឃុំ ចៅ សង្កាត់ជាសាក្សី

- សេចក្តីប្រកាសស្វែងរកគ្រួសារអេចិន្ត្រៃយ៍ ថ្នាក់ជាតិ
- ឯកសារចម្លង ការសម្ភាសន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ សេចក្តីប្រកាស តាមរយៈ វិទ្យុ ទូរទស្សន៍។ល។ ដើម្បីបញ្ជាក់ថាបានស្វែងរកនៅក្នុងប្រទេស
- របាយការណ៍អំពីការខិតខំក្នុងការទុកដាក់កុមារជា អចិន្ត្រៃយ៍ ក្នុងប្រទេស
- លិខិតស្នើសុំចុះឈ្មោះកុមារក្នុងបញ្ជីកុមារដែលមានលក្ខណសម្បត្តិសម ស្របសម្រាប់ស្មុំកូនអន្តរប្រទេស

II. <u>ឯកសារអ្នកសុំ</u>

- ពាក្យសុំកូន (ដោយបញ្ជាក់ពីបំណង និងហេតុផលដែលចង់សុំកុមារទៅ ចិញ្ចឹម)
- លិខិតអនុញ្ញាតឲ្យសុំកូនចិញ្ចឹមចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមាន សមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំ ដោយមាន បញ្ជាក់ថាកូនសុំត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុង ប្រទេសរបស់អ្នកសុំ នៅពេលដែលដំណើរការស្មុំកូនបានសម្រេចជាផ្លូវការ
- របាយការណ៍ស្តីពីស្ថានភាពគ្រួសារ ដែលធ្វើឡើងដោយភ្នាក់ងារជំនាញលើ ការងារនេះ ហើយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃ ប្រទេសរបស់អ្នកសុំដោយមានបញ្ជាក់អំពីសមត្ថភាពរបស់អ្នកសុំ ផ្នែកធន ធានថវិកា សមត្ថភាពផ្លូវចិត្ត និងប្រព័ន្ធគាំទ្រកុមារដែលអាចឆ្លើយតបទៅ នឹងតម្រូវការរបស់កុមារ
- សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតបញ្ជាក់កំណើត
- សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់សុខភាពរបស់អ្នកសុំ
- របាយការណ៍អំពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលមានការ ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច
- លិខិតបញ្ជាក់ថាអ្នកសុំបានទទួលព័ត៌មានគ្រប់គ្រាន់ និងបានទទួលការ ប្រឹក្សាយោបល់អំពីការសុំកុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារ ដែលមានតម្រូវការពិសេស មុនពេលសុំកូន
- លិខិតបញ្ជាក់ថា គ្មានទោស ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុង ប្រទេសកំណើត ឬ កន្លែងដែលអ្នកសុំរស់នៅចុងក្រោយឬ លិខិតថ្កោល ទោសចេញដោយតុលាការ ឬដោយអាជ្ញាធរមានសមត្ថកិច្ច ហើយនៅមាន សុពលភាពសម្រាប់ប្រើប្រាស់
- លិខិតបញ្ជាក់ពីកិរិយាមាយាទ នៅកន្លែងប្រកបការងារ និងនៅក្នុងសង្គម រស់នៅរបស់អ្នកសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- លិខិតបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់អ្នកសុំដែលចេញ ដោយអាជ្ញាធរមានសមត្ថកិច្ច
- កិច្ចសន្យាគោរពសិទ្ធិជាកូន ផ្តល់ការសិក្សា ព្រមទាំងសិទ្ធិផ្តល់កេរ្តិ៍មរតកដូច កូនបង្កើតរបស់ខ្លួន
- កិច្ចសន្យា ស្តីពីការផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការវិវឌ្ឍ របស់កូនសុំទៅកាន់រដ្ឋបាលស្មុំកូនអន្តរប្រទេសដោយផ្ទាល់ ឬតាមរយៈ អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬតាមរយៈទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំ រៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ០៣ឆ្នាំ បន្ទាប់មក ត្រូវផ្តល់របាយ

| | |
|---|---|
| | ការណ៍ ០១ឆ្នាំម្តង រហូតដល់កូនសុំមានអាយុ ១៨ឆ្នាំ<br>• ផែនការក្នុងការចិញ្ចឹមកុមារនៅពេលកុមារទៅដល់ប្រទេសទទួល (ដូចជារយៈពេលដែលអ្នកសុំអាចមានលទ្ធភាពឈប់សម្រាកថែទាំកុមារ)។ ផែនការក្នុងការមានអាណាព្យាបាលមើលថែទាំកុមារ ក្នុងករណីអ្នកសុំបាត់បង់សមត្ថភាព ឬស្លាប់ដោយថាហេតុ<br>• លិខិតបញ្ជាក់ពីមនោសញ្ចេតនា និងការអភិវឌ្ឍសង្គម ក្នុងកិច្ចការពារថែទាំកុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារមានតម្រូវការពិសេស<br>• ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់អ្នកសុំ<br>• រូបថតរបស់អ្នកសុំ ៦សម x ៨សម ដែលថតក្នុងអំឡុង ០៣ខែចុងក្រោយ<br>• ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋាន អចិន្ត្រៃយ៍របស់អ្នកសុំ<br>• ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ដែលមានការបញ្ជាក់ត្រឹមត្រូវ។<br>III.<u>**ឯកសារសម្រាប់កុមារអាចទទួលបានការអនុញ្ញាតរស់នៅស្របច្បាប់ក្នុងគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល**</u><br>• ដីការសម្រេចពីស្មុំកូនអន្តរប្រទេស<br>• លិខិតបញ្ជាក់ស្មុំកូនអន្តរប្រទេស ដែលចេញដោយអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា<br><u>**IV.នីតិវិធី**</u><br>• សំណុំឯកសារអ្នកសុំនឹងត្រូវផ្ញើតាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសទីភ្នាក់ងារ ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>• ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ត្រូវបញ្ជូនពាក្យសុំមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• បន្ទាប់ពីបានការសម្រេចអនុញ្ញាតពីអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសរួចហើយ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវសហការជាមួយអ្នកសុំក្នុងការរៀបចំសំណុំឯកសារស្មុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ<br>• បន្ទាប់ពីបានដីការសម្រេចរបស់តុលាការសាលាដំបូងរាជធានីភ្នំពេញ រួចមក អាជ្ញាធរ កណ្តាលស្មុំកូនអន្តរប្រទេសត្រូវរៀបចំចេញនូវលិខិតបញ្ជាក់ស្មុំកូនអន្តរប្រទេសដល់គ្រួសារ អ្នកសុំ ហើយអ្នកសុំត្រូវមកកម្ពុជាដើម្បីទទួលកូននៅរដ្ឋបាលស្មុំកូនអន្តរប្រទេស ក្នុងពិធីប្រគល់កូនជាផ្លូវការ<br>• ករណីមានបណ្តឹងជំទាស់ទៅតុលាការសាលាឧទ្ធរណ៍ បន្ទាប់ពីបានដីការសម្រេចរបស់តុលាការឧទ្ធរណ៍អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសត្រូវរៀបចំចេញនូវលិខិតបញ្ជាក់ស្មុំកូនអន្តរប្រទេសដល់គ្រួសារ អ្នកសុំ ហើយអ្នកសុំត្រូវមកកម្ពុជាដើម្បីទទួលកូននៅរដ្ឋបាលស្មុំកូនអន្តរប្រទេស ក្នុងពិធីប្រគល់កូនជាផ្លូវការ។ |
| **យោបល់** | ពាក់ព័ន្ធនឹងការផ្តល់សេវាលើការផ្តល់អាជ្ញាបណ្ណដល់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេស ក្នុងការទទួលបានការអនុញ្ញាតឲ្យផ្តល់សេវាស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស បានខិតខំរៀបចំកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ស្របតាមបទដ្ឋានជាតិ អន្តរជាតិដែលការងារ |

| | |
|---|---|
| | ទាំងអស់នេះពិតជាបានចូលរួម ចំណែកយ៉ាងសំខាន់ ដើម្បីរកគ្រួសារល្អឱ្យកុមារ និងធានាឧត្តមប្រយោជន៍របស់កុមារ ទប់ស្កាត់ការកេងប្រវ័ញ្ច និងជួញដូរតាមរូបភាពសុំកូនអន្តរប្រទេស។ |

# ការផ្តល់សេវាជួយដល់អតីតយុទ្ធជន និងគ្រួសារក្រីក្រនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាជួយដល់អតីតយុទ្ធជន និងគ្រួសារក្រីក្រនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានអតីតយុទ្ធជន<br>• ការិយាល័យសម្បទានដីសង្គមកិច្ច និងអភិវឌ្ឍមណ្ឌលអតីតយុទ្ធជន<br>- អាសយដ្ឋាន : អគារលេខ ៧៨៨មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : ០១២ ៦៥៦ ៧៥៥ |
| គោលបំណង នៃការផ្តល់សេវា | • យកចិត្តទុកដាក់ជួយអភិវឌ្ឍជីវភាពគ្រួសារអតីតយុទ្ធជន ដែលជួបការលំបាកជាងគេ បង្កឱ្យមានសមត្ថភាព និងលទ្ធភាពប្រកបរបររកស៊ីចញ្ចឹមជីវិត ដោយថ្លៃថ្នូរសមរម្យ<br>• ការផ្តល់សេវាអតីតយុទ្ធជន និងគ្រួសារក្រីក្រនៅតាមសហគមន៍ ដើម្បីជួយទ្រទ្រង់ ជីវភាពរស់នៅ បណ្តុះបណ្តាលវិជ្ជាជីវៈ និងលើកគម្រោងនានាក្នុងន័យអភិវឌ្ឍស្ថានភាព ជីវភាពរបស់ពួកគាត់កសាងសមត្ថភាព ស្តាបនា និងរៀបចំយន្តការសហការរវាងមន្ត្រី សង្គមកិច្ច អាជ្ញាធរ មូលដ្ឋាន និងអតីតយុទ្ធជនផ្ទាល់ដើម្បីអនុវត្តគម្រោងនានា |
| មូលដ្ឋានគតិយុត្ត | • ប្រកាសលេខ១៤៧ស.អ.យ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតក្រោមនាយកដ្ឋានអភិវឌ្ឍអតីតយុទ្ធជន<br>• ប្រកាសលេខ ១៨៥៨ ស.អ.យ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យអតីតយុទ្ធជន និងអភិវឌ្ឍមណ្ឌលអតីតយុទ្ធជន<br>• អនុក្រឹត្យរាជរដ្ឋាភិបាល លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស.អ.យ<br>• លិខិតលេខ ១៩៦១ ស.អ.យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ស្តីពីការស្នើសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជនចំនួន ១៦ឃុំ៖ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ឃុំភូមិធំ ស្រុកកៀនស្វាយ ឃុំស្វាយរលំ ស្រុកស្អាង ឃុំសិត្បូ ស្រុកស្អាង ឃុំកោះអន្លង់ចិន ស្រុកស្អាង ឃុំកោខ្ពស់ ស្រុកស្អាង ឃុំស្វាយប្រទាល ស្រុកស្អាង ឃុំព្រែកគយ ស្រុកស្អាង ឃុំស្អាងភ្នំ ស្រុកស្អាង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ឃុំតាលន់ ស្រុកស្អាង ឃុំត្រើយស្លា ស្រុកស្អាង ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្តាល<br>• លិខិតលេខ ១១១៩ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ ស្តីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ឃុំភ្នំបាត ស្រុកពញាឮ ឃុំពោធិបាន ស្រុកកោះធំ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល<br>• លិខិតលេខ ៩០៣ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ<br>• លិខិតលេខ ៩០៤ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំ |

ទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំសង្កែ១ ស្រុកឆែប ខេត្តព្រះវិហារ

- លិខិតលេខ ៩០៥ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ
- លិខិតលេខ ៩០៦ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ
- លិខិតលេខ ៩០៨ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំចំរើន ស្រុកសង្គមថ្មី ខេត្តព្រះវិហារ
- លិខិតលេខ ៩០៩ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំរបៀប ស្រុករវៀង ខេត្តព្រះវិហារ
- លិខិតលេខ ៩១០ ស.អ.យ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ
- លិខិតលេខ ១៨៩៥ ស.អ.យ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន សង្កាត់បរយ៉ាខា ក្រុងបៃលិន ខេត្តបៃលិន
- លិខិតលេខ ១២២៦ ស.អ.យ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន សង្កាត់បុស្សរ៍ ក្រុងសំរោង ខេត្តឧត្តមានជ័យ
- លិខិតលេខ ៧៥០ ស.អ.យ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ
- លិខិតលេខ ៣២២ ស.អ.យ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំកំពង់ចម្លង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង
- លិខិតលេខ ១៦៣២ ស.អ.យ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំសាមគ្គី ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង
- លិខិតលេខ ៦១០ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
- លិខិតលេខ ៦១១ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំខ្វាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប
- លិខិតលេខ ៦១២ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំបាល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ
- លិខិតលេខ ៦១៣ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំ

ទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

- លិខិតលេខ ៦១៤ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ
- លិខិតលេខ ៦១៥ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ
- លិខិតលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ
- លិខិតលេខ ៦១៧ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- លិខិតលេខ ៦១៨ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ
- លិខិតលេខ ៦១៩ ស.អ.យ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំចំការលើ ស្រុកស្ទោង ខេត្តកំពង់ធំ
- លិខិតលេខ ១២៩៩ ស.អ.យ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន សង្កាត់រាម ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ
- លិខិតលេខ ១១៧ ស.អ.យ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន សង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ខេត្តកែប
- លិខិតលេខ ២០០ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំអណ្តូងខ្មែរ ខេត្តកំពត
- លិខិតលេខ ២០១ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំកណ្តោល ខេត្តកំពត
- លិខិតលេខ ២០២ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំកំពង់ត្រាចខាងកើត ខេត្តកំពត
- លិខិតលេខ ២០៣ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំសំរោងក្រោម ខេត្តកំពត
- លិខិតលេខ ២០៥ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំក្រាំងស្នាយ ខេត្តកំពត
- លិខិតលេខ ២០៦ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំ

| | |
|---|---|
| | ទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំដងទង់ ខេត្តកំពត<br>• លិខិតលេខ ២០៧ ស.អ.យ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំស្រែចែង ខេត្តកំពត<br>• លិខិតលេខ ១៨២១ ស.អ.យ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ស្តីពីការសុំទទួលស្គាល់សមាសភាពគណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំឆក់ឈើនាង ខេត្តកណ្តាល<br>• លិខិតលេខ ៩០៥ ស.អ.យ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ស្តីពីការអភិវឌ្ឍអតីតយុទ្ធជន<br>• លិខិតលេខ ៩០៥ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ស្តីពីការងារអភិវឌ្ឍអតីតយុទ្ធជន<br>• ប្រកាសលេខ ១៦៥ ស.អ.យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យអភិវឌ្ឍអតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត<br>• លិខិតលេខ ១៨៥២ ស.អ.យ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៧ ករណីទទួលស្គាល់គណៈកម្មការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដែលក្រីក្រនៅតាមសហគមន៍ |
| **ស្តង់ដាសេវា** | អតីតយុទ្ធជនអាចទទួលបានផ្ទះមួយខ្នងតម្លៃប្រមាណ ៨.០០០ដុល្លារអាមេរិក |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • សំណើរបស់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• លិខិតទទួលស្គាល់គណៈកម្មការអភិវឌ្ឍន៍ ឃុំ-សង្កាត់ ដែលជារចនាសម្ព័ន្ធរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **យោបល់** | |

# ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានយុវនីតិសម្បទា<br>• ទូរស័ព្ទ ៖ ០៧៧ ៩៦៩ ២២១ |
| គោលបំណង នៃការផ្តល់សេវា | • ផ្តល់សេវាស្តារនីតិសម្បទា បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ និងសមាហរណកម្មនៅសហគមន៍ជូនអនីតិជនទំនាស់នឹងច្បាប់<br>• កុមារតាមម្តាយដែលមានអាយុចាប់ពី ០៣ឆ្នាំឡើង នៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារទទួលបានសេវាការពារ ថែទាំ អាហារូបត្ថម្ភ និងការអប់រំចំណេះដឹងទូទៅ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ ស្តីពីពន្ធនាគារឆ្នាំ២០១២<br>• ប្រកាសអន្តរក្រសួងលេខ ៨៦៣ ប្រក/សកបយ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០០១ ស្តីពីការអប់រំ កែប្រែ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈដល់ទណ្ឌិត |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | អនីតិជនដែលកំពុងជាប់ពន្ធនាគារ និងកុមារតាមម្តាយនៅក្នុងពន្ធនាគារដែលមានអាយុចាប់ពី ០៣ (បី) ឆ្នាំឡើង |
| ស្តង់ដាសេវា | ក.អនីតិជននៅក្នុងមណ្ឌលអប់រំ កែប្រែ និងពន្ធនាគារទទួលបានសេវាគ្រប់គ្រងករណី ពិគ្រោះយោបល់ ស្តារនីតិសម្បទា បណ្តុះបណ្តាលមុខជំនាញ សមាហរណកម្ម និងតាមដានបន្តនៅសហគមន៍។<br>ខ.កុមារតាមម្តាយនៅមណ្ឌលអប់រំ កែប្រែ និងពន្ធនាគារ អាយុលើសពី ៣ឆ្នាំ ទទួលបានសេវាចិញ្ចឹម ថែទាំ ជំនួសពីក្រុមគ្រួសារ សាច់ញាតិ នៅសហគមន៍ ឬមណ្ឌលកុមារកំព្រា របស់រដ្ឋ និងអង្គការ ដោយទទួលបានអាហារូបត្ថម្ភ សម្លៀកបំពាក់ និងការសិក្សាអប់រំ ដូចកុមារទូទៅ។ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ទម្រង់គ្រប់គ្រងករណី រហូតដល់ទម្រង់បិទករណី(សម្ភាសន៍ ពិគ្រោះយោបល់ តាមដាន វាយតម្លៃ និងបិទករណី) |
| យោបល់ | |

# របបឧបត្ថម្ភគោលនយោបាយចំពោះជនពិការនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | របបគោលនយោបាយឧបត្ថម្ភចំពោះជនពិការក្រីក្រនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• គណៈកម្មការសម្របសម្រួល និងជំរុញការអនុវត្តរបបគោលនយោបាយចំពោះជន ពិការក្រីក្រនៅតាមសហគមន៍ និងអនុគណៈកម្មការ<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ<br>• នាយកដ្ឋានសុខុមាលភាពជនពិការ<br>• នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់<br>• មូលនិធិជនពិការ៖ អាសយដ្ឋាន ផ្លូវជាតិលេខ ៦អា សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ<br>• ការិយាល័យបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការ<br>**គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ រាជធានី ខេត្ត (លេខាធិការដ្ឋានមន្ទីរ ស.អ.យ រាជធានី ខេត្ត)**<br>• អនុគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាម សហគមន៍ក្រុង ស្រុក ខណ្ឌ<br>• ក្រុមការងារឃុំ សង្កាត់ |
| គោលបំណងនៃការផ្តល់សេវា | • អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• រួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានាដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ<br>• ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនពិការក្រីក្រនៅតាមសហគមន៍<br>• ស្តារលទ្ធភាពពលកម្ម និងកសាងជីវភាពរស់នៅឡើងវិញដល់ជនពិការក្រីក្រនៅតាម សហគមន៍<br>• ទប់ស្កាត់ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថានរបស់ជនពិការក្រីក្រនៅ តាមសហគមន៍<br>• ផ្តល់សេវាសង្គមកិច្ចដល់ជនពិការក្រីក្រនៅតាមសហគមន៍ឱ្យមានប្រសិទ្ធភាព |
| មូលដ្ឋានគតិយុត្ត | • អនុសញ្ញា ស្តីពីសិទ្ធិជនពិការ<br>• ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>• អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ |
| អតិថិជនដែលមានសិទ្ធទទួលសេវា | • ជនពិការមានពិការភាពធ្ងន់ធ្ងរ ក្រីក្របំផុតនិងគ្មានទីពឹង<br>• ជនពិការចាស់ជរា ក្រីក្របំផុតនិងគ្មានទីពឹង<br>• ជនពិការមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រីក្របំផុតគ្មានទីពឹង |
| ស្តង់ដាសេវា | - ប្រាក់ឧបត្ថម្ភជីវភាពរស់នៅប្រចាំខែ (២០០០០៛/ខែ សម្រាប់រយៈពេល ០៣ ខែ ០៦ខែ និង ១២ខែ តាមរយៈ ការពិនិត្យ និងវាយតម្លៃពីគណៈកម្មការគ្រប់គ្រងរបប គោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍រាជធានី ខេត្ត<br>- ទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម រួមមាន៖<br>• សេវាស្តារលទ្ធភាពពលកម្ម<br>• ប្រាក់សម្រាប់អាហារក្នុងអំឡុងពេលទទួលសេវាស្តារលទ្ធភាពពលកម្ម |

| | |
|---|---|
| | ៣០០០៛/ថ្ងៃ<br>• ប្រាក់សោហ៊ុយធ្វើដំណើរមកទទួលសេវាស្តារលទ្ធភាពពលកម្មទៅមក ១០០០០៛<br>• ប្រាក់ឧបត្ថម្ភទៅពិនិត្យ ព្យាបាល ថែទាំសុខភាព នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យ បង្អែក ៣០០០០៛/ម្នាក់ (មួយលើក/ឆ្នាំ) |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • ប័ណ្ណសមធម៌កម្រិតភាពក្រីក្រដែលចេញដោយក្រសួងផែនការ<br>• មានលំនៅដ្ឋាន ឬកន្លែងស្នាក់នៅដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន<br>• ការវាយតម្លៃប្រភេទ និងកម្រិតពិការភាព តាមប្រកាសលេខ ២៤៩២ ស អយ/បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ក្រសួង សអយ និង ក្រសួងសុខាភិបាល<br>• ប្រកាសទទួលស្គាល់ជនពិការដើម្បីទទួលបានរបបគោលនយោបាយជនពិការក្រី ក្រនៅតាមសហគមន៍ចេញដោយក្រសួង ស.អ.យ<br>• ប័ណ្ណសង្គមកិច្ច ដែលចេញដោយគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយ ចំពោះជនពិការក្រីក្រនៅតាមសហគមន៍រាជធានី ខេត្ត តាមរយៈប្រកាសរបស់ ក្រសួង ស.អ.យ<br>• គណនីផ្ទាល់ខ្លួនរបស់ជនពិការនៅធនាគារអេស៊ីលីដា ដើម្បីផ្ទេរថវិការបបគោល នយោបាយពីមូលនិធិជនពិការជូនជនពិការ |
| **យោបល់** | ការផ្តល់សេវានេះអាចដំណើការទៅបាន និងមានប្រសិទ្ធភាព លុះត្រាមានការចូលរួម ពីស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងថ្នាក់ក្រសួង ស.អ.យ មូលនិធិជនពិការ គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ រាជធានី ខេត្ត មន្ទីរ សអយ រាជធានី ខេត្ត អនុគណៈកម្មការគ្រប់គ្រងរបបគោល នយោ បាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ក្រុង ស្រុក ខណ្ឌ ក្រុមការងារឃុំ សង្កាត់ តាមរយៈការរៀបចំផែនការសកម្មភាព ថវិកា សម្រាប់ចំណាយលើកិច្ចរដ្ឋបាលថ្នាក់ កណ្តាល និងថ្នាក់ក្រោមជាតិ និងថវិការបបគោលនយោបាយចំពោះជនពិការក្រីក្រនៅ តាមសហគមន៍ និងការអនុវត្តផ្ទាល់។ |

# ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា

| | |
|---|---|
| ឈ្មោះសេវា | ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពសង្គម<br>• ការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទនាយកដ្ឋាន : ០២៣ ២១២ ៦៧៣<br>- ទូរស័ព្ទការិយាល័យ : ០៨៨ ៧៣៨ ៥០០០<br>- អ៊ីម៉ែល : nguon.kosal@gmail.com<br>• មន្ទីរ ស.អ.យ រាជធានីខេត្ត និងការិយ៉ាយ ស.អ.យ ក្រុង ស្រុក ខណ្ឌ |
| គោលបំណងនៃការផ្តល់សេវា | ផ្តល់ការស្នាក់នៅជាបណ្តោះអាសន្ន ហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ អប់រំ បណ្តុះ បណ្តាលវិជ្ជាជីវៈ បំណិនជីវិត ធ្វើការបញ្ជូនបន្តទៅអង្គការដៃគូ និងសមាហរណកម្មទៅ សហគមន៍វិញ។ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទ ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយ ចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៣នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បកចុះថ្ងៃទី២៦ តុលា ឆ្នាំ២០០៦ ស្តីពីរបប គោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• សេចក្តីណែនាំលេខ ០១ សណន.គជអ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថា<br>• ផែនការសកម្មភាពស្តីពី ការដោះស្រាយបញ្ហាជនអនាថាលេខ ០១ គ.ជ.អ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩<br>• កិច្ចព្រមព្រៀងលេខ ០០៦ គ.ជ.អ/ស.អ.យ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១៥ ស្តីពី កិច្ចសហការប្រតិបត្តិការរវាងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា (អ.គ.អ) រាជធានី ខេត្ត<br>• សេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា<br>• ប្រកាសលេខ ៤៨២ ស.អ.យ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែប្រែមជ្ឈ មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពោធិ៍សែនជ័យ ទៅជាមណ្ឌលសំចតសង្គមកិច្ចរាជធានី ភ្នំពេញ<br>• សារាចរណែនាំលេខ ០០២ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពី កម្មវិធី ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុ ចំណាកស្រុក អនាថា និងវិកលចរិតនៅតាមសហគមន៍ |

| | |
|---|---|
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | ជនរងគ្រោះដែលស្ម័គ្រចិត្តមកទទួលសេវា ៖<br>• ជនចាស់ជរា និងជនពិការគ្មានទីពឹង<br>• ជនអនាថា<br>• ជនវិកលចរិត<br>• ទុគតជន<br>• ស្ត្រី កុមាររងគ្រោះដោយសារការជួញដូរផ្លូវភេទ និងពលកម្ម<br>• អ្នកប្រើប្រាស់សារធាតុញៀន<br>• ជនរងគ្រោះ និងងាយរងគ្រោះផ្សេងៗទៀត |
| **ស្តង់ដាសេវា** | ជនអនាថាទទួលបានរបបគោលនយោបាយស្នាក់នៅបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅមូលដ្ឋានមានដូចខាងក្រោម ៖<br>• របបម្ហូបអាហារស្នាក់នៅក្នុងមជ្ឈមណ្ឌល ៥.០០០៛ ក្នុងម្នាក់ក្នុងមួយថ្ងៃ<br>• របបបំប៉នសុខភាពចំពោះជនអនាថាស្នាក់នៅក្នុងមជ្ឈមណ្ឌល ២០.០០០៛/ខែ<br>• របបសម្លៀកបំពាក់ចំពោះជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹងស្នាក់នៅក្នុង មជ្ឈមណ្ឌល ១២០.០០០៛/ឆ្នាំ (ទទួលបាននៅដើមឆ្នាំ)<br>• របបបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈចំពោះជនពិការ ជនអនាថាដែលមានជំងឺអេដស៍ ៣៩០.០០០៛ ក្នុងមួយវគ្គ (រយៈពេល៣ខែ)<br>• របបរៀបចំពិធីបុណ្យសពជនអនាថា ជនពិការ និងចាស់ជរាគ្មានទីពឹង ស្នាក់នៅក្នុងមជ្ឈមណ្ឌលទទួលមរណភាព ៥៤០.០០០៛ (១ដងគត់)<br>• របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរកសាងជីវភាពគ្រួសារដោយខ្លួនឯង ៨១០.០០០៛ (១ដងគត់)<br>**ប្រភេទ២ ៖**<br>ជនរងគ្រោះ និងងាយរងគ្រោះ ចំណាកស្រុកដោយប្រថុយប្រថាន ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាសម្ភារប្រើប្រាស់ និងស្បៀងអាហារ ដោយគិតជាថវិកាមិនលើសពីចំនួន ៣០០.០០០៛ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែង រួមមាន អង្ករ អំបិល មី មុង កន្ទេល ភួយ ទឹកត្រី និងទឹកស៊ីអ៊ីវ។<br>**ប្រភេទ៣ ៖**<br>ជនអនាថា ជាជនទីទ័លក្រ គ្មានទីជម្រក តែលតោលគ្មានទីពឹងស្នាក់នៅតាមទី សាធារណៈ តំបន់ទេសចរណ៍ ឬទីប្រជុំជននានា ក្នុងរាជធានី ខេត្ត ដោយធ្វើសកម្មភាពដើរសុំទាន ជូតកញ្ចក់រថយន្ត លក់ផ្កា ឬលក់កាសែតតាមស្តុប។ល។ ត្រូវពិនិត្យ ផ្តល់ជំនួយគាំទ្រ ពិគ្រោះយោបល់ និងជំនួយសង្គ្រោះបន្ទាន់ជាស្បៀងអាហារ និងមធ្យោបាយដោយគិតជាថវិកាមិនលើសពីចំនួន ៣០០.០០០៛ក្នុងមួយគ្រួសារ (ចំពោះជនអនាថាដែលយល់ព្រមធ្វើសមាហរណកម្មទៅក្នុងសហគមន៍)<br>**ប្រភេទ៤ ៖**<br>ជនវិកលចរិតជាជនដែលមានវិបត្តិផ្នែកអារម្មណ៍ និងការគិតដែលកើតឡើងជាប្រចាំ និងដើរអនាថា (គ្មានសាច់ញាតិថែទាំ) ត្រូវស្វែងរកសេវា គាំទ្រនានារួមទាំងការស្នាក់នៅ ហូបចុក និងសេវាសុខភាពគិតជាថវិកាមិនលើសពី ចំនួន ៣០០.០០០៛ ក្នុងមួយនាក់ និងថវិកាតាមលទ្ធភាពជាក់ស្តែង។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត<br>• សេចក្តីសម្រេចរបស់ក្រសួង |

| | |
|---|---|
| **យោបល់** | ការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថាក្នុងគោលបំណងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ព្រមទាំង ធ្វើការទប់ស្កាត់នូវលំហូរចូលនៃជនអនាថាមកទីក្រុង ឬទីប្រជុំជន និងឆ្លងដែនទៅប្រទេសជិតខាង។ ដូច្នេះក្រសួង ស.អ.យ មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>• បង្កើតឱ្យមានយុទ្ធសាស្ត្ររួមសម្រាប់ដោះស្រាយបញ្ហាជនអនាថា ដោយរួមបញ្ចូលការស្តារនីតិ សម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការទប់ស្កាត់ការវិលត្រឡប់មកសុំទានវិញ<br>• ពង្រឹងពង្រីកបណ្តាញការងារសម្រាប់ជនអនាថានៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សេវាដល់ជនទាំងនោះឱ្យមានលំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង<br>• ផ្តល់ឱកាសឱ្យជនអនាថាមានជម្រកសុវត្ថិភាព ស្នាក់នៅបណ្តោះអាសន្ន ដើម្បីទទួលបានការផ្គត់ផ្គង់ជីវភាពការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងធ្វើការដឹកជញ្ជូនជនទាំងនោះឱ្យបានដល់មូលដ្ឋានគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ<br>• កសាងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ចំណាយលើការងារសេវាដល់ជនអនាថាដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗទៀត<br>• ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តគោលការណ៍ផែនការកម្មវិធី និងគម្រោងនានាព្រមទាំងគ្រប់គ្រងស្ថិតិ និងបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថាប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល |

## សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ

| | |
|---|---|
| ឈ្មោះសេវា | សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : ០២៣ ២១៣ ០៤៤<br>: ០១២ ៤០៤ ៧៤៨<br>- អ៊ីម៉ែល : vannrity_ing@yahoo.com<br>• មជ្ឈមណ្ឌលសុំចតប៉ោយប៉ែត<br>- អាសយដ្ឋាន ផ្លូវ សុខភាព ផ្ទះលេខ ១២ ភូមិ បាលិលេយ្យ២ សង្កាត់/ក្រុង ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ<br>- ទូរស័ព្ទ ៖ ០៥៤ ៩៦៧ ១៤១<br>៖ ០១២ ៧២៥ ០៥៧<br>- អ៊ីមែល ៖ chramanith@gmail.com |
| គោលបំណងនៃការផ្តល់សេវា | ជួយសង្គ្រោះដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទទួលបាននូវការស្នាក់នៅ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា ៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី របបគោលនយោបាយចំពោះជនរងគ្រោះថ្នាក់នៅក្នុងមណ្ឌលរដ្ឋ<br>• អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>• ប្រកាសលេខ ២១៧៨ ស.អ.យ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្ត ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>• ប្រកាសលេខ ១២៧៤ ស.អ.យ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើសមាហរណកម្ម ផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល<br>• នីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការផ្តល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជា បុរសដោយអំពើជួញដូរមនុស្ស ខែឧសភា ឆ្នាំ២០១២<br>• ឯកសារណែនាំ ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ២០១០<br>• សារាចរណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នូវក្នុងមជ្ឈមណ្ឌលរបស់ រដ្ឋ និងអង្គការដែលមិនមែនរដ្ឋាភិបាល<br>• ប្រកាសលេខ ៨៥២ ស.អ.យ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ លើគោល |

| | |
|---|---|
| | នយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>• សៀវភៅបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០១៤ ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ប្រកាសលេខ ២០៨១ស.អ.យ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតក្រោមនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្មជនរងគ្រោះ<br>• ប្រកាសលេខ ១២៨ ស.អ.យ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើត មជ្ឈមណ្ឌលសំចតប៉ោយប៉ែត |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ |
| **ស្តង់ដាសេវា** | ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានទទួលការថែទាំ របបស្នាក់នៅ វគ្គបណ្តុះបណ្តាល វិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ដូចខាងក្រោម ៖<br>• របបម្ហូបអាហារ ស្នាក់នៅក្នុងមជ្ឈមណ្ឌល ១៥០.០០០៛/ខែ (រយៈពេល ០៣ខែ)<br>• របបសម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១២០.០០០៛ ទទួលពេលដើមឆ្នាំ<br>• ១វគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ សម្រាប់រយៈពេលខ្លី ៣ខែ ទទួលបាន ៣៩០.០០០៛<br>• របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរ កសាងជីវភាព គ្រួសារដោយខ្លួនឯង ៨១០.០០០៛ (១ដងគត់) |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត<br>• សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ |
| **យោបល់** | ការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំង និងអំពើជួញដូរមនុស្សក្នុងគោលបំណងការពារស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍វិញដូច្នេះក្រសួង ស.អ.យ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>• បង្កើតផែនការសកម្មភាពសម្រាប់ប្រយុទ្ធប្រឆាំង និងអំពើជួញដូរមនុស្សដោយក្នុងនោះរួមបញ្ចូលទាំងការផ្តល់ជម្រក ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍ និងការបង្កាទប់ស្កាត់អំពើជួញដូរមនុស្ស<br>• កសាងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ការចំណាយលើការផ្តល់សេវាដល់ជនរងគ្រោះ ដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួង ស.អ.យ និងទំនាក់ទំនងស្វែងរក ថវិកាពីប្រភពផ្សេងៗ<br>• ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលការអនុវត្តផែនការកម្មវិធី និងគម្រោងនានា គ្រប់គ្រងទិន្នន័យ និងបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំង និងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល |

# សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ

| | |
|---|---|
| ឈ្មោះសេវា | សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• អគ្គនាយកដ្ឋានបច្ចេកទេស<br>• នាយកដ្ឋានសុខុមាលភាពជនពិការ<br>• ទូរស័ព្ទ ៖ ០២៣ ២១៨ ៤៣៧<br>• ការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈមុខរបរ និងដោះស្រាយការងារធ្វើជូនជនពិការ<br>• ទូរស័ព្ទ ៖ ០៩២ ៨៣១ ៣១៧<br>• អ៊ីមែល ៖ bun_chanrasmey@yahoo.com<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• សាលា JSCភូមិត្រពាំងវែង ឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល<br>• ទូរស័ព្ទ ៖ ០១៧ ៤៥១ ៧៤៦<br>• សាលា JCIA ភូមិធ្លក សង្កាត់គោករកា ខ័ណ្ឌព្រែកព្នៅរាជធានីភ្នំពេញ<br>• ទូរស័ព្ទ ៖ ០១៦ ៦៦៨ ៣៤៩ |
| គោលបំណង នៃការផ្តល់សេវា | កសាងសមត្ថភាពជនពិការតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្អែកលើបទដ្ឋានរួមមួយសម្រាប់មជ្ឈមណ្ឌលនិងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការទាំងអស់ ដែលជាបទដ្ឋាន ពង្រឹងគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងមុខរបរ |
| មូលដ្ឋានគតិយុត្ត | សារាចរណែនាំលេខ ០០១ ស.អ.យ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការពង្រឹងគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនពិការដែលមកទទួលសេវាបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ |
| ស្តង់ដាសេវា | **គ្រប់មជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ៖**<br>កម្រិតបទដ្ឋានអប្បបរមា ១៤ចំណុច ដើម្បីធានាគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ៖<br>1. មានអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជននិង យុវនីតិសម្បទា<br>2. អនុវត្តនូវបទដ្ឋានគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ<br>3. សិក្សាពីទីផ្សារកម្លាំងពលកម្ម ដើម្បីកំណត់មុខជំនាញសម្រាប់បណ្តុះបណ្តាល<br>4. ផ្តល់សេវាកម្មប្រឹក្សាយោបល់ជាមួយសិក្ខាកាមលើការណែនាំតម្រង់ទិស សម្រាប់ជំនួយក្នុងការជ្រើសរើសមុខជំនាញ និងការងារសមស្រប<br>5. ផ្តល់ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈសមស្របទៅនឹងតម្រូវការទីផ្សារការងារ និងមុខរបរ<br>6. គ្រូបណ្តុះបណ្តាលត្រូវមានសមត្ថភាព និងគរុកោសល្យគ្រប់គ្រាន់ក្នុងការអនុវត្តកម្មវិធីសិក្សា<br>7. ត្រូវធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សាឱ្យស្របនឹងតម្រូវការទីផ្សារ<br>8. ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងស្មារតីចំពោះសិក្ខាកាមទាំង |

ពេលសិក្សា និងប្រកបការងារ

9. ផ្តល់ការបំប៉នជំនាញបន្ថែមដើម្បីអភិវឌ្ឍសមត្ថភាព និងឱកាសថ្មីៗសម្រាប់សិស្សដែលកំពុងប្រកបការងារ
10. ត្រូវមានបទបញ្ជាផ្ទៃក្នុងដែលធានាដល់ការអនុវត្តកម្មវិធីសិក្សាដើម្បីទទួលបានជោគជ័យ
11. ត្រូវមានកម្មវិធីបណ្តុះបណ្តាលបន្ថែមនូវជំនាញគួបផ្សំ និងបង្កឱកាសឱ្យសិក្ខាកាមបានចូលរួមក្នុងសកម្មភាពនានារបស់សង្គម
12. ផ្តល់ និងសម្របសម្រួលដើម្បីទទួលបានកម្ចីគ្មានការប្រាក់ ឬមានការប្រាក់ទាបផ្តល់ជាជំនួយ និងឧបករណ៍ផ្សេងៗដើម្បីជួយដល់ជនពិការមានលទ្ធភាពបង្កើតមុខរបរផ្ទាល់ខ្លួន និងជួយសម្របសម្រួលក្នុងការស្វែងរកការងារ
13. ត្រូវមានកម្មវិធីការងារតាមដានសិស្សបញ្ចប់វគ្គ ដើម្បីគាំទ្រឱ្យមាននិរន្តរភាពមុខរបរ
14. ហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលត្រូវសម្រួលដល់លទ្ធភាពចល័តចេញចូលរបស់ជនពិការគ្រប់ប្រភេទ

<u>**លក្ខណវិនិច្ឆ័យ ៧ ចំណុច៖**</u>

1. រយៈពេលសមស្របសម្រាប់ការបណ្តុះបណ្តាល
2. គ្រូបណ្តុះបណ្តាលត្រូវមានលក្ខណសម្បត្តិ
    a. មានការទទួលស្គាល់សមត្ថភាពវិទ្យាស្ថាន ឬស្ថាប័នបណ្តុះបណ្តាលបច្ចេកទេសជាផ្លូវការ
    b. មានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្រៀន
    c. មានគរុកោសល្យ ឬភាពប៉ិនប្រសប់ក្នុងការផ្ទេរចំណេះដឹង និងជំនាញ
3. កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងមុខវិជ្ជាចំរុះបន្ថែម (អក្ខរកម្ម លេខនព្វន្តជំនួញ ចំណេះដឹងផ្នែកទីផ្សារ និងគោលការណ៍គ្រប់គ្រង....)
4. ត្រូវធ្វើបច្ចុប្បន្នភាពលើកម្មវិធីបណ្តុះបណ្តាលទៅតាមតម្រូវការទីផ្សារ
5. សម្ភារបណ្តុះបណ្តាលត្រូវផ្គត់ផ្គង់ទៅតាមតម្រូវការនៃវគ្គជំនាញនីមួយៗ
6. ការងារបណ្តុះបណ្តាលត្រូវមានទ្រឹស្តីផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង (៣០:៧០)
7. ត្រូវផ្តល់សេវាគាំពារសុខភាពនិងសម្របសម្រួលដល់ការប្រើប្រាស់ ឧបករណ៍ជំនួយ(ក្នុងកំឡុងពេល សិក្សា)

<u>**លក្ខណៈនៃបទដ្ឋានវិញ្ញាបនបត្រ ២២ ចំណុច ៖**</u>

1. ចំពោះប្រភេទទីមួយ គឺប្រើសម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលចាប់ពី០៦ខែឡើងទៅហើយចុះហត្ថលេខាបញ្ជាក់នៅលើវិញ្ញាបនបត្រដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
2. ប្រភេទទីពីរ គឺប្រើសម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលតិចជាង ០៦ខែហើយចុះហត្ថលេខាបញ្ជានៅលើវិញ្ញាបនបត្រដោយប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត

| | |
|---|---|
| | 3. ទម្រង់បទដ្ឋានវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានព្រះរាជសង្ហានៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស មានទីតាំងខ្ពស់ជាងគេនៅចន្លោះក្បាលរចនា<br>4. គំរូវិញ្ញាបនបត្រទាំងពីរត្រូវមានពណ៌ទឹកមាសជុំវិញក្រដាសជាក្បាច់រចនាប័ទ្មខ្មែរ<br>5. ទីតាំងនៃស្លាកសញ្ញារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការសាមីត្រូវមានទីតាំងកម្ពស់ស្មើគ្នា<br>6. វិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រូវចុះហត្ថលេខាដោយនាយកប្រធានអង្គការសាមី<br>7. ចំពោះវិញ្ញាបនបត្រដែលមានរយៈពេលបណ្តុះបណ្តាលវិជ្ជាជីវៈតិចជាង០៦ខែត្រូវបោះពុម្ពលើផ្ទៃក្រដាសពណ៌ស<br>8. ចំពោះវិញ្ញាបនបត្រដែលមានរយៈពេលបណ្តុះបណ្តាលវិជ្ជាជីវៈដែលចាប់ពី ០៦ខែ ឡើងទៅត្រូវបោះពុម្ពលើផ្ទៃក្រដាសពណ៌ពងមាន់<br>9. គ្រប់វិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានកម្មវិធីបណ្តុះបណ្តាលនៅផ្នែកខាងខ្នងនៃវិញ្ញាបនបត្រ ដោយមានការចុះហត្ថលេខាបញ្ជាក់ពីនាយកសាលាបានឃើញ និងឯកភាពដោយប្រធានមណ្ឌល<br>10. តួអក្សរខ្មែរស្តីពី ព្រះរាជាណាចក្រកម្ពុជាត្រូវប្រើពណ៌ខ្មៅ Limon R4 ទំហំ៣២ ជាតិ សាសនា ព្រះមហាក្សត្រ ត្រូវប្រើពណ៌ខ្មៅ Limon R4 ទំហំ៣១<br>11. តួអក្សរខ្មែរស្តីពីវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវប្រើពណ៌ខ្មៅ Limon R5ទំហំ ៣៤<br>12. តួអក្សរអង់គ្លេសស្តីពីវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវប្រើពណ៌ខ្មៅ Arial ទំហំ ១០<br>13. តួអក្សរអង់គ្លេសស្តីពីអង្គការស្ថាប័នបណ្តុះបណ្តាលត្រូវដាក់ពីក្រោមស្លាកសញ្ញាហើយមានទំហំសមរម្យ<br>14. តួអក្សរខ្មែរស្តីពីលេខត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២២<br>15. តួអក្សរអង់គ្លេសស្តីពីលេខត្រូវប្រើអក្សរពណ៌ខ្មៅ Arial ទំហំ ១០<br>16. ចំពោះវិញ្ញាបនបត្រដែលត្រូវបញ្ជាក់ទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាប្រើ Limon R4 ទំហំ ២៤<br>17. ចំពោះវិញ្ញាបនបត្រដែលត្រូវបញ្ជាក់ទទួលស្គាល់ត្រឹមថ្នាក់ខេត្ត តួអក្សរខ្មែរស្តីពី ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទារាជធានីខេត្តត្រូវប្រើ Limon R4 ទំហំ ២៤<br>18. ចំពោះរូបថតរបស់សិក្ខាកាមត្រូវមានទំហំ ៤ x ៦ដាក់ចំកណ្តាលផ្នែកខាងក្រោម<br>19. តួអក្សរខ្មែរស្តីពីទម្រង់ខ្លឹមសារនៃវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២៤ ចំណែកឯតួអក្សរខ្មែរស្តីពីការបញ្ជាក់ភិនភាគ និងលទ្ធផលសិក្សារបស់ សិក្ខាកាមត្រូវប្រើអក្សរពណ៌ខ្មៅ Limon R4 ទំហំ ២៤ |

| | |
|---|---|
| | 20. តួអក្សរអង់គ្លេសស្ដីពីទម្រង់ខ្លឹមសារនៃវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅArial ទំហំ១០ចំណែកឯតួអក្សរខ្មែរស្ដីពីការបញ្ជាក់ភិនភាគ និងលទ្ធផលសិក្សារបស់សិក្ខាកាមត្រូវប្រើអក្សរពណ៌ខ្មៅដឹត Times New Roman ទំហំ ១២<br>21. ចំពោះវិញ្ញាបនបត្រទាំងពីរប្រភេទតួអក្សរស្ដីពី ថ្ងៃខែឆ្នាំ បានឃើញ និងឯកភាព ដែលត្រូវបញ្ជាក់លើវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២៤<br>22. ចំពោះវិញ្ញាបនបត្រទាំងពីរប្រភេទតួអក្សរស្ដីពី ឋានៈ តួនាទីនៃអ្នកដែលត្រូវបញ្ជាក់លើវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon R4 ទំហំ ២៤ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • សំណើរបស់សាមីខ្លួនជនពិការ<br>• សំណើរបស់ស្ថាប័ន និងអង្គការនានា<br>• ការសម្រេចរបស់ប្រធានមជ្ឈមណ្ឌល និងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការ |
| **យោបល់** | កម្រិតបទដ្ឋានរួមបានផ្តល់ឱ្យមជ្ឈមណ្ឌល និងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការបំពេញបាននូវ ៖<br>• តម្រូវការជាមួយមូលដ្ឋានរបស់ជនពិការ និងគ្រួសារមានភាពប្រសើរឡើងតាមរយៈកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈសំដៅបង្កើនប្រាក់ចំណូលដោះស្រាយមុខរបរ និងរកការងារឱ្យជនពិការធ្វើ<br>• បង្កើនប្រភពចំណូលរបស់ជនពិការតាមរយៈកិច្ចប្រកបមុខរបរ និងបម្រើការងារ<br>• បង្កើនសមត្ថភាពជំនាញ និងចំណេះដឹងរបស់ជនពិការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារនិងក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ជនពិការ<br>• ការកែលម្អគុណភាពវគ្គបណ្ដុះបណ្ដាលឱ្យឆ្លើយតបទៅនឹងទីផ្សារការងារ<br>• បង្កើត និងជំរុញយន្តការអនុវត្តបទដ្ឋានឱ្យមានផែនការច្បាស់លាស់ |

# សេវាកម្មបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈកម្រិតឧត្តមសិក្សា

| | |
|---|---|
| **ឈ្មោះសេវា** | ការបណ្ដុះបណ្ដាលមុខជំនាញវិជ្ជាជីវៈកម្រិតឧត្តមសិក្សា |
| **ក្រសួង/ស្ថាប័ន ផ្តល់សេវា** | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>• វិទ្យាស្ថានជាតិសង្គមកិច្ច<br>• អាសយដ្ឋាន៖ អគារ ២០B វិថីឌួងងៀប II សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៨៣ ៩៤៦ / ០១២ ៥៦៥ ០២២ / ០៨៩ ៦៧៨ ៨០៥<br>• ទូរសារលេខ(Fax) : ០២៣ ៨៨៣ ៩៤៣<br>• ទូរសារអេឡិចត្រូនិច (E-Mail) : nisa@nisa-edu.gov.kh<br>• វេបសាយ(website): www.nisa-edu.gov.kh |
| **គោលបំណង នៃការផ្តល់សេវា** | • ដើម្បីបង្កើនធនធានមនុស្សលើវិស័យសង្គមកិច្ច ទាំងស្ថាប័នរដ្ឋ និងឯកជន ដោយផ្សាភ្ជាប់ ទៅនឹងតម្រូវការប្រទេសជាតិ និងសង្គម<br>• ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ និងមុខរបរ ។ |
| **មូលដ្ឋានគតិយុត្ត** | • អនុក្រឹត្យលេខ ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីការបង្កើតវិទ្យាស្ថាន ជាតិសង្គមកិច្ច<br>• ប្រកាសលេខ ៧២៥ ស.អ.យ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិសង្គមកិច្ច<br>• ប្រកាសលេខ ៤២៧ ស.អ.យ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការបង្កើតដេប៉ាតឺម៉ង់ គោលនយោបាយនិងអភិបាលកិច្ច និងដេប៉ាតឺម៉ង់ភាសាអង់គ្លេស<br>• សេចក្តីសម្រេចលេខ ២៨ អយក.សសរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបង្កើត ដេប៉ាតឺម៉ង់ និងមុខជំនាញនៅវិទ្យាស្ថានជាតិសង្គមកិច្ច ។ |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | សិស្ស-និស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ផ្តល់អាទិភាពចំពោះសិស្ស-និស្សិត ក្រីក្រ និងពិការ) |
| **ស្តង់ដាសេវា** | អនុវត្តតាមស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | ពាក្យសុំចូលរៀនដោយភ្ជាប់មកជាមួយនូវ៖<br>• ប្រវត្តិរូបសង្ខេប (បិតរូបថត ៤X៦)<br>• រូបថត(៤X៦) ចំនួន ០២សន្លឹក<br>• សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្របណ្តោះអាសន្ន ឬសញ្ញាបត្រមានតម្លៃស្មើ<br>• លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ចំពោះតែនិស្សិតក្រីក្រ និងពិការ) ។ |
| **យោបល់** | |

# ការផ្តល់សេវាជូនជនពិការនៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយ សម្បទា និងនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាជូនជនពិការនៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយ សម្បទា និងនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• មូលនិធិជនពិការ<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ |
| គោលបំណង នៃការផ្តល់សេវា | • ដើម្បីផ្តល់សេវាស្តារលទ្ធភាពពលកម្ម (ការផ្តល់អវយវៈសិប្បនិម្មិត និង រណបឧបករណ៍ ជំនួយរាងកាយ រទេះរុញ ការជួសជុល និងការព្យាបាលដោយចលនាជូនជនពិការ)<br>• ដើម្បីឱ្យជនពិការមានលទ្ធភាពទទួលបានព្រមទាំងការចូលរួម និងដាក់បញ្ចូលដោយ ពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍<br>• ប្រកាសលេខ ១៦១៥ ស.អ.យ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការអនុវត្ត របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ដែលមកទទួលសេវា នៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរបស់រដ្ឋ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនពិការ |
| ស្តង់ដាសេវា | • ជនពិការទទួលសេវាដោយមិនគិតថ្លៃ<br>• ជនពិការ ដែលមកទទួលសេវានៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយ សម្បទារបស់រដ្ឋត្រូវទទួលបានថ្លៃអាហារ ៣.០០០៛/ថ្ងៃ និងថ្លៃធ្វើដំណើរទៅមក ១០.០០០៛ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាស្នើសុំថវិកាសម្រាប់ថ្លៃអាហារ និងថ្លៃ ធ្វើដំណើររបស់ជនពិការ<br>• មូលនិធិជនពិការស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| យោបល់ | |

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

វិមានរាជរដ្ឋាភិបាល ផ្លូវស៊ីសុវត្ថិ វត្តភ្នំ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ៩៨១ ១៥៤
អ៊ីមែល : cdc.cib@online.com.kh
គេហទំព័រ : www.cambodianinvestment.gov.kh

# ការចុះបញ្ជីគម្រោងវិនិយោគ

| | |
|---|---|
| ឈ្មោះសេវា | ការចុះបញ្ជីគម្រោងវិនិយោគ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មាធិការវិនិយោគកម្ពុជា**<br>ការិយាល័យច្រកចេញចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិមានរាជរដ្ឋាភិបាល ផ្លូវស៊ីសុវត្ថិ វត្តភ្នំ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : (៨៥៥ ២៣) ៩៨១ ១៥៤<br>- អ៊ីមែល : cdc.cib@online.com.kh<br>- គេហទំព័រ : www.cambodianinvestment.gov.kh |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ភាពងាយស្រួលដល់វិនិយោគិនក្នុងការស្នើសុំអាជ្ញាប័ណ្ណវិនិយោគ និងផ្តល់ការលើកទឹកចិត្តផ្សេងៗទៀត |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣<br>• អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | អ្នកវិនិយោគសញ្ជាតិខ្មែរ និងសញ្ជាតិបរទេស |
| ស្តង់ដាសេវា | • រយៈពេល ០៣ ថ្ងៃនៃថ្ងៃធ្វើការ ចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ<br>• រយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ ចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ<br>• តម្លៃ ១៥ លានរៀល ( ប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ១. ពាក្យស្នើសុំ (ចុះហត្ថលេខាដោយអ្នកមានសិទ្ធិ) (ច្បាប់ដើម)<br>២. លក្ខន្តិកៈក្រុមហ៊ុន (ច្បាប់ដើម)<br>៣. គម្រោងសិក្សាសមិទ្ធិលទ្ធភាព (ច្បាប់ដើម)<br>៤. ម្ចាស់ភាគហ៊ុនជានីតិបុគ្គល ៖<br>- លិខិតប្រគល់សិទ្ធិ ឬ លិខិតតែងតាំង របស់ក្រុមហ៊ុនមេចំពោះតំណាងស្របច្បាប់ របស់ខ្លួន (ច្បាប់ដើម)<br>- លក្ខន្តិកៈក្រុមហ៊ុនមេ (ច្បាប់ថតចម្លង)<br>៥. អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ច្បាប់ថតចម្លង)<br>៦. លិខិតថ្កោលទោស សមាជិកភាគហ៊ុនសញ្ជាតិបរទេស (ច្បាប់ដើម)<br>៧. រូបថតសមាជិកភាគហ៊ុន (៤x៦)<br>៨. ឯកសារបញ្ជាក់ទីតាំង (កម្មសិទ្ធិ កិច្ចសន្យាជួល ដែលមានបញ្ជាក់ពីអាជ្ញាធរដែនដី ឬ សម្បទាន ប្លង់បង្ហាញទីតាំង-ប្លង់មេ)<br>៩. លិខិតបញ្ជាក់២៥% នៃដើមទុនចុះបញ្ជីនៅធនាគារពាណិជ្ជណាមួយ (ច្បាប់ដើម) |
| យោបល់ | ពង្រឹងយន្តការ " ច្រកចេញ-ចូលតែមួយ " នៅ " ក.អ.ក " ឱ្យមានប្រសិទ្ធភាព ដោយអ្នកវិនិយោគ នឹងទទួលបាននូវរាល់សេវាពី "ក.អ.ក" លើការងារចុះបញ្ជីអាជ្ញាប័ណ្ណ លិខិតអនុញ្ញាតនានា ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមស្មារតីនៃច្បាប់ និង អនុក្រឹត្យសំដៅបង្កភាពកាន់តែងាយស្រួលជូនអ្នកវិនិយោគ និងបង្កើនភាពទាក់ទាញ លំហូរវិនិយោគកាន់តែខ្លាំង។ |

# ការងារផ្តល់សេវាផ្នែកនីតិកម្ម

| | |
|---|---|
| **ឈ្មោះសេវា** | ការងារផ្តល់សេវាផ្នែកនីតិកម្ម |
| **ក្រសួង/ស្ថាប័ន ផ្តល់សេវា** | **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មាធិការវិនិយោគកម្ពុជា**<br>ការិយាល័យច្រកចេញចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិមានរាជរដ្ឋាភិបាល ផ្លូវស៊ីសុវត្ថិ វត្តភ្នំ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : (៨៥៥ ២៣) ៩៨១ ១៥៤<br>- អ៊ីមែល : cdc.cib@online.com.kh<br>- គេហទំព័រ : www.cambodianinvestment.gov.kh |
| **គោលបំណង នៃការផ្តល់សេវា** | សម្រួលការងារ ដល់អ្នកវិនិយោគ ក្នុងការផ្ទេរភាគហ៊ុន ការប្តូរអ្នកតំណាងម្ចាស់ភាគហ៊ុន ការប្តូរទីតាំង ការប្តូរទីស្នាក់ការ ការប្តូរនាមករណ៍ ការប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ការបង្កើន និងការបន្ថយដើមទុនចុះបញ្ជី ការលុបគម្រោងវិនិយោគ ការទិញយក និងការរួមបញ្ចូលគ្នា របស់ក្រុមហ៊ុនវិនិយោគ (Merger and Acquisition) និងការធ្វើនិយ័តកម្ម មកជាគម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" |
| **មូលដ្ឋានគតិយុត្ត** | • ច្បាប់ស្តីពី វិសោធនកម្ម នៃច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣<br>• អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា<br>• ប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | ក្រុមហ៊ុន ដែលបានទទួលចុះបញ្ជីជាគម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" |
| **ស្តង់ដាសេវា** | • រយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ<br>• តម្លៃ ២ លានរៀល |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | ១. គោលការណ៍អនុញ្ញាតឱ្យវិនិយោគពី កអក/គវក (សម្រាប់ក្រុមហ៊ុនចាស់) ឬវិញ្ញាប័នបត្រចុះបញ្ជីជាស្ថាពរ (សម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីក្រោយច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ស្តីពី វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា (ច្បាប់ថតចម្លង)<br>២. ពាក្យស្នើសុំ របស់ក្រុមហ៊ុន (ច្បាប់ដើម)<br>៣. លក្ខន្តិកៈកំពុងប្រើ របស់ក្រុមហ៊ុន (ច្បាប់ថតចម្លង)<br>៤. សេចក្តីសម្រេច ឬ កំណត់ហេតុអង្គប្រជុំ របស់ម្ចាស់ភាគហ៊ុន (ច្បាប់ដើម)<br>៥. លិខិតបញ្ជាក់ការទទួលខុសត្រូវនូវបំណុលពន្ធរដ្ឋ និងបំណុលពន្ធផ្សេងៗ (ច្បាប់ដើម)<br>៦. លិខិតធានាលើការផ្ទេរភាគហ៊ុន របស់ប្រធានក្រុមហ៊ុន (ច្បាប់ដើម)<br>៧. តារាងផ្ទេរភាគហ៊ុន និងតារាងម្ចាស់ភាគហ៊ុនថ្មី (ច្បាប់ដើម)<br>៨. លក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន (ច្បាប់ដើម)<br>៩. អត្តសញ្ញាណបណ្ណ (សម្រាប់ជនជាតិខ្មែរ) ឬ លិខិតឆ្លងដែន (សម្រាប់ជនបរទេស) របស់សមាជិកភាគហ៊ុន (ច្បាប់ថតចម្លង)<br>១០. ប័ណ្ណកម្មសិទ្ធិ ឬ កិច្ចសន្យាជួលដី ឬ កិច្ចសន្យាជួលទីតាំងរោងចក្រ (ច្បាប់ដើម) |

| | |
|---|---|
| | ១១. លិខិតថ្កោលទោសម្ចាស់ភាគហ៊ុនថ្មី (ក្នុងករណីជាជនបរទេស) (ច្បាប់ដើម)<br>១២. ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គល ត្រូវភ្ជាប់មកជាមួយនូវ ៖<br>ក- វិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជី របស់នីតិបុគ្គលនោះ<br>ខ- លិខិតចាត់តាំងជាតំណាងនីតិបុគ្គល និងលិខិតប្រគល់សិទ្ធិចុះហត្ថលេខារបស់ម្ចាស់ភាគហ៊ុនជានីតិបុគ្គល (ក្នុងករណីផ្ទេរភាគហ៊ុន)<br>គ- លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ (ច្បាប់ថតចម្លង) និងរូបថត (៤x៦)<br>១៣. ឯកសារបញ្ជាក់ទីតាំង: កម្មសិទ្ធិ កិច្ចសន្យាជួល (ដែលមានបញ្ជាក់ពីអាជ្ញាធរដែនដី) ប្លង់អាគារ ប្លង់ទីតាំង |
| **យោបល់** | សេវាដែលផ្តល់ជូនខាងលើនេះ គឺផ្តល់ជូនចំពោះពាក្យសុំរបស់ក្រុមហ៊ុនវិនិយោគ ដែលបានចុះបញ្ជីជាក្រុមហ៊ុនវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតែប៉ុណ្ណោះ។ |

**ពិនិត្យសំណើនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ នូវឧបករណ៍ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មសម្រាប់បម្រើឱ្យគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់**

| | |
|---|---|
| ឈ្មោះសេវា | ពិនិត្យសំណើនាំចូល ដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ នូវឧបករណ៍ សម្ភារៈបរិក្ខារ ផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម សម្រាប់បម្រើឱ្យគម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា**<br>ការិយាល័យច្រកចេញចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិមានរាជរដ្ឋាភិបាល ផ្លូវស៊ីសុវត្ថិ វត្តភ្នំ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : (៨៥៥ ២៣) ៩៨១ ១៥៤<br>- អ៊ីមែល : cdc.cib@online.com.kh<br>- គេហទំព័រ : www.cambodianinvestment.gov.kh |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការលើកទឹកចិត្ត និងជំរុញដល់ការវិនិយោគ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣<br>• អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា<br>• ប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ក្រុមហ៊ុនដែល បានទទួលចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" |
| ស្តង់ដាសេវា | • រយៈពេល ០៧ថ្ងៃ នៃថ្ងៃធ្វើការ<br>• តម្លៃ ៤ លានរៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | **ក- សំណើសុំនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋ (លើកទី១)**<br>១. ពាក្យស្នើសុំ (ចុះហត្ថលេខាដោយអ្នកមានសិទ្ធិ) (ច្បាប់ដើម)<br>២. បញ្ជីមេ CIB 01E (ច្បាប់ដើម)<br>- ការបំពេញលក្ខខណ្ឌ ដែលមានក្នុងគោលការណ៍<br>- អាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្ម (ច្បាប់ថតចម្លង)<br>៣. ចុះបញ្ជីពន្ធដារ(ប័ណ្ណប៉ាតង់-អាករលើតម្លៃបន្ថែម) (ច្បាប់ថតចម្លង)<br>៤. ប្លង់សាងសង់ (ករណីស្នើសុំគ្រឿងសំណង់) (ច្បាប់ថតចម្លង)<br>**ខ- សំណើសុំនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋ (ជាបន្តបន្ទាប់)**<br>១. ពាក្យស្នើសុំ (ចុះហត្ថលេខាដោយអ្នកមានសិទ្ធិ) (ច្បាប់ដើម)<br>២. បញ្ជីមេ CIB 01E (ច្បាប់ដើម)<br>៣. របាយការណ៍ ស្តីពីការនាំចូល-នាំចេញ និងសន្និធិ (ច្បាប់ដើម)<br>៤. វិញ្ញាបនបត្របញ្ជាក់ ស្តីពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ (ច្បាប់ថតចម្លង)<br>៥. ការវាយតម្លៃសមត្ថភាពផលិត បទដ្ឋានផលិត និងបំរែបំរួលខ្សែសង្វាក់ផលិតកម្ម (ច្បាប់ថតចម្លង) |

| | |
|---|---|
| **យោបល់** | - ការអនុញ្ញាតឱ្យនាំចូល ដោយរដ្ឋជាអ្នកទទួលបន្ទុកលើពន្ធនាំចូលនេះមានទិសដៅសំខាន់ សម្រាប់បម្រើតម្រូវការផលិតកម្មរបស់ក្រុមហ៊ុន ស្របតាមមុខសញ្ញាកំណត់។ ក្រោយពេលនាំចូល ក.អ.ក នឹងចាត់តាំងក្រុមត្រួតពិនិត្យចុះតាមដានការប្រើប្រាស់នូវរាល់ទំនិញដែលបាននាំចូលខាងលើនេះ ហើយរយៈពេល ០៦ ខែក្រោយ ការនាំចូល នឹងមានការចុះត្រួតពិនិត្យក្រោមរូបភាពជា Post Audit ពីអន្តរក្រសួងមានសមត្ថកិច្ច។ ក្នុងករណីពិនិត្យឃើញថាក្រុមហ៊ុនបានប្រើប្រាស់ ការលើកទឹកចិត្តមិនចំមុខសញ្ញាវិនិយោគទេនោះ ក្រុមហ៊ុននឹងត្រូវទទួលរងការបង់ពន្ធ ការផាកពិន័យ និងទោសទណ្ឌតាមច្បាប់ជាធរមាន។<br>- ចំពោះក្រុមហ៊ុន ដែលមានជំពាក់បំណុលពន្ធរដ្ឋ នឹងមិនត្រូវទទួលបាននូវការពិនិត្យសំណើនាំចូលបន្តទៀតទេ។<br>- ចំពោះការមិនអនុវត្តកាតព្វកិច្ចផ្សេងៗទៀត ដូចជាករណីមិនចូលរួមកិច្ចការពារបរិស្ថានតាមការណែនាំ របស់ស្ថាប័នមានសមត្ថកិច្ច ក៏ត្រូវអនុវត្តតាមលំនាំដូចខាងលើ។ |

# អាជ្ញាប័ណ្ណបង្កើតតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឈ្មោះសេវា | អាជ្ញាប័ណ្ណបង្កើតតំបន់សេដ្ឋកិច្ចពិសេស |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា**<br>ការិយាល័យច្រកចេញចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិមានរាជរដ្ឋាភិបាល ផ្លូវស៊ីសុវត្ថិ វត្តភ្នំ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : (៨៥៥ ២៣) ៩៨១ ១៥៤<br>- អ៊ីមែល : cdc.cib@online.com.kh<br>- គេហទំព័រ : www.cambodianinvestment.gov.kh |
| គោលបំណង នៃការផ្តល់សេវា | សម្របសម្រួលរាល់សកម្មភាពវិនិយោគ ជំរុញលើកទឹកចិត្ត ដល់អ្នកវិនិយោគ បង្កើននូវបរិយាកាសវិនិយោគ ដែលអំណោយផលដល់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវផលិតភាព ក្នុងការផលិតទំនិញ ការប្រជែងឈ្នះកំណើនសេដ្ឋកិច្ចជាតិ ជម្រុញការនាំចេញ ដោះស្រាយការងារជូនប្រជាជន ដើម្បីកាត់បន្ថយភាពក្រីក្រ |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។<br>• ប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវា សាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | អ្នកវិនិយោគសញ្ជាតិខ្មែរ និងសញ្ជាតិបរទេស |
| ស្តង់ដាសេវា | • រយៈពេល ២៨ ថ្ងៃ នៃថ្ងៃធ្វើការ<br>• តម្លៃ ១៥ លានរៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ១. លក្ខន្តិកៈក្រុមហ៊ុន (០៣ច្បាប់ )<br>២. គម្រោងសិក្សាសមិទ្ធិផល<br>៣. ពាក្យស្នើសុំវិនិយោគ<br>៤. លិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណថតចំលង<br>៥. លិខិតថ្កោលទោស សមាជិក ភាគហ៊ុនបរទេស<br>៦. រូបថតសមាជិកភាគហ៊ុន<br>៧. ឯកសារបញ្ជាក់ទីតាំង(កម្មសិទ្ធិ-កិច្ចសន្យាជួលកិច្ចសន្យាជី សម្បទានប្លង់ និងផែនទីបង្ហាញទីតាំង)<br>៨. ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គល ត្រូវភ្ជាប់មកជាមួយនូវៈ<br>ក- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់នីតិបុគ្គលនោះ<br>ខ- លិខិតតែងតាំងតំណាងនីតិបុគ្គល<br>គ- ថតចំលងអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនតំណាងនីតិបុគ្គល<br>ឃ- រូបថតទំហំ ៤ គុណ ៦ របស់តំណាងនីតិបុគ្គល<br>៩. ប្លង់អាគារ និងប្លង់ទីតាំង |
| យោបល់ | អាជ្ញាប័ណ្ណចុះបញ្ជីវិនិយោគ គឺមានសារសំខាន់ និងមានប្រយោជន៍ដល់អ្នកវិនិយោគ ដើម្បីទទួលបាននូវការលើកទឹកចិត្ត ពីរាជរដ្ឋាភិបាលក្នុងការនាំចូលនូវសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្ម ដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ។ |

## រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល

បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន
សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩
ទូរសារ: ០២៣ ៨៦៦ ០១៩

**អាជ្ញាប័ណ្ណ ៖ ចេញលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរ តាមរដូវកាល របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស**( Landing Permit to Operate Summer/Winter Schedule Flight )

| | |
|---|---|
| **ឈ្មោះសេវា** | ចេញលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរតាមរដូវកាល និងប្រតិបត្តិការហោះហើរ របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស ( Summer/Winter Schedule Flight ) |
| **ក្រសួង/ស្ថាប័ន ផ្តល់សេវា** | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្សី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស<br>ការិយាល័យអនុញ្ញាតហោះហើរ |
| **គោលបំណង នៃការផ្តល់សេវា** | ផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរតាមរដូវកាលដល់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| **មូលដ្ឋានគតិយុត្ត** | • សេចក្តីប្រកាសលេខ ១៣៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• Form 002/ATD |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| **ស្តង់ដាសេវា** | • មានរយៈពេល ០២ខែ ដើម្បីផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរតាមរដូវកាល Summer/Winter Schedule<br>• មានសុពលភាពរយៈពេល ០៦ខែ<br>• បង់ថ្លៃ ២០០ដុល្លា |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | • ពាក្យសុំ ( ០១ច្បាប់ )<br>• ថតចម្លងលិខិតចាត់តាំងករុមហ៊ុនអាកាសចរណ៍ចេញដោយអាជ្ញាធរអាកាសចរស៊ីវិល<br>• ថតចម្លងវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស( AOC )<br>• ថតចម្លងវិញ្ញាបនបត្រសុវត្ថិភាពហោះហើរគ្រប់ប្រភេទយន្តហោះ ( Airworthiness )<br>• ថតចម្លងវិញ្ញាបនបត្រចុះបញ្ជីគ្រប់ប្រភេទយន្តហោះ( Aircraft Registration )<br>• ថតចម្លងវិញ្ញាបនបត្រធានារ៉ាប់រង ( Insurance Certificate and Coverage ) |
| **យោបល់** | |

**អាជ្ញាប័ណ្ណ៖ ចេញលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការ ហោះហើរក្រៅកម្មវិធី របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស**( Landing Permit to Operate Extra and Charter Flight )

| | |
|---|---|
| ឈ្មោះសេវា | ចេញលិខិតអនុញ្ញាត សម្រាប់ប្រតិបត្តិការហោះហើរក្រៅកម្មវិធី របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស<br>( Extra and Charter Flight ) |
| ក្រសួង/ស្ថាប័នផ្តល់សេវា | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្សី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស<br>ការិយាល័យអនុញ្ញាតហោះហើរ |
| គោលបំណងនៃការផ្តល់សេវា | ផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរតាមរដូវកាលដល់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| មូលដ្ឋានគតិយុត្ត | • សេចក្តីប្រកាសលេខ ១៣៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• Form 002/ATD |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| ស្តង់ដាសេវា | • មានរយៈពេល ០៧ថ្ងៃ ដើម្បីផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរក្រៅកម្មវិធី Extra and Charter Flight<br>• មានសុពលភាពរយៈពេល តាមការស្នើសុំ<br>• បង់ថ្លៃ ២០០ដុល្លា |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | • ពាក្យសុំ ( ០១ច្បាប់ )<br>• ថតចម្លងលិខិតចាត់តាំងករុមហ៊ុនអាកាសចរណ៍ចេញដោយអាជ្ញាធរអាកាសចរស៊ីវិល<br>• ថតចម្លងវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស( AOC )<br>• ថតចម្លងវិញ្ញាបនបត្រសុវត្ថិភាពហោះហើរគ្រប់ប្រភេទយន្តហោះ ( Airworthiness )<br>• ថតចម្លងវិញ្ញាបនបត្រចុះបញ្ជីគ្រប់ប្រភេទយន្តហោះ( Aircraft Registration )<br>• ថតចម្លងវិញ្ញាបនបត្រធានារ៉ាប់រង ( Insurance Certificate and Coverage ) |
| យោបល់ | |

**អាជ្ញាប័ណ្ណ៖ ចេញលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរ ដឹកទំនិញគ្រោះថ្នាក់ របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស**( Permission to Carry Dangerous Goods )

| | |
|---|---|
| ឈ្មោះសេវា | ចេញលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរដឹកទំនិញគ្រោះថ្នាក់ របស់ក្រុមហ៊ុន អាកាសចរណ៍ក្នុងស្រុក និងបរទេស<br>( Permission to Carry Dangerous Goods ) |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស<br>ការិយាល័យអនុញ្ញាតទំនិញគ្រោះថ្នាក់ |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរតាមរដូវកាលដល់ក្រុមហ៊ុន អាកាសចរណ៍ក្នុងស្រុក និងបរទេស |
| មូលដ្ឋានគតិយុត្ត | • សេចក្តីប្រកាសលេខ ១៣៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• Form 002/ATD |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| ស្តង់ដាសេវា | • មានរយៈពេល ០២ខែ ដើម្បីផ្តល់ការអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរដឹកទំនិញគ្រោះថ្នាក់<br>• មានសុពលភាពរយៈពេល 01ឆ្នាំ (ឬតាមការស្នើសុំ)<br>• បង់ថ្លៃ ៥០០ដុល្លា |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ពាក្យសុំ (០១ច្បាប់)<br>• ចំតចម្លងលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការហោះហើរដឹកទំនិញគ្រោះថ្នាក់ ចេញដោយអាជ្ញាធរអាកាសចរស៊ីវិល (Dangerous Goods Permit issued by the State of the Operator )<br>• ចំតចម្លងវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស(AOC)<br>• ចំតចម្លងក្បួនប្រតិបត្តិការទំនិញគ្រោះថ្នាក់(DG Ops Manuals) |
| យោបល់ | |

## អាជ្ញាប័ណ្ណ៖ ចេញលិខិតចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក ហោះហើរទៅកាន់បរទេស

( Letter of Designated Airline )

| | |
|---|---|
| ឈ្មោះសេវា | ចេញលិខិតចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក ហោះហើរទៅកាន់បរទេស ( Letter of Designated Airline ) |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស<br>ការិយាល័យចរាចរកិច្ចព្រមព្រៀង |
| គោលបំណង នៃការផ្តល់សេវា | ធ្វើការចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក ហោះហើរទៅកាន់បរទេស |
| មូលដ្ឋានគតិយុត្ត | សេចក្តីប្រកាសលេខ ១៣៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក |
| ស្តង់ដាសេវា | • មានរយៈពេល ២ខែ មុនថ្ងៃប្រតិបត្តិការហោះហើរ<br>• បង់ថ្លៃ ៥០០ដុល្លា |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ពាក្យសុំ ( ០១ច្បាប់ )<br>• កម្មវិធីហោះហើរ<br>• ឯកសារពាក់ព័ន្ធ |
| យោបល់ | |

# អាជ្ញាប័ណ្ណ ៖ វិញ្ញាបនបត្រអាកាសយានដ្ឋាន

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនបត្រអាកាសយានដ្ឋាន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន<br>ការិយាល័យវិញ្ញាបនប័ត្រអាកាសយានដ្ឋាន |
| គោលបំណង នៃការផ្តល់សេវា | ពង្រឹងសុវត្ថិភាពប្រតិបត្តិការអាកាសយានដ្ឋានអនុលោមតាមច្បាប់ជាតិ និងស្តង់ដាអន្តរជាតិ |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីអាកាសចរស៊ីវិលឆ្នាំ ១៩៩៨ជំពូកទី៦ មាត្រា ៣៤<br>• បទប្បញ្ញត្តិអាកាសចរស៊ីវិលឆ្នាំ ២០០៧ជំពូកទី ១២(CCAR, Part 12), បទប្បញ្ញត្តិព្រលានយន្តហោះ(Aerodromes Regulation)ប្រការ ១២.២ (§ 12.2, including latest amendment)<br>• ស្តង់ដាអង្គការអាកាសចរស៊ីវិលអន្តរជាតិICAO Annex 14, និងឧបសម្ព័ន្ធ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ប្រតិបត្តិករអាកាសយានដ្ឋាន ដែលមានអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការអាកាសយានដ្ឋាន |
| ស្តង់ដាសេវា | • ចេញវិញ្ញាបនប័ត្រថ្មី រយៈពេល ៦ខែ ,ចេញឡើងវិញរយៈពេល ៣ខែ<br>• សុពលភាព ៥ ឆ្នាំ<br>• បង់ថ្លៃ ៖ អាកាសយានដ្ឋានអន្តរជាតិ15,000$/ឆ្នាំ, អាកាសយានដ្ឋានមូលដ្ឋាន៣,000$/ឆ្នាំ, ឧទ្ធម្ភាគចក្រដ្ឋាន(Heliport) 2,400$/ឆ្នាំ, ព្រលានឧទ្ធម្ភាគចក្រ(Helipad)2,000$/ឆ្នាំ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ពាក្យសុំ<br>• ទម្រង់បំពេញពត៌មាន(Application form)<br>• កម្រងប្រតិបត្តិព្រលានយន្តហោះ(Aerodrome Manual, Aerodrome SMS Manual)<br>• សំណុំឯកសារឧបសម្ពន្ធ័(Annexes to the Aerodrome Manuals) |
| យោបល់ | • ក្រោយការទទួលឯកសារខាងលើមន្ត្រីអធិការព្រលានយន្តហោះនឹងចុះធ្វើសវនកម្មវិញ្ញាបនប័ត្រអាកាស យានដ្ឋានរួចចេញរបាយការណ៍កំហុសឬកង្វះខាត(Finding)<br>• ក្រោយការកែតម្រូវកំហុសឬកង្វះខាតតបតាមផែនការសកម្មភាព (Corrective Action Plan)បានទាំងស្រុងឬមួយចំនួនសមស្រប ទើបធ្វើការចេញវិញ្ញាបនប័ត្រអាកាសយានដ្ឋាន<br>• ក្រោយការចេញវិញ្ញាបនប័ត្រអាកាសយានដ្ឋានមន្ត្រីអធិការនៅបន្តតាមដាន (Inspection)និង ពិនិត្យលទ្ធផលកែតម្រូវកំហុសឬកង្វះខាតខាងលើតាមកាលវិភាគនិងក្រៅកាលវិភាគ |

# អាជ្ញាប័ណ្ណ ៖ ការចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស

| | |
|---|---|
| ឈ្មោះសេវា | ការចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្សី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានស្តង់ដារនិងសុវត្ថិភាពហោះហើរ |
| គោលបំណង នៃការផ្តល់សេវា | ត្រួតពិនិត្យលើការផ្តល់វិញ្ញាបនបត្រប្រតិបត្តិការហោះហើរឲ្យស្របតាមតម្រូវការអប្បបរមា |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីអាកាសចរស៊ីវិល ជំពូកទី ១០ មាត្រា ៥៤<br>• Part-9 Air Operator Certification Requirements |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | នីតិបុគ្គល |
| ស្តង់ដាសេវា | **១- ចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស (លើកដំបូង)**<br>• អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg តម្លៃសេវា 50,000 $ រយៈពេលផ្តល់សេវា ៣ ខែ សុពលភាព ១ ឆ្នាំ ។<br>• អាកាសយានធុនស្រាល ( Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T តម្លៃសេវា 100,000$ រយៈពេលផ្តល់សេវា ៣ ខែសុពលភាព ១ ឆ្នាំ។<br>• អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136 T ឡើងទៅ តម្លៃសេវា 150,000 $ រយៈពេលផ្តល់សេវា ៣ ខែ សុពលភាព ១ ឆ្នាំ ។<br>**២. ចេញវិញ្ញាបនបត្រពន្យាសុពលភាពប្រតិបត្តិការផ្លូវអាកាស**<br>• អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg តម្លៃសេវា 5,000 $ រយៈពេលផ្តល់សេវា ២ ខែ សុពលភាព ១ ឆ្នាំ ។<br>• អាកាសយានធុនស្រាល ( Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T តម្លៃសេវា 10,000$ រយៈពេលផ្តល់សេវា ២ខែ សុពលភាព ១ ឆ្នាំ។<br>• អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136 T ឡើងទៅ តម្លៃសេវា 15,000 $ រយៈពេលផ្តល់សេវា ២ ខែ សុពលភាព ១ ឆ្នាំ ។<br>**៣. ការប្រែប្រួល (បន្ថែម/ បន្ថយយន្តហោះ) លក្ខខណ្ឌកិច្ចប្រតិបត្តិការហោះហើរ អមវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស**<br>• អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg តម្លៃសេវា 1,000 $ រយៈពេលផ្តល់សេវា 2 ខែ សុពលភាពអចិន្ត្រៃយ៍ ។<br>• អាកាសយានធុនស្រាល ( Medium Aircraft ) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T តម្លៃសេវា 2,000$ រយៈពេលផ្តល់សេវា 2ខែសុពលភាពអចិន្ត្រៃយ៍។<br>• អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136 T |

| | |
|---|---|
| | ឡើងទៅ តម្លៃសេវា 3,000 $ រយៈពេលផ្តល់សេវា ២ ខែ សុពលភាពអចិន្ត្រៃយ៍ ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • មានការចុះបញ្ជីក្រុមហ៊ុនស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>• មានទីតាំងកន្លែងធ្វើការច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រម្ពុជា<br>• បំពេញបែបបទតាមបទបញ្ញត្តិ AOCR។<br>• មានរយៈពេល ៦ខែ ចាប់ពីដំណើរការដើម្បីផ្តល់វិញ្ញាបនប្រតិបត្តិការផ្លូវអាកាស<br>• សុពលភាពវិញ្ញាបនបត្រ រយៈពេល ១ ឆ្នាំ។ |
| **យោបល់** | • នីតិបុគ្គលដែលប្រកបអាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាសត្រូវមានវិញ្ញាបនប្រតិបត្តិការផ្លូវអាកាស ។<br>• ករណីគ្មានអាជ្ញាប័ណ្ណ ឬគ្មានសុពលភាពត្រូវទទួលទោសតាមច្បាប់អាកាសចរស៊ីវិល ជំពូកទី ១០ មាត្រា ៥៣ ។ |

# អាជ្ញាប័ណ្ណ៖ វិញ្ញាបនបត្រអង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយាន

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនប័ត្រអង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយាន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានលទ្ធភាពហោះហើរ<br>ការិយាល័យ : វិញ្ញាបនកម្មប្រតិបត្តិករ និងអង្គភាពថែរក្សាបច្ចេកទេសអាកាសយាន |
| គោលបំណង នៃការផ្តល់សេវា | • ឲ្យស្របតាមច្បាប់ និងបទបញ្ញាតិអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា<br>• ឲ្យស្របតាមស្តង់ដាអប្បរមា ICAO |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ជំពូក២ មាត្រា៦<br>• បទបញ្ញាត្តិអាកាសចរស៊ីវិល( CCARs Part 6 ) |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ក្រុមហ៊ុន |
| ស្តង់ដាសេវា | **១- អង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយានធុនស្រាល ( ទម្ងន់ហោះឡើងសរុបតិចជាង 5,700 គក្រ )**<br>១.១ ឯកភាព តម្លៃសេវា 1,200$/ដង រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង៣ខែ សុពលភាព១ឆ្នាំ<br>១.២ បន្តឯកភាព តម្លៃសេវា 1,000$/ដង រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង៣ខែ សុពលភាព១ឆ្នាំ<br>**២- អង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយានធុនស្រាល ( ទម្ងន់ហោះឡើងសរុបចាប់ពី 5,700 គក្រ )**<br>២.១ ឯកភាព តម្លៃសេវា 2,400$/ដង រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង៣ខែ សុពលភាព១ឆ្នាំ<br>២.២ បន្តឯកភាព តម្លៃសេវា 2,400$/ដង រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង៣ខែ សុពលភាព១ឆ្នាំ<br>**៣- អាជ្ញាប័ណ្ណស្ថានីយប្រេងអាកាសយាន តម្លៃសេវា 1,800/ដង រយៈពេល ផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង៣ខែ សុពលភាព១ឆ្នាំ**<br>**៤- បន្តអាជ្ញាប័ណ្ណស្ថានីយប្រេងអាកាសយាន តម្លៃសេវា 1,400/ដង រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង៣ខែ សុពលភាព១ឆ្នាំ**<br>**៥- វិញ្ញាបនបត្រ ឬអាជ្ញាប័ណ្ណ ទុតិយតា តម្លៃសេវា 100$/ដង រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) ១៤ថ្ងៃ សុពលភាពផ្អែកលើឯកសារដើម**<br>**៦- ផ្តល់ការអនុញ្ញាតិ ឬការកែប្រែនូវឯកសារបច្ចេកទេសផ្សេងៗ តម្លៃសេវា 100$/ដង រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) ១៤ថ្ងៃ សុពលភាពផ្អែកលើឯកសារដើម** |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • ដាក់ពាក្យសុំ<br>• បំពេញពាក្យស្នើសុំ<br>• ភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ |

| | |
|---|---|
| **យោបល់** | • អង្គភាពជួសជុល ថែរក្សាបច្ចេកទេសអាកាសយានណា ដែលផ្តត់ផ្គង់សេវាបច្ចេកទេស ដល់អាកាសយានដែលចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមាន វិញ្ញាបនប័ត្រដែលផ្តល់ជូនដោយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។<br>• អង្គភាពប្រេងដែលផ្គត់ផ្គង់សេវា ដល់អាកាសយាននានា ត្រូវតែមានវិញ្ញាបនប័ត្រ<br>• ដែលផ្តល់ជូនដោយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដែរ។ |

## **អាជ្ញាប័ណ្ណ៖ វិញ្ញាបនបត្រចុះបញ្ជីអាកាសយាន**

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនបត្រចុះបញ្ជីអាកាសយាន |
| ក្រសួង/ស្ថាប័នផ្តល់សេវា | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានលទ្ធភាពហោះហើរ<br>ការិយាល័យ : វិញ្ញាបនកម្មអាកាសយាន |
| គោលបំណងនៃការផ្តល់សេវា | • ឲ្យស្របតាមច្បាប់ និងបទបញ្ញត្តិអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា<br>• ឲ្យស្របតាមស្តង់ដាអប្បរមា ICAO |
| មូលដ្ឋានគតិយុត្ត | • ច្បាប់ស្តីពីអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ជំពូក២ មាត្រា៦<br>• បទបញ្ញាត្តិអាកាសចរស៊ីវិល(CCARs Part 4.5) |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ក្រុមហ៊ុន ឬបុគ្គល |
| ស្តង់ដាសេវា | **១-ចេញវិញ្ញាបនបត្រអាកាសយានធុនស្រាល(ទម្ងន់ហោះឡើងសរុបតិចជាង 5,700 គក្រ) សម្រាប់:**<br>១.១ ចុះបញ្ជី តម្លៃសេវា500$ រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាពអចិន្ត្រៃយ៍<br>១.២ ដកបញ្ជី តម្លៃសេវា100$ រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាពអចិន្ត្រៃយ៍<br>១.៣ លទ្ធភាពហោះហើរ 1,000$/ដង រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង ២ខែ សុពលភាព១ឆ្នាំ<br>១.៤ បន្តលទ្ធភាពហោះហើរ 700$/ដង រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាព១ឆ្នាំ<br>១.៥ លទ្ធភាពហោះហើរនាំចេញ1,000$/ដងរយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាព១ឆ្នាំ<br>**២-ចេញវិញ្ញាបនបត្រអាកាសយានធុនធ្ងន់(ទម្ងន់ហោះឡើងសរុបចាប់ពី 5,700 គក្រ) សម្រាប់:**<br>២.១ ចុះបញ្ជី តម្លៃសេវា 100kg=7$ ទម្ងន់ហោះឡើងសរុប រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាពអចិន្ត្រៃយ៍<br>២.២ ដកបញ្ជី តម្លៃសេវា 100kg=1$ ទម្ងន់ហោះឡើងសរុប រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាពអចិន្ត្រៃយ៍<br>២.៣ លទ្ធភាពហោះហើរ តម្លៃសេវា 100kg=12$ ទម្ងន់ហោះឡើងសរុប រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង២ខែសុពលភាព១ឆ្នាំ<br>២.៤ បន្តលទ្ធភាពហោះហើរ តម្លៃសេវា 100kg=10$ ទម្ងន់ហោះឡើងសរុប រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាព១ឆ្នាំ<br>២.៥ លទ្ធភាពហោះហើរនាំចេញ តម្លៃសេវា 100kg=12$ ទម្ងន់ហោះឡើងសរុប រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពល |

| | |
|---|---|
| | ភាព១ឆ្នាំ<br>៣- អាជ្ញាប័ណ្ណវិទ្យុអាកាសយាន តម្លៃសេវា 150$/ដង រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាព២ឆ្នាំ<br>៤- បន្តអាជ្ញាប័ណ្ណវិទ្យុអាកាសយាន តម្លៃសេវា 100$/ដង រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) មិនតិចជាង២ខែ សុពលភាព២ឆ្នាំ<br>៥- វិញ្ញាបនបត្រសម្លេង តម្លៃសេវា 150$ រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) មិនតិចជាង ២ខែ សុពលភាពអចិន្ត្រៃយ៍ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | • ដាក់ពាក្យសុំ<br>• បំពេញពាក្យស្នើសុំ<br>• ភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ |
| **យោបល់** | គ្រប់អាកាសយានទាំងអស់ត្រូវតែមាន៖<br>• សញ្ញាជាតិ និងសញ្ញាចុះបញ្ជី<br>• វិញ្ញាបនបត្របញ្ជាក់លទ្ធភាពហោះហើរ ដែលមានសុពលភាព<br>• អាជ្ញាប័ណ្ណបញ្ជាក់ពីប្រភេទឧបករណ៍វិទ្យុសំខាន់ៗ ដែលបំពាក់លើអាកាសយាន<br>• អាជ្ញាប័ណ្ណបញ្ជាក់ពីកំរិតសម្លេងម៉ាស៊ីនអោយស្របតាម ICAO Annex 16 ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទៅលើសុវត្ថិភាពហោះហើរ។ |

## អនុបាលទី ៖ ចេញលិខិតអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរអាកាសយាន ឬផ្លាស់ប្តូរផ្លូវហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស

| | |
|---|---|
| **ឈ្មោះសេវា** | ចេញលិខិតអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរអាកាសយាន ឬផ្លាស់ប្តូរផ្លូវហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| **ក្រសួង/ស្ថាប័ន ផ្តល់សេវា** | រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស<br>ការិយាល័យអនុញ្ញាតហោះហើរ |
| **គោលបំណង នៃការផ្តល់សេវា** | ផ្តល់ការអនុញ្ញាត សម្រាប់ប្រតិបត្តិការហោះហើរក្រៅកម្មវិធី ដល់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| **មូលដ្ឋានគតិយុត្ត** | • សេចក្តីប្រកាសលេខ ១៣៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• Form 003/ATD |
| **អតិថិជនដែលមាន សិទ្ធទទួលសេវា** | ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស |
| **ស្តង់ដាសេវា** | • មានរយៈពេល ០៧ថ្ងៃ ដើម្បីផ្តល់ការអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរប្រភេទអាកាសយាន ឬផ្លាស់ប្តូរផ្លូវហោះហើរ<br>• មានសុពលភាពរយៈពេលតាមការស្នើសុំ<br>• បង់ថ្លៃ ២០០ដុល្លារអាមេរិក |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | • ពាក្យសុំ (០១ច្បាប់)<br>• ថតចម្លងលិខិតចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ចេញដោយអាជ្ញាធរអាកាសចរស៊ីវិល<br>• ថតចម្លងវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស (AOC)<br>• ថតចម្លងវិញ្ញាបនបត្រសុវត្ថិភាពហោះហើរគ្រប់ប្រភេទយន្តហោះ (Airworthiness)<br>• ថតចម្លងវិញ្ញាបនបត្រចុះបញ្ជីគ្រប់ប្រភេទយន្តហោះ (Aircraft Registration)<br>• ថតចម្លងវិញ្ញាបនបត្រធានារ៉ាប់រង (Insurance Certificate and Coverage) |
| **យោបល់** | |

## អាជ្ញាប័ណ្ណ៖ ផ្តល់ការបណ្តុះបណ្តាល ធ្វើតេស្ត និងបន្តវិញ្ញាបនបត្រថ្នាក់បឋម

| | |
|---|---|
| ឈ្មោះសេវា | ផ្តល់ការបណ្តុះបណ្តាល ធ្វើតេស្ត និងបន្តវិញ្ញាបនបត្រថ្នាក់បឋម |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>• បរិវេណក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ<br>• ទូរស័ព្ទ: ០២៣ ៨៦៦ ០១៩<br>• ទូរសារ: ០២៣ ៨៦៦ ០១៩<br>នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល |
| គោលបំណង នៃការផ្តល់សេវា | • ផ្តល់ការបណ្តុះបណ្តាល និងចេញវិញ្ញាបនបត្រសន្តិសុខថ្នាក់បឋម<br>• ធ្វើតេស្ត និងបន្តវិញ្ញាបនបត្រថ្នាក់បឋមឲ្យស្របតាមច្បាប់ |
| មូលដ្ឋានគតិយុត្ត | • សេចក្តីប្រកាសលេខ ១៣៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• Annex 17 of Chicago Convention<br>• National Civil Aviation Security Program<br>• National Civil Aviation Security Training Program<br>• Screener Certification Program |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | ជនជាតិខ្មែរ ឬជនជាតិបរទេស |
| ស្តង់ដាសេវា | • រយៈពេល ១២ថ្ងៃ<br>• មានសុពលភាពរយៈពេល ២ឆ្នាំ<br>• បង់ថ្លៃ ៥០ដុល្លារអាមេរិចក្នុង១នាក់<br>• រយៈពេល ៥ថ្ងៃ<br>• មានសុពលភាពរយៈពេល ២ឆ្នាំ<br>• បង់ថ្លៃ ២៥ដុល្លារអាមេរិកក្នុង១នាក់ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | • បញ្ជីរាយនាមសិក្ខាកាម<br>• ប្រវត្តិរូប ០១ច្បាប់<br>• រូបថត ៤X៦ ចំនួន ០២សន្លឹក |
| យោបល់ | ដើម្បីយោងតាមតម្រូវការច្បាប់ជាតិ និងអន្តរជាតិ |

**អាជ្ញាប័ណ្ណ៖ ពិនិត្យ ផ្តល់ការយល់ព្រម និងបន្តសុពលភាពលើកម្មវិធីសន្តិសុខអាកាសយានដ្ឋាន និងកម្មវិធីសន្តិសុខក្រុមហ៊ុនអាកាសចរណ៍**

| | |
|---|---|
| ឈ្មោះសេវា | ពិនិត្យ ផ្តល់ការយលព្រម និងបន្តសុពលភាពលើកម្មវិធីសន្តិសុខអាកាសយានដ្ឋាន និងកម្មវិធីសន្តិសុខក្រុមហ៊ុនអាកាសចរណ៍ |
